ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Jun-2012, 15:48
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៧៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាតាចា វីស៊ែល រីស៊ើ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក រេយ៍ន័រ កែត *(Mr.RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកធួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោក គ្រីស្ទីន ម៉ាទីណូ

*(Mr. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក វ៉េង ហ៊ាត់ | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក យុន គីម (TCW-797) | ខ្មែរ |
| លោក ខៀវ នៅ (TCW-321) | ខ្មែរ |
| លោក នួន ជា | ខ្មែរ |

# ឧបសម្ព័ន្ធ


**ការសួរសំណួរទៅសាក្សី៖ លោក យុន គីម ហៅ ខាំ** (TCW-797)

ស្តួរដោយលោក វ៉ែន ពៅ ផ្តើមពី៖ ..................................................ទំព័រ ២

សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី៖ ..................................................ទំព័រ២១

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖ ..................................................ទំព័រ២៧

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី៖ ..................................................ទំព័រ៤៦

សួរដោយលោក សុន អរុណ ផ្តើមពី៖ ..................................................ទំព័រ ៦១

សួរដោយលោក អាកទួរ វែកគែន ផ្តើមពី៖ ..................................................ទំព័រ៧០

**ការសួរសំណួរទៅសាក្សី៖ លោក ខៀវ នៅ** (TCW-321)

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី៖ ..................................................ទំព័រ៧៥

សួរដោយលោក វ៉េង ហ៊ាត់ ផ្តើមពី៖ ..................................................ទំព័រ៧៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅថ្ងៃនេះយើងនឹងបន្តស្តាប់សក្ខីកម្មសាក្សី យុន គីម ដែលនឹងការ-- បន្តការតាំងសំណួរដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រឡាបញ្ជី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែលោកមេធាវី ម៉ៃខល កាណាវាស មេធាវីអន្តរជាតិការពារក្តីឲ្យលោក អៀង សារី អវត្តមានដោយមិនដឹងពីមូលហេតុ។ ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់ខ្លួន ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដោយឡែកសាក្សីបម្រុង TCW-323 មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

[០៩:០៣:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយគាត់សុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ដោយមានបញ្ហាសុខភាព មិនអាចអង្គុយតាមដានស្តាប់នូវកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។ អនុសាសន៍របស់វេជ្ជបណ្ឌិតដែលទទួលបន្ទុក

ពិនិត្យថែទាំសុខភាពព្យាបាលជនជាប់នៅមន្ទីរឃុំឃាំង អ.វ.ត.ក ក៏បានផ្តល់នូវអនុសាសន៍ថានៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ ជនជាប់ចោទគួរតែត្រូវបានទទួលការអនុញ្ញាតឲ្យនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដោយហេតុលោក អៀង សារី មានអាការៈវិលមុខ ហេវហត់ និងជាពិសេសនៅពេលឡើងជណ្តើរ និងពុំមានលទ្ធភាពអង្គុយយូរបាន។

[០៩:០៤:២៥]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បាន។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ឲ្យផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការពីចម្ងាយសម្រាប់រយៈពេលដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅ ក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

[០៩:០៥:៤១]

**លោក វ៉ែន ពៅ៖**

សូមៗអរគុណលោកប្រធាន។ ជាបឋមខ្ញុំបាទសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពតំណាងព្រះរាជអាជ្ញា និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ខ្ញុំបាទសូមជម្រាបសួរលោក យុន គីម។ ក្នុងនាមខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្ប-

វេណី ខ្ញុំមានសំណួរមួយចំនួនដែលត្រូវសួរលោកនាពេលនេះ។ ឆ្លងតាមបទពិសោធន៍ ក៏ដូចជាចំណេះដឹង ក្នុងឋានៈលោកធ្លាប់ជាមេឃុំ ក៏ដូចជាធ្លាប់ជាប្រធានសហករណ៍នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ខ្ញុំសូមស្នើឲ្យលោកជួយបំភ្លឺ និងបញ្ជាក់បន្ថែមនូវចំណុចមួយចំនួន ដែលពាក់ព័ន្ធពីអ្វីដែលលោកបានដឹង បានឃើញ បានឮនៅក្នុសម័យនោះ។ ខ្ញុំចង់សួរលោកថា កាលពីម្សិលមិញលោកបានឆ្លើយនឹងសំណួររបស់សហព្រះរាជអាជ្ញាមួយចំនួនហើយ ក្នុងនោះពាក់ព័ន្ធនឹងការដែលលោកចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា។ សំណួររបស់ខ្ញុំចង់សួរថាតើមុននឹងលោកក្លាយជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា តើលោកចូលចលនាបដិវត្តន៍ខ្មែរក្រហមនៅពេលណាដែរបាទ?

[០៩:០៦:៥៦]

**លោក យុន គីម៖**

**ឆ៖** ខ្ញុំសូមអធ្យាស្រ័យ ព្រោះស្អក-កថ្ងៃនេះ។ ខ្ញុំបានចូលរួមក្នុងចលនាបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ គឺនៅក្រោយពេលដែលខេត្តក្រចេះបានរំដោះហ្នឹង ខ្ញុំក៏បានចូលរួមក្នុងចលនានេះ។ ហើយដល់មកថ្ងៃទី០៤ ខែ៣ ឆ្នាំ១៩៧១ ហ្នឹងគឺខាងថ្នាក់ស្រុកនេះបានតែងតាំងខ្ញុំឲ្យធ្វើជាមេឃុំនៅវឌ្ឍនៈហ្នឹងតែម្តង នៅពេលដែលឃុំនេះចាប់ផ្តើមធ្វើជាឃុំថ្មីមួយ ពីមុននៅក្នុងឃុំផ្សេងទៀតទេ ប៉ុន្តែដល់នេះគេបំបែកឃុំវឌ្ឍនៈហ្នឹងជាឃុំថ្មីមួយ បាទ។ ហើយខ្ញុំចូលរួមពីឆ្នាំ៧០ ក្រោយរដ្ឋប្រហារហ្នឹង។ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ស៖** តើលោកអាចបញ្ជាក់បានទេ តើមូលហេតុអ្វីទៅបានលោកសម្រេចចិត្តចូលចលនាបដិវត្តន៍ខ្មែរក្រហម? ជាការបង្ខិតបង្ខំ ឬក៏ជាការស្ម័គ្រចិត្តរបស់លោក?

[០៩:០៨:០៨]

**ឆ៖** យើងដឹងហើយថានៅពេលនោះវាមានជាចលនា បាទចលនាបដិវត្តន៍មកដល់។ ក្នុងខណៈខ្ញុំដែលជាកសិករមួយរូបនៅភូមិវឌ្ឍនៈហ្នឹង ហើយបើសិនណាជាយើងមិនចូលរួមជាមួយចលនានេះទេ គឺយើងអាចទទួលគ្រោះថ្នាក់នៅថ្ងៃណាមួយ។ ពីព្រោះយើងឃើញថា ចលនានេះលក្ខណៈស្រួចស្រាល់ដែរ។ អ៊ីចឹងដើម្បីយល់ដឹងពីបញ្ហាបដិវត្តន៍នេះ យើង-- ខ្ញុំក៏សម្រេចចិត្តចូលរួមដើម្បីឲ្យបានទទួលនូវការយល់ដឹងពីបញ្ហានេះកាន់តែជ្រៅទៅទៀត។ ម្យ៉ាងដើម្បីការពារខ្លួនឯងផង ម្យ៉ាងជាគោលគំនិតគឺដើម្បីការពារប្រជាពលរដ្ឋផង។ ខ្ញុំសូមមានមតិប៉ុណ្ណេះ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានសំណួរមួយចំនួនទៀតពាក់ព័ន្ធទៅនឹងការជួបប្រជុំរបស់លោក

ជាមួយនឹងលោក នួន ជា នៅខេត្តក្រចេះដែលជាតំបន់៥០៥នោះ នៅក្នុងឆ្នាំ១៩៧៣។ ខ្ញុំចង់សួរថា នៅពេលដែលលោកជួបជាមួយលោក នួន ជា នៅពេលនោះ តើក្រៅពីលោក នួន ជា តើមានមេដឹកនាំបក្សកុម្មុយនីស្តដទៃផ្សេងទៀតមកចូលរួមប្រជុំទេនៅពេលនោះ?

[០៩:០៩:៤០]

**ឆ៖** នៅពេលដែលលោក នួន ជា បានអញ្ជើញទៅកាន់ហៅ ដ-៣ កន្លែងឃុំដារហ្នឹង ទិសដៅសំខាន់គឺអប់រំណែនាំអំពីការរៀបចំធ្វើក្រុមប្រវាស់ ក្រុម-- សហករណ៍កម្រិតទាប ឬកម្រិតខ្ពស់នោះ កម្មាភិបាលដែលទៅរួមដំណើរជាមួយគាត់ គឺដូចអត់ឃើញមានអ្នកណាទេ ពីព្រោះក្នុងឱកាសប្រជុំនោះ គណៈអធិបតីមានតែគណៈតំបន់៥០៥ហ្នឹង ជាមួយនឹងលោក នួន ជា ប៉ុណ្ណឹងបាទ។ ខ្ញុំសូមអស់មតិ។

**ស៖** ក្រៅពីលោក នួន ជា បាននិយាយអំពីរឿងការធ្វើសហករណ៍កម្រិតទាប ឬក៏សហករណ៍កម្រិតខ្ពស់ តើលោកនៅចាំបានទេ លោក នួន ជា មាននិយាយអំពីផែនការវាយប្រយុទ្ធប្រទេសកម្ពុជាចុងក្រោយទាំងមូលទេបាទ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាដែល-- អំពីសភាពការណ៍សង្គ្រាមនៅពេលនោះ នៅឆ្នាំ១៩៧៣នេះ ប្រទេសជាតិយើងកំពុងតែមានសង្គ្រាមយ៉ាងក្តៅគគុកជាមួយនឹងពួក លន់ នល់ ដែលមានពួកអាមេរិកាំងជាអ្នកគាំទ្រ។ ជាធម្មតារាល់ការប្រជុំរបស់ ថាបក្សកុម្មុយនីស្តចុះ នៅស្រុកក្តី នៅខេត្តក្តី សភាពការណ៍នេះគឺគេអត់និយាយចុងក្រោយទេ គឺនិយាយពីដំបូង។ ដំបូងឡើងនិយាយពីសភាពការណ៍។ បាទខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[០៩:១១:១៨]

**ស៖** តើលោកមានដឹងទេថា នៅពេលនោះលោក នួន ជា មាននិយាយណែនាំ ឬក៏ពីគោលនយោបាយនៃការឲ្យតែតាមមូលដ្ឋាន ឬសហករណ៍នានាត្រៀមរៀបចំទទួលប្រជាជនដែលត្រូវជម្លៀសមកពីក្នុងទីក្រុងផ្សេងៗទេ នៅពេលដែលប្រទេសត្រូវបានរំដោះ?

**ឆ៖** បាទ នៅពេលនោះ គឺពាក់ព័ន្ធនឹងបញ្ហាការណែនាំជម្លៀសប្រជាពលរដ្ឋចេញពីទីក្រុងអីមិនទាន់មានគោលការណ៍និយាយទេបាទ ពីព្រោះសភាពសង្គ្រាមកំពុងតែនៅបន្ត។ អ៊ីចឹងគាត់អត់ទាន់មានណែនាំថា បើយើងឈ្នះរំដោះជម្លៀសប្រជាជនចេញអីទេ គឺអត់ទាន់មាននិយាយអារឿងហ្នឹង។ ខ្ញុំសូមអស់មតិ។

**ស៖** បាទ កាលពីម្សិលមិញផងដែរ លោកបានឆ្លើយទៅនឹងសំណួររបស់សហចៅក្រម-- អំ

សហព្រះរាជអាជ្ញាថា ក្រោយពេលដែលលោកបានជួបប្រជុំជាមួយលោក នួន ជា ហើយ ឈ្មោះ ចែត ដែលជាលេខាស្រុកសំបូរបានហៅលោក ដែលជាគណៈឃុំទៅណែនាំទាំងអស់នៅក្នុងស្រុកសំបូរឱ្យរៀបចំជាសហគមន៍វិញ មិនឱ្យធ្វើជាសហករណ៍ទេ។ ខ្ញុំចង់សួរលោកថា តើមានលក្ខណៈខុសគ្នាបែបណាទៅរវាងសហគមន៍ និងសហករណ៍នោះបាទ?

[០៩:១២:៤៨]

**ឆ៖** សហគមន៍ និងសហករណ៍មានលក្ខណៈខុសគ្នា។ សហករណ៍បានន័យថាយើងធ្វើការងាររួម តែយើងចែកផលៗគ្នា។ ឯសហគមន៍នេះ គឺប្រមូលអ្វីៗទាំងអស់ដាក់រួម ធ្វើរួមគ្នា ហូបរួមគ្នាដែរ អត់មានចែកផលទេបាទ។ សូមអស់មតិ។

**ស៖** តើការធ្វើសហគមន៍ដែលលោកបានធ្វើនៅក្នុងស្រុកសំបូរទាំងមូល ធ្វើរហូតដល់ពេលណាបានចប់បាទ?

**ឆ៖** សហគមន៍នេះគឺយើងចាប់ធ្វើតាំងពីឆ្នាំ១៩៧៣ តាមបទបញ្ជារបស់លោក ចែត ហ្នឹងបាទ រហូតដល់យើងរំដោះឆ្នាំ៧៥ តែម្តង ព្រោះនៅតែហូបរួមទាំងអស់គ្រប់កន្លែងបាទ។ សូមអស់មតិ។

**ស៖** បាទ សំណួរខ្ញុំមួយទៀតពាក់ព័ន្ធនឹងការជួបជាមួយលោក នួន ជា នេះ នៅពេលនោះដែរ ខ្ញុំចង់លោក តើលោកមានបានដឹង ឬមានអ្នកណានិយាយប្រាប់លោកទេថា តើលោក នួន ជា មានឋានៈជាអ្វីដែរ តួនាទីជាអ្វីដែលនៅពេលនោះបាទ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាបាទ?

[០៩:១៤:០៥]

**ឆ៖** ចំពោះតួនាទីរបស់លោក នួន ជា នៅពេលនោះ ខ្ញុំអត់បានដឹងប្រាកដថាគាត់មានតួនាទីជាស្អី ប៉ុន្តែគ្រាន់តែដឹងថាគាត់នៅក្នុងមជ្ឈិមបក្សបាទ។ បានន័យថានៅក្នុងថ្នាក់ដឹកនាំកំពូលនៃបក្សកុម្មុយនីស្តកម្ពុជា។

**ស៖** បាទ សូមអរគុណ។ ខ្ញុំនឹងចូលទៅប្រធានបទមួយទៀតពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធមូលដ្ឋាន រដ្ឋបាលខាងសហករណ៍ និងឃុំបាទ។ នៅក្នុងការស្តាប់ចម្លើយរបស់លោកនៅការិយាល័យសហចៅក្រមស៊ើបអង្កេត លោកបានបញ្ជាក់ហើយថា នៅក្នុងឃុំសំបូរ គឺមានបំបែកជាពីរសហករណ៍ គឺសហករណ៍សំបូរ និងសហករណ៍ស្រែខឿន។

**លោក វ៉ែន ពៅ៖**

លោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតបង្ហាញឯកសារដែលជាការស្តាប់ចម្លើយរបស់សាក្សី ដែល

ដើម្បីដាក់បង្ហាញបាទ ហើយខ្ញុំនឹងសួរចេញពីហ្នឹង គឺដែលមាន-- គឺឯកសារដែលមានលេខ D125/184 ERN ជាភាសាខ្មែរ 00340150, ERN ជាភាសាអង់គ្លេស 00345192, ERN ជាភាសាបារាំង 00404178។

[០៩:១៥:៥០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉េន ពៅ៖**

**ស៖** ក្នុងនោះ ខ្ញុំសូមគ្រាន់តែអានចម្លើយលោក លោកបានឆ្លើយថា៖ "ក្រោយពីមានការបែងចែកសហករណ៍សំបូរ និងសហករណ៍ស្រែខឿន គេលែងនិយាយពីឃុំទៀតហើយ គេនិយាយតែពីសហករណ៍ប៉ុណ្ណោះ"។

សំណួររបស់ខ្ញុំចង់សួរថា លោកចង់បញ្ជាក់បានន័យថា នៅពេលនោះគ្មានមេឃុំ ឬគណៈឃុំទៀតទេ ឬក៏លោក ខ្លួនលោក មានតួនាទីជាមេឃុំភូមិផង និងជាប្រធានសហករណ៍ផងបាទ?

**លោក យុន គីម៖**

**ឆ៖** បាទ នៅពេលដែល គេកំណត់ថាបែងចែកទៅជាសហករណ៍ មេឃុំហ្នឹងមានតួនាទីជាប្រធានសហករណ៍តែម្តង អត់មានមេឃុំផ្សេង ប្រធានសហករណ៍ផ្សេងទេ គឺមេឃុំមានតួនាទីជាប្រធានសហករណ៍។ ឯមេភូមិ គឺយើងរៀបចំទៅជាមេបញ្ជាការមុខព្រួញ ឧទាហរណ៍ថាមួយភូមិហ្នឹងគេបែងចែកប៉ុន្មានមុខព្រួញ គឺមេភូមិហ្នឹងគាត់ទទួលខុសត្រូវតាមមុខព្រួញហ្នឹង។ បាទ ខ្ញុំសូមអស់មតិ។

[០៩:១៧:៥៥]

**ស៖** ដូច្នេះមានន័យថា ឃុំសំបូរលែងមានមេឃុំហើយនៅពេលនោះ តើមែនទេ?

**ឆ៖** បាទ អត់មានមេឃុំទៀតទេ ព្រោះទៅជាប្រធានសហករណ៍ហើយ គេលែងនិយាយពីឃុំហើយ គេនិយាយពីសហករណ៍ទៅវិញ។ បាទ ខ្ញុំសូមអស់មតិហើយ។

**ស៖** កាលពីម្សិលមិញលោកបានបញ្ជាក់ផងដែរថា នៅក្នុងសហករណ៍ គឺមានការគ្រប់គ្រងដោយគណៈកម្មាធិការដែលមានគ្នាបីនាក់។ ខ្ញុំចង់សួរលោកថា តើគណៈកម្មាធិការគ្រប់គ្រងនោះគេហៅថាដូចម្តេច? ហៅថា ក្នុងការគ្រប់គ្រងគេហៅថា ប្រធានឃុំ គណៈឃុំ ឬក៏លេខាឃុំយ៉ាងម៉េចដែរ សូមលោកអាចរៀបរាប់បានទេបាទ?

**ឆ៖** ពេលទៅជាសហករណ៍នេះ គឺយើង វាទៅជាគណៈសហករណ៍វិញ អត់មានជាគណៈឃុំដូចមុនទេបាទ។ ហើយពាក់ព័ន្ធនឹងលេខាឃុំនេះ គឺអត់មានផ្លាស់ប្តូរអីទេ ឧបមាថា យើងពីមុនមកធ្វើមេឃុំ ឬមានតួនាទីជាលេខាឃុំ នៅពេលដែលយើងធ្វើជាប្រធានសហករណ៍ក៏នៅជាលេខាឃុំដដែល។ អាហ្នឹងពាក់ព័ន្ធនឹងការងារបក្ស ព្រោះការងារវាផ្នែកបក្សនេះ វានៅដដែលទេ អត់មានប្រែប្រួលបាទ។ ខ្ញុំសូមអស់មតិ ចប់។

[០៩:១៩:១៩]

**ស៖** តើក្នុងឋានៈលោកជាលេខាឃុំ ឬក៏គណៈឃុំនៅពេលនោះ ខ្ញុំចង់សួរលោកថា តើលោកដែលមានទទួលគោលការណ៍ ឬក៏ផែនការណែនាំពីថ្នាក់លើណាមួយឱ្យលោកបញ្ជូនមនុស្សណាដែលធ្វើខុស ឬមានកំហុស ដែលគេចាត់ទុកថាជាខ្មាំងទៅមន្ទីរសន្តិសុខណាមួយដែរឬទេ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាបញ្ជូននេះ វាពាក់ព័ន្ធនឹងការរាយការណ៍របស់យើង បើយើងខាងឃុំហ្នឹងរាយការណ៍ទៅថា ជននេះមួយមានសភាពមិនល្អអ៊ីចេះ ជននោះមួយមានសភាពមិនល្អអ៊ីចុះ អាហ្នឹងបានគេឱ្យយើងចាប់បញ្ជូន ហើយបើសិនណាយើងអត់មានរាយការណ៍ទៅថា ជននេះជាខ្មាំងនៅក្នុងសហករណ៍អីទេ អាហ្នឹងអត់មានទេ។ ហើយកន្លងមកខ្ញុំក៏មិនដែលបានចាប់បញ្ជូនបងប្អូនយើងទៅដែរ។

[០៩:២០:១៦]

ពីព្រោះពេលនោះ យុវជន យុវនារីនៅក្នុងសហករណ៍ក៏ដូចជានៅក្នុងឃុំអង្កាល់មុនយើងបង្កើតសហករណ៍យុវជន-នារី ចេញចង់អស់ហើយ ខ្លះទៅធ្វើទ័ព។ បាទភាគច្រើនទៅធ្វើទ័ព ខ្លះទៅបម្រើនៅអង្គភាពរបស់ស្រុក លើផ្នែកការងារផ្សេងៗ ខ្លះទៅអង្គភាពខេត្ត ខ្លះទៅចម្ការកៅស៊ូ។ អ៊ីចឹងនៅក្នុងសហករណ៍-- នៅក្នុងឃុំនេះកម្លាំងពលកម្មវាខើចមែនទែន។ ហើយខ្ញុំមានចំណាប់អារម្មណ៍មួយថា បើសិនណាជាងាកខ្មាំងៗទៅ វាប្រាកដជាអត់មានអ្នកណាបង្កបង្កើនផលនៅក្រោយហើយ។ ដូច្នេះហើយ ក្នុងឋានៈខ្ញុំជាអ្នកដឹកនាំឃុំ ខ្ញុំមិនដែលរាយការណ៍សម្លាប់ប្រជាជនឯងទេបាទ ពីព្រោះដូចខ្ញុំបញ្ជាក់ជូនក្នុងនេះខាងលើអ៊ីចឹង។ សូមអស់មតិ។

[០៩:២១:១៤]

**ស៖** ពាក់ព័ន្ធនឹងនៅសហករណ៍នុ៎ងដែរ ខ្ញុំចង់សួរពីមធ្យោបាយទំនាក់ទំនងការងារផ្សេងៗ។ តើលោកប្រើមធ្យោបាយច្រើនជាងគេនៅសម័យនោះ ពីថ្នាក់លើទៅថ្នាក់ក្រោម មធ្យោបាយទំនាក់ទំនងការងារដោយវិធីណាទៅបាទ?

**ឆ៖** បញ្ហាទំនាក់ទំនងគ្នាមានពីរ។ ឧទាហរណ៍ថា ពេលប្រជុំ ៗចប់យើងដាក់ផែនការប្រជុំថ្ងៃណាទៀត កំណត់ដូចខ្ញុំបានជម្រាបជូនពីម្សិលអ៊ីចឹង។ ថ្នាក់ស្រុកជាមួយនឹងឃុំ ប្រាំពីរថ្ងៃ គឺជួបគ្នាម្តងហើយបាទ។ រៀងរាល់ប្រាំពីរថ្ងៃ ឧបមាប្រជុំ ឧទាហរណ៍ថា យើងប្រជុំថ្ងៃហ្នឹង ដល់ថ្ងៃនេះឧទាហរណ៍ថា ថ្ងៃពុធអ៊ីចឹង ដល់ថ្ងៃពុធក្រោយយើង ៗមកជួបជុំគ្នាទៀត។ អ៊ីចឹងគេដាក់ផែនការជាស្រេចតែម្តង។ ហ្នឹងទីមួយ។

[០៩:២២:១១]

ទីពីរ ក្នុងករណីចាំបាច់ ឬមានករណីពិសេស ឬមានការងារក្រៅពីហ្នឹងទៀត ដែលយើងមិនបានដាក់ផែនការនៅពេលប្រជុំ គឺមាននីរសារបាទ។ ស្រុកគេមាននីរសារគេ ខាងឃុំក៏មាននីរសារដូចគ្នាអ៊ីចឹង។ បើសិនណាជាចាំបាច់នីរសារហ្នឹងត្រូវទៅស្រុក ខាងស្រុកមាននីរសារស្រុក គេមកខាងឃុំវិញ។ អានេះជាការងារដែលអនុវត្តនៅពេលនោះ។ ខ្ញុំសូមអស់មតិ។

**ស៖** បាទ ពាក់ព័ន្ធនឹងឃុំវិញម្តង។ លោកបានបញ្ជាក់ថា លោកធ្លាប់ធ្វើជាគណៈឃុំ ឬក៏ជាប្រធានឃុំ ចាប់ពីថ្ងៃទី០៤ ខែមីនា ឆ្នាំ៧១-- ១៩៧១ រហូតដល់ថ្ងៃ ខែកុម្ភៈ ឆ្នាំ១៩៧៧ គឺនៅក្នុងឃុំវត្តឈ្លន:។ ខ្ញុំចង់សួរថា តើនៅក្នុងឃុំវត្តឈ្លន:ដែលលោកកាន់កាប់នោះមានប៉ុន្មានសហករណ៍ដែរបាទ?

[០៩:២៣:១៦]

**ឆ៖** នៅឃុំវត្តឈ្លន:ដែលខ្ញុំកាន់កាប់ហ្នឹង គឺមានតែមួយសហករណ៍ទេ។ បាទ សហករណ៍មួយឃុំហ្នឹង គេរៀបចំតែមួយសហករណ៍បាទ។ គ្រាន់តែថាវាតាមភូមិមួយៗទៅគេបែងចែកជាមុខព្រួញទៅទៀតទៅ មុខព្រួញការងារ។ បាទ អ៊ីចឹងគឺដូចជាខ្ញុំបញ្ជាក់ជូនថា នៅសំបូរ បែងចែកជាពីរសហករណ៍។ ឯនៅវត្តឈ្លន:នេះតែមួយសហករណ៍។ ឃុំទូទៅគេតែមួយសហករណ៍ទេ ប៉ុន្តែដោយឃុំសំបូរនោះ វាធំក្រោយមក-- ពីមុនតែមួយដែរ ប៉ុន្តែដល់ក្រោយមកបានគេបែងចែកជាពីរៗសហករណ៍។ ឯនៅវត្តឈ្លន:នេះមានតែមួយសហករណ៍ទេ។ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[០៩:២៤:០៣]

**លោក វ៉ែន ពៅ៖**

លោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតដាក់បង្ហាញឯកសារមួយទៀតពាក់ព័ន្ធទៅនឹងចម្លើយរបស់សាក្សីដែរ នៅក្នុងឯកសារ D125/184 ដែលមាន ERN ជាភាសាខ្មែរគឺលេខ 00340150, ERN ជាភាសាអង់គ្លេសគឺលេខ 00345192 និង ERN ជាភាសាបារាំងគឺមានលេខ 00404178។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ នៅក្នុងចម្លើយខាងក្រោម សំណួរសួរថា៖ "ក្នុងរយៈកាលដែលលោកកាន់កាប់តំណែងនេះ ផែនការការងារដែលលោកបានណែនាំឲ្យថ្នាក់លើ-- អ៊ំ!ៗ សូមទោស ឲ្យថ្នាក់ក្រោមអនុវត្តរួមមានអ្វីខ្លះ?" លោកបានឆ្លើយថា "យើងហៅប្រធានភូមិមកប្រជុំនៅតាមមុខព្រួញដោយដាក់ផែនការ។ ការប្រជុំជាមួយភូមិធ្វើឡើងក្នុងអំឡុងមួយអាទិត្យម្តងបន្ទាប់ពីទទួលបានផែនការពីថ្នាក់លើ។ សំណួររបស់ខ្ញុំចង់សួរថាតើលោកចេះរបៀបធ្វើផែនការនេះពីណាមក តើលោកមានរៀនសូត្រពីអ្នកណា មានវគ្គបណ្តុះបណ្តាលបែបណាដែរបាទ?

**ឆ៖** រាល់ផែនការសកម្មភាព គឺយើងបាន-- ម្យ៉ាងជាការច្នៃប្រឌិត ប៉ុន្តែម្យ៉ាងទៀតជាការណែនាំរបស់ថ្នាក់លើដែរបាទ របស់ថ្នាក់ស្រុក។ ពេលយើងរៀនសូត្រ ក៏យើងគោលការណ៍ ជាវគ្គជាអីក៏មានណែនាំពាក់ព័ន្ធនឹងបញ្ហាការធ្វើផែនការការងារដែរបាទ។ ខ្ញុំសូមអស់មតិ។

**ស៖** តើលោកអាចបញ្ជាក់ឲ្យច្បាស់ជាងនេះទៀតបានទេ ថាពាក្យដែលលោកសំដៅថ្នាក់ហ្នឹងគឺសំដៅថ្នាក់ណាឡើងទៅ ខ្លះទៅបាទ?

**ឆ៖** ថ្នាក់លើដែលខ្ញុំបានលើកឡើងនេះ គឺមានតែថ្នាក់ស្រុក និងថ្នាក់តំបន់បាទ។

[០៩:២៦:២៧]

**ស៖** សូមអរគុណ។ ខ្ញុំសូមលើកសំណួរមួយទៀត ពាក់ព័ន្ធនឹងបញ្ហាថ្នាក់លើនេះដែរ លោកតែងនិយាយថា លោកតែងមានទំនាក់ទំនងជាមួយថ្នាក់លើ។ រាយការណ៍ ក៏ដូចជាប្រជុំជាមួយថ្នាក់លើជាហូរហែ តើលោកដឹងទេថា ថ្នាក់លើមានដឹងថានៅសហករណ៍ ឬឃុំរបស់លោកហ្នឹងមានការបង្ខិតបង្ខំប្រជាជនឲ្យធ្វើការ ឬក៏មានការបង្អត់អាហារដែរទេបាទ?

**ឆ៖** ពាក់ព័ន្ធនឹងការងារនេះគឺ ថ្នាក់លើគេគ្រាន់តែមានផែនការឲ្យយើង ដំណើរការដូចជាសហករណ៍អីចឹង។ ឯការហូបចុកមាន មានជាក់ស្តែងដូចជា កន្លងមកនៅក្នុងឃុំអីចឹង គេណែនាំឲ្យហូបបបរ ពេលប្រជុំស្រុកគេថា ឲ្យហូបបបរជាទូទៅដោយមានកន្លែងខ្លះខ្វះខាតយើងចែករំលែកគ្នាបាទ។ ហើយអីចឹងក្នុងការហូបបបរនេះ កន្លងមកខ្ញុំអត់អនុវត្តបានតាមការណែនាំរបស់ស្រុកទេ ខ្ញុំជំទាស់ តែខ្ញុំទេ។ ប៉ុន្តែថា ខ្ញុំមិនដែលជំទាស់ក្នុងអង្គប្រជុំទេ ខ្ញុំនិយាយស្ងាត់ៗជាមួយខាងស្រុកហ្នឹង។

ខ្ញុំថា បើចង់ឱ្យហូបបបរនៅកន្លែងខ្ញុំ ទាល់តែដកខ្ញុំចេញពីមេគេ បើឱ្យខ្ញុំនៅធ្វើមេគេ ខ្ញុំដាច់ខាតត្រូវតែហូបបាយ។ ពីព្រោះអី? ពីព្រោះមានមាគ៌ាចំណុចខ្លះ គឺរបស់ថ្នាក់ខាងលើ គឺក្នុងទង់ហ្នឹង ក៏មានចែងពីបញ្ហាហូបបាយដែរបាទ។ ពីព្រោះមានចំណុចមួយ ប៉ុន្តែខ្ញុំមិនចាំ មិនជានៅក្នុងឯកសារណាមួយ។

[០៩:២៨:២២]

ខាងលើបានបញ្ជាក់ថា "នៅកន្លែងណាដែលឱ្យប្រជាជនហូបបបរ ឬមើមឈើ ឱ្យពិនិត្យថ្នាក់ដឹកនាំ។ ទីមួយ តើថ្នាក់ដឹកនាំហ្នឹងមានសមត្ថភាពឬអត់? បើគ្មានសមត្ថភាពទេត្រូវផ្លាស់ប្តូរ តែគ្មានវិធានការទេ ប៉ុន្តែ ប្រយ័ត្នប្រភេទទីពីរដែលជាខ្សែក្បត់ បង្កប់ក្នុងជួរបក្ស ពួកនេះឱ្យប្រជាជនហូបបបរ ឬមើមឈើ ក្នុងបំណងផ្តួលរំលំមាគ៌ារបស់បក្ស"។ ដោយមានគោលការណ៍នេះ បានខ្ញុំនៅកន្លែងណាក៏ខ្ញុំអត់-- ហូបបាយរហូត ពីព្រោះផ្អែកលើថា បើសិនណាជាយើងឱ្យប្រជាជនហូបបបរ ឬមើមឈើ ព្រោះគ្មានចំណុចណាមួយដែលយើងថាមិន-- រកបាយឱ្យប្រជាជនហូបមិនបានទេ ពីព្រោះប្រជាជនសុទ្ធតែអ្នកស្រែ អ្នកចម្ការ បាទ។ អ៊ីចឹងហើយ បានខ្ញុំប៊ានវ៉ា ប៊ានតស៊ូដោយសំអាងហ្នឹង។ អ៊ីចឹងបើចង់ឱ្យមូលដ្ឋានដែលខ្ញុំកាន់កាប់ហ្នឹងហូបបបរ ដកខ្ញុំពីមេចុះបាទ។ បើដកខ្ញុំចេញពីមេ ចង់ហូបអីហូបទៅ។ នេះជាចំណុចមួយដែលខ្ញុំតស៊ូក្នុងដំណាក់កាលនោះបាទ។ ដល់អ៊ីចឹងមេៗដូចអត់ប៊ានថាអីឱ្យខ្ញុំដែរ ពីព្រោះមេភាគច្រើនជាមិត្តភក្តិរបស់ខ្ញុំដែរបាទ។ ប៉ុន្តែក្រោយមក ងាប់អស់ហើយអត់មានសល់ទេ។ ដូចជា មិត្តផាន មិត្តតានី អីហ្នឹង។ អ៊ីចឹងខ្ញុំសូមបញ្ជាក់ជូន ពាក់ព័ន្ធបញ្ហានេះអ៊ីចឹង គេបញ្ជាអ៊ីចឹង។ អូ គេថា បើអ៊ីចឹងវាប៉ះពាល់ដល់មូលដ្ឋានផ្សេងៗទៀត ដែលគេហូបបបរ។

[០៩:៣០:០៣]

អ៊ីចឹងបានថា ខ្ញុំដាច់ខាតអ៊ីចឹង ជាក់ស្តែងខ្ញុំចេញពីវឌ្ឍនៈទៅ អ្នកវឌ្ឍនៈក៏វេទនាដែរ គ្នាហូបបបរ។ បាទ ហើយដល់ខ្ញុំទៅនៅសំបូរ ខ្ញុំហូបបាយនៅសំបូរទៀត។ ដល់ខ្ញុំចេញពីសំបូរទៅ ប-៣ ទៅកន្លែងយុវជន យុវនារី ទៅដំបូងបបរចំហុយ ដល់បបរចំហុយ ក្រោយមកក៏ដាំបាយហូបទៀតទៅ ដោយស្រុកគេផ្តល់អង្ករ។ ព្រោះពេលនុ៎ងគឺ គ្នា៥០០នាក់ជាងទៅ ៤០០នាក់ជាងដំបូង ក្រោយមក ៧០០នាក់ គេផ្តល់អង្ករច្រើនដែរ។ ដល់គេដកកម្លាំងអស់ពីអង្គភាពហ្នឹង នៅសល់១០០ជាង អង្ករនៅសល់គគោក យើងនាំគ្នាហូបបបរទៀតទៅ-- អ្ហូ! ហូបបាយទៀតទៅ។ នេះខ្ញុំសូមជម្រាបអ៊ីចឹងវាមាន មានការណែនាំឱ្យហូបបបរអ៊ីចឹង។ ខ្ញុំសូមអស់យោបល់។

**ស៖** បាទ ខ្ញុំមានសំណួរផ្សេងទៀតពាក់ព័ន្ធនឹងការចាប់ខ្លួន ដែលនៅក្នុងកំណត់ហេតុយក

ចម្លើយរបស់លោក លោកបានបញ្ជាក់ផងដែរថា លោកធ្លាប់បានទទួលសំបុត្រពីថ្នាក់ស្រុក ដើម្បីធ្វើការចាប់ខ្លួនមនុស្សម្នាក់ឈ្មោះ តាឈី។ សំណួររបស់ខ្ញុំចង់សួរថា តើក្រៅពីលោកទទួលសំបុត្រពីថ្នាក់ស្រុក ថាតើលោកធ្លាប់ទទួលសំបុត្រពីថ្នាក់លើណាផ្សេងទៀតទេ ដើម្បីឲ្យមានការចាប់ខ្លួនមនុស្សនោះ បាទ?

[០៩:៣១:៣៧]

**ឆ៖** នៅពេលដែលខ្ញុំទទួលនាទីជាមេឃុំវឌ្ឍនៈក្តី នៅឃុំសំបូរក្តី នៅការដ្ឋានយុវជននារី ប-៣ក្តី គឺបានទទួលនូវសំបុត្រអញ្ជើញតាឈី-- គេមិនដាក់ថាចាប់ខ្លួនទេ គេថាឲ្យអញ្ជើញតាឈីមកកន្លែងសាលាស្រុក កន្លែងស្រុក បាទមកមន្ទីរស្រុក។ អ៊ីចឹងគឺខ្ញុំបានទទួលតែមួយគត់សំបុត្រចាប់ខ្លួនហ្នឹង។ ខ្ញុំសូមអស់មតិ។

**ស៖** កាលពីម្សិលមិញផងដែរ លោកបានឆ្លើយថា គណៈស្រុកសំបូរគឺ តាចែត គាត់មានបញ្ហាសីលធម៌ជាមួយនារី ក្រោយមកគាត់ត្រូវបានគេចាប់ខ្លួន។ សំណួររបស់ខ្ញុំចង់សួរលោកថាតើនៅក្នុងនាមលោកជាមេឃុំ ក៏ដូចជាប្រធានសហករណ៍ នៅពេលនោះតើលោកដែលមានដឹង ឬក៏មានដឹង ឬក៏មានឃើញយុវជនយុវនារីណាដែលមានបញ្ហាខាងផ្នែកសីលធម៌ ខុសសីលធម៌នៅក្នុងភូមិ ឬក៏សហករណ៍របស់លោកទេ?

**ឆ៖** នៅក្នុងសហករណ៍របស់ខ្ញុំនេះគឺពាក់ព័ន្ធនឹងបញ្ហាសីលធម៌ គឺចំពោះយុវជននារី ដូចជាអត់ដែលបានជួបដែរទេ។ ឯដោយឡែកគឺមាន មានកសិករអីខ្លះ ប៉ុន្តែដល់យើងអប់រំណែនាំទៅ ក៏បានស្រួលវិញទៅដែរ អត់មានបញ្ហា ហើយអត់បានចាប់ចងអីទេបាទ។ ព្រោះគិតថា ជាក់ស្តែងខ្ញុំលើកឧទាហរណ៍ម្នាក់នោះរស់នៅដល់រាល់ថ្ងៃទេ គាត់អ្នកជញ្ជូនស្បៀងទៅឲ្យស្រែឆ្ងាយមួយ ដល់គាត់មក ទៅស្នាក់ពាក់កណ្តាលផ្លូវ ដល់គាត់ស្នាក់ញយៗទៅ ទៅត្រូវជាមួយអ្នកនៅដាំបាយនុ៎ងទៅ។ ដល់ថ្នាក់មានបញ្ហារាយការណ៍អីមកអ៊ីចឹងទៅ ដល់សម្រួលគ្នាទៅ អប់រំណែនាំទៅ ក្រោយមកគាត់ក៏បានស្រួលវិញទៅ។ អត់មានចាប់ចងអីទេបាទ។ សូមអស់យោបល់។

[០៩:៣៤:០១]

**ស៖** តើលោកធ្លាប់រៀនវគ្គបណ្តុះបណ្តាល ខាងផ្នែកសីលធម៌នេះទេពីមុនមកនៅក្នុងសម័យនោះ?

**ឆ៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងបញ្ហាសីលធម៌ គឺបានអប់រំណែនាំជាបន្តបន្ទាប់ដែរ។ បាទ ពីព្រោះបញ្ហាសីលធម៌នេះ ជាបញ្ហាមួយដែលអាចប៉ះពាល់ដល់គោលនយោបាយរបស់បក្ស

ហ្នឹង។ អ៊ីចឹងគឺជាវិធានមួយតឹងរ៉ឹង។ បាទ អ្នកដែលមានសីលធម៌ហ្នឹង គឺជាកំហុសដ៏ធ្ងន់ធ្ងរ។ ដូច្នេះ ហើយបានជាទាំងអស់គ្នា ទាំងគេហ្នឹង ទាំងប្រជាពលរដ្ឋហ្នឹងប្រយ័ត្នប្រយែងទាំងអស់គ្នា ពិសេសក្នុងចំណោមយុវវ័យ។ បាទ ពីព្រោះយើងផ្តល់សិទ្ធិឲ្យដែរ មិនមែនថាមិនផ្តល់សិទ្ធិទេ។ បើសិនណាជាចង់បានប្តីប្រពន្ធ គឺឲ្យរាយការណ៍ មកតាមគណៈរបស់គេ។ អ៊ីចឹង ខ្ញុំសូមអស់មតិ។

**ស៖** បាទ ក្នុងឋានៈលោកជាមេឃុំ ក៏ដូចជាប្រធានសហករណ៍ តើនៅសម័យនោះ នៅពេលដែលលោកចង់ធ្វើដំណើរទៅណាមកណា លោកមានធ្វើការសុំច្បាប់ ឬក៏លិខិតអនុញ្ញាតធ្វើដំណើរពីថ្នាក់ណាដែរបាទ?

[០៩:៣៥:៣៧]

**ឆ៖** ក្នុងការធ្វើដំណើរនៅពេលដែល ដូចថា មានការចាំបាច់ បាទ។ មានការចាំបាច់ គឺពិសេស គឺមានពេលដែលតាមដានប្រវត្តិរូប ស្រាវជ្រាវប្រវត្តិរូបយុវវ័យ ដែលចូលទ័ពអី បាទ ឲ្យដឹងថា ក្រុមគ្រួសារទាំងអស់ មានពាក់ព័ន្ធអីខ្លះ ឪពុកម្តាយហ្នឹងគឺ យ៉ាងម៉េច អាហ្នឹងបានយើងអាចធ្វើដំណើរបាន បាទ ហើយដោយមានលិខិតចេញឲ្យរបស់ស្រុក។ ហើយបើសិនណាជា ការងារធម្មតា ដូចជា មិនដែលបានដើរទៅណាមកណាផង ព្រោះវាមមាញឹករវល់រហូត បាទ រវល់រហូត។ ហើយបើសិនណាជាថា នឹកម៉ែឪ ក៏ ដូចខ្ញុំអ៊ីចឹង ស្រុកកំណើតនៅឯស្រុកក្រូចឆ្មារអ៊ីចេះ នឹកម៉ែឪចង់មកលេង ក៏អត់ដឹង អត់ដែលហ៊ានសុំថា អ្អេ! សុំច្បាប់មកលេងម៉ែឪបានបួនប្រាំថ្ងៃអត់ទេ។ បាទ អ៊ីចឹងទៅតាមដំណើរមនោសញ្ចេតនាហ្នឹងគឺ ដាច់ឆ្ងាយដែរ។ បាទ យូរៗទៅធម្មតាអស់។ ខ្ញុំសូមអស់មតិ។

**ស៖** បាទ ចុះចំពោះប្រជាពលរដ្ឋធម្មតាវិញ នៅពេលដែលពួកគាត់ចង់ទៅស្រុកផ្សេង ឬក៏ឃុំផ្សេង តើពួកគាត់មានសិទ្ធិសេរីភាព ក្នុងការដើរហើរ ឬក៏សុំលិខិតអនុញ្ញាតពីថ្នាក់ណាដែរបាទ?

**ឆ៖** នៅពេលនោះ កម្រមានអ្នកដែលសុំច្បាប់ទៅណាមកណាណាស់ បាទ ព្រោះកាលពីមុនកាលពីយើងមុនរំដោះឆ្នាំ៧៣,៧៤ អីអាហ្នឹងមាន មានអ្នកសុំទៅៗម៉ែឪអីខ្លះ ដល់ក្រោយពី៧៥ ហ្នឹងដូចជាគ្មានអ្នកសុំទៅទេ បាទ គឺអ្នកនៅត្រង់ណា គឺនៅត្រង់នុ៎ងហើយបាទ។ ដោយឡែក ដូចជាខ្ញុំនៅការដ្ឋានក្រោយពីខ្ញុំធ្វើមេឃុំ អ៎ ធ្វើប្រធានសហករណ៍ស្រែខឿន ខ្ញុំទៅនៅការដ្ឋាន ប-៣។ ជាមួយយុវជន នារី អាហ្នឹង ខ្ញុំបើកសិទ្ធិឲ្យវិញ អ្នកឆ្ងាយមកលេងផ្ទះបានបីថ្ងៃ អ៎ អ្នកជិត អ្នកឆ្ងាយបានប្រាំថ្ងៃ ព្រោះមិនឆ្ងាយប៉ុន្មាន ព្រោះអ្នកក្នុងស្រុកហ្នឹងដែរ គ្រាន់តែថា អ្នកខ្លះនៅពីការដ្ឋានមកភូមិសណ្តាន់ ទៅឃុំក្បាលដំរីអីវាជិត អាហ្នឹងបីថ្ងៃបាន។ ឯអ្នកនៅសំបូរ អ្នកនៅឯវត្តនៈឯណេះ អ្នកនៅកោះខ្វែរ កោះអី

អ៊ីចឹង អាហ្នឹងប្រាំថ្ងៃ អាហ្នឹងយើងឲ្យសិទ្ធិមក ដោយឲ្យប្រធានកងគេសរសេរសំបុត្របន្ដិចមក ពីព្រោះពេលនោះ តែអត់មានលិខិតនៅសហករណ៍ សហករណ៍ខ្លះអត់ឲ្យបាយគ្នាហូបទេ ដូចគ្នាមកលេងផ្ទះអ៊ីចឹង អត់មានលិខិត អត់ឲ្យបាយហូប។ អ៊ីចឹង បើមានលិខិតទៅ អាហ្នឹងអត់មានបញ្ហាអីទេ។ នេះខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[០៩:៣៩:០៣]

**ស៖** បាទ ខ្ញុំសូមបញ្ជាក់ឡើងវិញ ដូច្នេះ មានន័យថា មុនឆ្នាំ១៩៧៥ បានន័យថា អាចនៅមានសិទ្ធិសេរីភាពខ្លះ ចំពោះប្រជាជនធម្មតា អាចដើរហើរ តែបន្ទាប់១៩៧៥មក បានន័យថា ប្រជាជនមិនមានសិទ្ធិក្នុងការដើរហើរទេ មែនទេបាទ?

**ឆ៖** បាទអ៊ីចឹងហើយបាទ។ ក្រោយពី៧៥ ការដើរហើរហ្នឹងវាមានលក្ខណៈតឹងរ៉ឹង មិនមែនតឹងរ៉ឹងតែប្រជាជនទេ សូម្បីតែថ្នាក់ដឹកនាំហ្នឹង ក៏មានការតឹងរ៉ឹងដែរបាទ។ និយាយរួមផែនការវាស្អេកស្កះទៅអត់ដឹងទៅណាមកណា នៅជួបទាំងការងារទាំងអស់ហ្នឹង។ បាទ ខ្ញុំសូមអស់មតិ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចូលមកប្រធានបទមួយទៀត គឺពាក់ព័ន្ធនឹងរចនាសម្ព័ន្ធស្រុក។ លោកបានបញ្ជាក់ថានៅតំបន់៥០៥ នោះ គឺនៅពេលនោះគឺមានស្រុកចំនួនបី គឺស្រុកសំបូរ ស្រុកស្នួល និងស្រុកក្រចេះ។ ខ្ញុំចង់សួរលោកថា តើលោកដឹងទេនៅក្រោម-- ជាពិសេសពាក់ព័ន្ធនឹងស្រុកសំបូរ ដែលលោកធ្វើការនៅទីនោះ នៅក្នុងឃុំសំបូរដែរ ខ្ញុំចង់សួរថាតើស្រុកសំបូរវិញ តើមានរចនាសម្ព័ន្ធយ៉ាងម៉េច? តើនៅមានមន្ទីរប៉ុន្មានដែរនៅក្រោមឱវាទស្រុកនោះបាទ? មានមន្ទីរអ្វីខ្លះ? លោកចាំទេ លោកដឹងទេបាទ?

[០៩:៤០:៣៨]

**ឆ៖** នៅកន្លែងស្រុក កាលពីជំនាន់នោះគឺមានឃើញ ទីមួយ មានមន្ទីររបស់សម្រាប់ធ្វើការរួមសម្រាប់ប្រជុំ មានសាលមួយសម្រាប់ប្រជុំដោយមានផ្ទះរបស់ថ្នាក់ដឹកនាំស្រុកគេនៅជាមួយគ្នាហ្នឹងមួយកន្លែងបាទ។ ហើយដោយឡែកទៀត គឺមានមន្ទីរពីរដែលដាច់ពីគេទៀត គឺទីមួយ មន្ទីរសេដ្ឋកិច្ចៗនេះគឺមានសម្រាប់ផ្ដល់ភ័ស្ដុភារ សម្លៀកបំពាក់ ឬសម្ភារៈអីដែលគេចែកចាយទៅតាមសហករណ៍ ហ្នឹងទីមួយ។ ហើយនិងទីពីរទៀត មានមន្ទីរសង្គមកិច្ចៗ នេះសម្រាប់ខាងក្រុមពេទ្យបាទ នេះគឺមន្ទីរហ្នឹង។ ឯមន្ទីរសន្ដិសុខនោះគឺជាកន្លែងឃុំឃាំងមនុស្សរបស់ផ្នែកសន្ដិសុខហ្នឹង។ បាទ អ៊ីចឹងគឺមានមន្ទីរបីហ្នឹងសំខាន់។ នេះខ្ញុំសូមអស់មតិ។

[០៩:៤១:៥២]

**លោក វ៉ែន ពៅ៖**

លោកប្រធាន ខ្ញុំបាទសូមអនុញ្ញាតបង្ហាញឯកសារមួយទៀតដែល គឺឯកសារជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែរ គឺ D232/61។ ERN ជាភាសាខ្មែរគឺ 00402522, ERN ជាភាសាអង់គ្លេស 00412191, ERN ជាភាសាបារាំង 434567 បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សំណួរសួរលោកថា៖ "តើនរណាមានតួនាទីរាយការណ៍ទៅមជ្ឈិម?" ចម្លើយរបស់លោកបានឆ្លើយថា៖ "ខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែដឹងថាឃុំបញ្ជូនរបាយការណ៍ទៅស្រុក ហើយស្រុកទៅខេត្តប៉ុណ្ណោះ"។ សំណួររបស់ខ្ញុំចង់សួរថា តើការបញ្ជូនរបាយការណ៍ពីឃុំទៅស្រុក ពីស្រុកទៅខេត្តដែលសំដៅលើតំបន់នោះ ថាតើជារបាយការណ៍បែបណាទៅ? ហើយរបាយការណ៍នេះបញ្ជូនតាមមធ្យោបាយអ្វីខ្លះទៅបាទ?

[០៩:៤៣:៣៧]

**លោក យុន គីម៖**

**ឆ៖** ដូចខ្ញុំបានជម្រាបពីម្សិលមិញហើយថា របាយការណ៍នេះភាគច្រើនគឺ យើងៗជួបជុំគ្នាអង្គុយជួបជុំគ្នា យើងនិយាយៗគេកត់ត្រាខ្លួនគេទេ រៀងខ្លួនបាទ។ គឺយើងប្រជុំប្រចាំសប្តាហ៍អ៊ីចឹង ឃុំណាមានបញ្ហាអី ឃុំណាមានបញ្ហាសន្តិសុខយ៉ាងម៉េច បញ្ហាកសិកម្មយ៉ាងម៉េច សង្គមកិច្ចយ៉ាងម៉េច? លើគ្រប់ផ្នែកហ្នឹង ហើយគេកត់ត្រា។ អ៊ីចឹងឯការបញ្ជូនហ្នឹងគឺផ្អែកទៅលើការកត់ត្រានេះ ស្រុកគេអាចបញ្ជូនតាមរបាយការណ៍នោះទៅខេត្ត។ ឯខេត្តទៅខាងលើទៀត មិនដឹងជាយ៉ាងម៉េច ខ្ញុំក្តាប់អត់បានទេបញ្ហាហ្នឹងបាទ។ សូមអស់មតិ។

**ស៖** ថាតើតាមមធ្យោបាយនៃការបញ្ជូនរបាយការណ៍នេះ អាចមានធ្វើតាមរយៈសារទូរលេខអីដែរឬទេបាទ នៅថ្នាក់ឃុំ ឬក៏ថ្នាក់ស្រុកបាទ? លោកអាចដឹងទេបាទ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថានៅថ្នាក់ឃុំអត់មានស្មីទាំងអស់បាទ។ មានតែ-- ដូចខ្ញុំជម្រាបអ៊ីចឹងត្រូវរាយការណ៍តាមមាត់ទទេយកទៅជូនគេទៅ ឯស្រុកទៅខេត្តខ្ញុំក៏អត់ដឹងគេមានស្មីគេដែរ ប៉ុន្តែដឹងតែ

ថា មាននីរសារទាក់ទងគ្នា សរសេរជាក្រដាសអ៊ីចឹងទៅ នីរសារចុះឡើងពីស្រុកទៅខេត្ត។ ហ្នឹងខ្ញុំសូមអស់មតិ។

**លោក វ៉ែន ពៅ៖**

បាទ លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានឯកសារដដែល គ្រាន់តែខាងក្រោម ដែលជា-- គឺលេខឯកសារដដែល ហើយនិងទំព័រដដែលដែរ។

[០៩:៤៥:២១]

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ក្នុងនោះសំណួរដែលគេសួរថា៖ “នៅពេលដែលលោកនិយាយថា ភ្នំពេញ តើលោកសំដៅលើមន្ទីរ៨៧០ មែនទេ?” ចម្លើយរបស់លោកបានឆ្លើយថា៖ “ប្រហែលមន្ទីរនេះហើយ ប៉ុន្តែខ្ញុំមិនដឹងច្បាស់ពីមន្ទីរនេះទេ។ ប៉ុន្តែនៅពេលនោះប្រហែលជា នួន ជា គឺជាអ្នកទទួលខុសត្រូវខេត្តក្រចេះ ពីព្រោះគាត់ឧស្សាហ៍មកខេត្តក្រចេះ។ ខ្ញុំមិនស្គាល់អ្នកផ្សេងទៀតទេ ខ្ញុំឮតែឈ្មោះ ប៉ុល ពត, អៀង សារី, ខៀវ សំផន ប៉ុន្តែខ្ញុំមិនដែលបានឃើញពួកគាត់ទេ”។ សំណួររបស់ខ្ញុំចង់សួរថា តើលោកមានដែលដឹង ឬក៏ឮគេនិយាយប្រាប់ថា ប៉ុល ពត មានមុខងារជាអ្វី ឬឋានៈជាអ្វីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែរទេបាទ?

**លោក យុន គីម៖**

**ឆ៖** ខ្ញុំធ្លាប់បានឮថា ប៉ុល ពត នេះជាលេខាបក្សកុម្មុយនីស្តកម្ពុជា បាទ។

[០៩:៤៦:២១]

**ស៖** ចុះចំពោះលោក ខៀវ សំផន វិញ តើលោកដឹងថាក្រោយជ័យជម្នះ១៧ មេសា ៧៥ នោះ តើគាត់មានតួនាទីជាអ្វី? ដែលមានគេប្រាប់ ឬក៏មានគេនិយាយថាគាត់មានមុខងារជាអ្វីដែលទេបាទ?

**ឆ៖** លោក ខៀវ សំផន គឺខ្ញុំបានឮដែរ គឺបានឮគេថាគាត់ជា១ ប្រមុខរដ្ឋកម្ពុជា ជាគេហៅស្អីទេកាលហ្នឹង គ្រាន់តែដឹងថាជា-- វាមិនច្បាស់។ ខ្ញុំសូមអស់យោបល់ប៉ុណ្ណឹង។

**ស៖** ចុះចំពោះលោក អៀង សារី វិញ តើលោកមានបានដឹង ឬមានដែលគេនិយាយប្រាប់លោកថា គាត់មានតួនាទី ឬឋានៈជាអ្វីដែរនៅក្នុងសម័យនោះបាទ?

**ឆ៖** ចំពោះ អៀង សារី ខ្ញុំបានដឹងច្បាស់ ព្រោះឮថាគាត់ជារដ្ឋមន្ត្រីការបរទេស បាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលប្រធានបទមួយទៀត ពាក់ព័ន្ធនឹងតំបន់៥០៥។ ខ្ញុំចង់សួរលោក តើលោកមានបានដឹងពីរចនាសម្ព័ន្ធ ឬក៏មន្ទីរផ្សេងៗដែលនៅក្រោមឱវាទនៃតំបន់៥០៥ នេះទេ

បាទ?

**ឆ៖** ពាក់ព័ន្ធនឹងអ្នក-- តំបន់៥០៥ មន្ទីរផ្សេងៗនៅក្នុងតំបន់៥០៥ ពេលនោះខ្ញុំអត់បានច្បាស់លាស់ទេ ខ្ញុំអត់បានក្ដាប់មិនបានដែរ។ ពីព្រោះបើថាមកក្រចេះ មកតែរៀន គេហៅទៅរៀន ទៅកន្លែងរៀនទៅ ចេញពីរៀនមក មកកន្លែងវិញ។ នេះខ្ញុំសូមអស់មតិ។

[០៩:៤៨:២៤]

**ស៖** លោកៗបានបញ្ជាក់ផងដែរថា តំបន់៥០៥នេះជាតំបន់ស្វយ័ត ដែលទទួលបញ្ជាផ្ទាល់ពីថ្នាក់លើ គឺគណៈមជ្ឈិមផ្ទាល់។ ខ្ញុំចង់សួរលោក ថាតើលោកដឹងទេថាហេតុអ្វីបានជាតំបន់៥០៥ នេះមានលក្ខណៈពិសេសយ៉ាងណាទៅ បានគេឲ្យសិទ្ធិទៅជាតំបន់ស្វយ័តនោះ? លោកដឹងទេបាទ? ឬក៏មានអ្នកណាដែលនិយាយប្រាប់យើងពីមូលហេតុអ្វីទេបាទ?

**ឆ៖** បញ្ហាដែលតំបន់៥០៥នេះ ក្លាយទៅជាតំបន់ស្វយ័ត ខ្ញុំគ្រាន់តែបានឮថាទៅជាតំបន់ស្វយ័ត ប៉ុន្តែអត់ដឹងថាមូលហេតុអីបានជាតំបន់នេះទៅជាតំបន់ស្វយ័តទេ។ បាទ ខ្ញុំសូមអស់មតិ។

**ស៖** ខ្ញុំចូលប្រធានបទមួយទៀត ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា។ ខ្ញុំចង់សួរលោកថា លោកចូលចលនាបដិវត្តន៍យូរហើយ តាមបទពិសោធន៍ ក៏ដូចចំណេះដឹង តើលោកមានដឹង ឬក៏យល់អំពីបញ្ហារចនាសម្ព័ន្ធយោធាខ្លះដែរទេបាទ?

[០៩:៤៩:៤៦]

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហារចនាសម្ព័ន្ធយោធា គឺខ្ញុំអត់បានដឹងដែរ ព្រោះខ្ញុំដឹងតែថានៅក្នុងឃុំមានមេឃុំទទួលខុសត្រូវរួម ឯអនុប្រធានឃុំទទួលខុសត្រូវយោធា។ ឯខាងថ្នាក់ស្រុកអី គឺរៀបចំរចនាសម្ព័ន្ធយ៉ាងម៉េច ថ្នាក់ខេត្តរៀបចំយ៉ាងម៉េចនោះ ខ្ញុំអត់បានដឹងបាទ។ ខ្ញុំសូមអស់មតិ។

**ស៖** តើលោកដឹងទេ តំបន់៥០៥នេះ មានយោធាប៉ុន្មានប្រភេទទៅ? មានតំបន់ជាយោធាមជ្ឈិម ឬក៏យោធាតំបន់ផ្ទាល់ឬទេ? មានប៉ុន្មានប្រភេទដែរ លោកដឹងទេបាទ?

**ឆ៖** នៅតំបន់៥០៥នេះ ខ្ញុំគ្រាន់តែដឹងថាមានយោធារបស់តំបន់ៗ ឯយោធាផ្សេងទៀត ខ្ញុំអត់បានដឹង ព្រោះដឹងថាមានៗយោធា ស្អីថាកងពលកងអី ប៉ុន្តែមិនដឹងជាកងពលនោះឈរជើងយ៉ាងម៉េច គ្រាន់តែឃើញថាដូចជានៅនឹងក្រចេះហ្នឹងមានថ្មគ្រែហ្នឹងមានកងពល ដូច៨០១អីចឹង ឈរជើងនៅទីនុំង គឺមិនមែនឈរជើង គ្រាន់តែទីតាំងសម្ភារៈអីគេនៅៗថ្មគ្រែហ្នឹង នៅវត្តហ្នឹង។ អីចឹង គឺគ្រាន់តែដឹងប៉ុណ្ណឹង។ ឯការរៀបចំរចនាសម្ព័ន្ធ ឬក៏មានយោធាយ៉ាងម៉េចៗទៀតនោះ ខ្ញុំអត់បានច្បាស់ទេបាទ។

[០៩:៥១:២៦]

**ស៖** ពាក់ព័ន្ធនឹងយោធានេះផងដែរ តើនៅក្នុងតំបន់៥០៥ នុំង តើលោកដឹងទេ ថាតើយោធាមានសិទ្ធិក្នុងការសម្រេចចាប់មនុស្ស ឬក៏អ្នកណាដែលគេចោទថាជាខ្មាំងដែរទេបាទ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាយោធានៅតំបន់៥០៥ កន្លងមក នេះគឺយោធាអត់មានតួនាទីជាអ្នកចាប់ចងទេ។ ខាងផ្នែកសន្តិសុខទេ ដែលគេអ្នកមានតួនាទីជាអ្នកចាប់ចង។ យោធាមានតួនាទី ដូចថាពេលសភាពការណ៍នៅព្រំដែនអីហ្នឹង គឺនាំគ្នាទៅខាងណោះ ខាងវៃខ្មាំង។ អ៊ីចឹង ខ្ញុំសូមអស់មតិ។

**ស៖** បាទ ខ្ញុំសូមចូលប្រធានបទមួយទៀត ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំនៅក្នុងសម័យនោះ។ ការពីម្សិលមិញផងដែរលោកបានឆ្លើយទៅនឹងសហព្រះរាជអាជ្ញាថា លោកធ្លាប់ជួយរៀបចំនៅពេលដែលយោធា គេស្នើសុំទៅខាងស្រុក ហើយស្រុកបញ្ជូនសំណើសុំរៀបការមកលោក ហើយលោករៀបចំជានារីដើម្បីរៀបការឲ្យ។ ក្នុងនោះក៏ធ្លាប់មានកងពល៩២០ ក៏បានស្នើសុំដែរ។ ខ្ញុំចង់សួរលោកថា ក្រៅពីការស្នើសុំខាងយោធា តើមានខាងយោធាស្នើសុំមកដែលជាយុទ្ធជនពិការរៀបការជាមួយនារីដែលមានដៃជើងល្អដែរទេ នៅក្នុងមូលដ្ឋានឬក៏របស់លោកហ្នឹងបាទ?

[០៩:៥៣:០៨]

**ឆ៖** ដូចខ្ញុំបានជម្រាបពីម្សិលមិញ គឺអង្កាល់ខ្ញុំនៅជាប្រធានអង្គភាពយុវជនយុវនារីនេះ គឺមានការស្នើសុំពីអង្គភាពយោធាតាមរយៈស្រុក សុំនារីដូចជា៣០នាក់អង្កាល់នុំង ប៉ុន្តែបានអត់គ្រប់ទេ ថាយកទៅធ្វើប្រពន្ធយោធា ពេលនោះអត់មានរៀបចំនៅកន្លែងខ្ញុំទេ គ្រាន់តែមាននារីដែលស្ម័គ្រចិត្តទៅគេបញ្ជូនទៅតាមរយៈអ្នកស្រុកទៅ។ អត់មែនថារៀបចំនៅកន្លែងខ្ញុំទេ ហើយក្នុងពេលដែលនារីនោះទៅ ខ្ញុំមិនបានដឹងថាតើទទួលបានគ្រួសារនោះពិការ ឬក៏មិនពិការយ៉ាងម៉េចនោះ អត់បានដែរ ព្រោះមិនមែនរៀបការនៅនឹងកន្លែងការដ្ឋានដែលខ្ញុំនៅទេបាទ។ ខ្ញុំសូមអស់មតិ។

**ស៖** ពាក់ព័ន្ធនឹងការរៀបការនេះដែរ តើលោកមានដឹងទេ ថាមាននារីនៅក្នុងសហករណ៍របស់លោក គាត់មិនព្រម ឬក៏ប្រកែក តើគាត់មានបញ្ហាអីកើតឡើងដែរទេបាទ?

[០៩:៥៤:៣១]

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំអត់ដែលជួបអ្នកដែលថាប្រកែកថាមិនព្រមទទួល ឬព្រមទទួលនោះ អត់ដែលមានជួបបញ្ហាហ្នឹងទេបាទ។ ឧទាហរណ៍ដូចជានារីដែលខាងយោធាស្នើទៅហ្នឹង បើទៅដល់កន្លែងនោះ គឺខ្ញុំក្តាប់អត់បានបាទ។ ឯនៅក្នុងសហករណ៍ក៏ដូចជានៅការដ្ឋានរបស់ខ្ញុំនេះ ក៏អត់ដែល

មានបញ្ហាដែល-- នៅការដ្ឋានមិនបានរៀបការឲ្យយុវជន យុវនារីផង ប៉ុន្តែបើនៅសហករណ៍ បើគេស្នើសុំត្រូវរូវគ្នាគេ អាហ្នឹងគេអត់មានប្រកែកអីទេបាទ។ សូមអស់មតិ។

**ស៖** បាទ ខ្ញុំមានសំណួរមួយទៀតដែរ ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញដល់ពួកជនជាតិខ្មែរអ៊ីស្លាម។ កាលពីម្សិលមិញក៏លោកបានបញ្ជាក់ផងដែរថា នៅស្ទើរគ្រប់សហករណ៍ទាំងអស់មានការបង្ខំឲ្យពួកខ្មែរអ៊ីស្លាមហូបសាច់ជ្រូកនៅសម័យនោះ។ តើលោកដឹងទេ គោលការណ៍ ឬក៏ផែនការនេះតើអ្នកណា អ្នកដាក់បញ្ជាមកឲ្យបង្ខំឲ្យជនជាតិអ៊ីស្លាមហូបសាច់ជ្រូកនៅពេលនោះ?

[០៩:៥៥:៥២]

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាហូបចុកនេះ ព្រោះអត់មានឯកសារណាមួយដែលចែងថា ជនជាតិអ៊ីស្លាមត្រូវតែហូបសាច់ជ្រូក ដូចជនជាតិខ្មែរនៅក្នុងសហករណ៍។ ដូច្នេះ គឺបញ្ហាបង្ខំ ឬក៏ដូចជាមិនឲ្យយកម្ហូបណាក្រៅពីសាច់ជ្រូកនេះឲ្យបងប្អូននេះហូប។ តាមខ្ញុំស្មាន គឺមិន គ្មានអ្នកណាក្រៅពីអ្នកនៅនឹងផ្ទះបាយហ្នឹងទេ តាមមុខព្រួញហ្នឹង ព្រោះបើសិនណាជាមុខព្រួញហ្នឹងមិនកំណត់ឲ្យ គេអាចឲ្យចេញជាដូចជាផ្អក ជាស្អីឲ្យគ្នាហូបហើយ បាទ។ នេះខ្ញុំសូមអស់មតិ។

**ស៖** បាទ ខ្ញុំមានសំណួរពីរទៀតទេ នៅចុងក្រោយនេះ ខ្ញុំសូមសួរ-- សំណួរនេះ គឺពាក់ព័ន្ធនឹង ប-៣។ កាលពីម្សិលមិញផងដែរ លោកបានបញ្ជាក់ថា នៅពេលដែលលោកត្រូវបានគេផ្លាស់ឲ្យទៅធ្វើជាប្រធាននៅការដ្ឋាន ប-៣ នោះ លោកបានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៧៨ មានទឹកជំនន់ធំ។ នៅពេលនោះ គេបានប្រមែប្រមូលយុទ្ធជនយុទ្ធនារីទាំងអស់ ដើម្បីទៅដោះសារបញ្ហាទឹកធំនោះ ហើយលោកនៅសេសសល់តែអ្នកជំងឺប្រហែល១០០នាក់ទេនៅក្នុងការដ្ឋាន។ ហើយនៅពេលនោះ លោកបានតវ៉ាថាលោកខ្វះកម្លាំង ភ្ជួររានដីតាមផែនការ តើលោកទទួលផែនការនេះពីណាមក ហើយផែននោះនិយាយពីអ្វីខ្លះទៅបាទ?

[០៩:៥៧:៥១]

**ឆ៖** ដូចខ្ញុំបានជម្រាបពីម្សិលហើយថា នៅថ្ងៃទី១១ ខែ៦ ឆ្នាំ១៩៧៨ ថ្នាក់ស្រុកនេះឲ្យខ្ញុំទៅទទួលការងារនៅការដ្ឋានជំនួសឈ្មោះ សារិន ដែលឃោធានៅទីនោះមុនខ្ញុំ។ នៅពេលនោះ គេឲ្យខ្ញុំរានដី ១០០ហិកតា។ គឺស្រុកហ្នឹង គណៈស្រុកហ្នឹង បងឯងទៅ ទៅរានដីឲ្យបាន១០០ហិកតា ពីព្រោះកម្លាំងមានដល់៤៥០នាក់ ចបមានគ្រប់ដៃ កាំបិតមាន១០ ពូថៅមាន១០ ដូចខ្ញុំជម្រាបម្សិលអីចឹង។ បាទ ដល់អីចឹង ខ្ញុំគិតថា គ្រោះថ្នាក់ដល់ខ្ញុំហើយ ព្រោះផែនការ តែមិនគ្រប់ ខ្លាចមានបញ្ហា។ អីចឹងខ្ញុំដេកគិតទៅ

គ្រាន់តែឃើញអត់មានកាំបិតពូថៅ ខ្ញុំសម្រេចចិត្តមកស្រុកវិញ ខ្ញុំសុំជាងដែក។ បាទ ខ្ញុំអត់សុំកាំបិតពូថៅគេទេ សុំជាងដែក។ បីថ្ងៃគេឲ្យជាងដែកទៅដល់មែន។ បាទ កាំបិតពូថៅ ខ្ញុំអត់ខ្វះទេ។ ខ្ញុំគិតមើលទៀត រានដីបើយកកម្លាំងមនុស្សទៅរាន វាបាន ប៉ុន្តែមិនងាយទេ។ បានខ្ញុំយកកម្លាំងដំរីទៅទៀត។ បាទដំរីនេះ ខ្ញុំលើកឲ្យតែបងប្អូនយើងលើកភ្លីទៅ កាប់ព្រៃហ្នឹងទៅ ដុតទៅ ហើយយើងលើកភ្លីទៅបងប្អូនយើងគាស់ គាស់ឈើតូចៗល្មមមួយចំហៀងៗទៅ ដល់បានដំរីមក ឲ្យវាផ្ដួល វាជាន់ផ្ដួលទៅកាត់ជាពីរ អាណាធំ កាត់ជាពីរ ជាបីទៅ អូសឡើងទួលអស់ទៅ។ បាទ ខ្ញុំរានរបៀបនេះ។ ដល់ខ្ញុំរានបានអ៊ីចឹង ខ្ញុំគិតថា ខ្ញុំអាចអត់គ្រោះថ្នាក់ទេ។ រួចដល់នៅទន្លេមេគង្គឆ្នាំ៧៨នោះ ទឹកធំណាស់ បាទលិចលង់គ្មានសល់ទេ ម៉ាប្រវត្តិសាស្ត្រដែលខ្ញុំកើតមកដល់អាយុប៉ុណ្ណេះ ទើបតែឃើញម្ដងហ្នឹងធំជាងគេ។

[០៩:៥៩:៥០]

អ៊ីចឹងដល់ពេលទឹកស្រកទៅនេះ សហករណ៍គេត្រូវការកម្លាំង ពីព្រោះយុទ្ធជននារីប្រមូលទៅអស់ហើយ។ ដូច្នេះ ខ្ញុំក៏បានរត់មកស្រុក មកជម្រាបគណៈស្រុកហ្នឹងថា បើសិនណាជាដកកម្លាំងមកជួយសហករណ៍អស់ ខ្ញុំពិតជាគ្រោះថ្នាក់ហើយ ពីព្រោះផែនការមិនបានសម្រេចបានទេ។ ដល់ខាងស្រុកនេះ គេថាអត់អីទេបង ផែនការបងឯងធ្វើទៅ ធ្វើបានប៉ុន្មានប៉ុនហ្នុងហើយ ឲ្យតែខ្ញុំសូមកម្លាំងប៉ុន្មានឲ្យខ្ញុំមក។ ដូច្នេះ ខ្ញុំក៏រីករាយចិត្តដែរ ពីព្រោះផែនការខ្ញុំពិតជាជ័យជម្នះហើយ ពីព្រោះខ្ញុំដក-- គេដកកម្លាំងអស់ហើយ ឲ្យខ្ញុំធ្វើបាន ១០០ហិកតា មិនបានទេ។ ប៉ុន្តែគ្រាន់តែបាន ៤០ហិកតាហ្នឹង ខ្ញុំថាវាមិនមែនធម្មតាទៅហើយ ហើយបើកុំតែខ្ញុំមានគំនិតយកដំរីទៅជួយរានហ្នឹង ប្រហែលជាមិនបាន១០ហិកតាផង។ នេះខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១០:០១:០៦]

**លោក វ៉ែន ពៅ៖**

បាទ នេះជាសំណួរចុងក្រោយរបស់ខ្ញុំលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតអានឯកសារ ដាក់ឯកសារនេះបង្ហាញ គឺឯកសារដែលមានលេខ D232/61 ដែលមាន ERNជាភាសាខ្មែរគឺ 00402524, ជាភាសាអង់គ្លេស 00412193, ជាភាសាបារាំង 00434568។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សំណួរដែលសួរលោកនៅពេលនោះ គឺថា “តើលោកចាំទេ នៅពេលនោះ នួន ជា និយាយអ្វីខ្លះ?” លោកឆ្លើយថា “សារៈសំខាន់របស់ នួន ជា គឺថា កន្លែងដែលមានការលំបាកគឺត្រូវធ្វើស្រែប្រវាស់ដៃ ហើយកន្លែងដែលមិនសូវលំបាកត្រូវធ្វើសហករណ៍កម្រិតទាប ហើយកន្លែងដែលងាយស្រួលធ្វើសហករណ៍កម្រិតខ្ពស់។ ការហូបរួមមិនទាន់អនុញ្ញាតឲ្យធ្វើទេ។” សំណួររបស់ខ្ញុំសួរថា តើនៅក្នុងតំបន់របស់លោកទាំងមូលនោះ ចាប់ផ្ដើមឲ្យហូបរួមពីពេលណាមកបាទ?

[១០:០២:២១]

**លោក យុន គីម៖**

**ឆ៖** ដូចខ្ញុំបានជម្រាបពីម្សិលមិញដែរ នៅពេលដែលលោក នួន ជា ចុះទៅណែនាំពីបញ្ហាធ្វើសហករណ៍ ធ្វើសហករណ៍កម្រិតទាប កម្រិតខ្ពស់ អំពីក្រុមប្រវាស់ដៃ ទៅតាមសភាពជាក់ស្ដែងនៅមូលដ្ឋាននីមួយៗ ឧបមាគេមានជីវភាពធូរធារអីយើងណែនាំ គេឲ្យធ្វើសហករណ៍គេដូចថា--

**ប្រធានអង្គជំនុំ៖**

សាក្សីចម្លើយនេះ ដដែលទេ។ សំណួរមិនសួរអ៊ីចឹងទេ។ សួរថា តំបន់ក្រចេះ ឬតំបន់៥០៥ តាមលោកដឹងហ្នឹង តើការកំណត់ឲ្យហូបរួមហ្នឹងចាប់ផ្ដើមពីពេលណាមក? សំណួរតែប៉ុណ្ណឹងទេ។ ចំណែកឯចម្លើយរបស់លោកអំមិញហ្នឹង គឺលោកបានឆ្លើយរួចហើយទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានសួរលោកកាលពីម្សិលមិញ។ លោកឆ្លើយតបឲ្យចំកម្រិតដែលសំណួរសួរគោលបំណងនៃការសួរបានហើយ។

[១០:០៣:២៥]

**លោក យុន គីម៖**

**ឆ៖** ការដែលហូបរួមនៅក្នុងស្រុកសំបូរ ឯតំបន់៥០៥ ខ្ញុំអត់បានដឹងទេ ប៉ុន្តែដោយឡែកស្រុកសំបូរ គឺនៅឆ្នាំ១៩៧៣ ដែរ ក្រោយពីចេញពីសាលាដែលលោក នួន ជា បានណែនាំរួចទៅ លោក ចែត នោះ បញ្ជាឲ្យធ្វើអ៊ីចឹងបណ្ដោយ។ បញ្ជាឲ្យធ្វើសហគមន៍ហូបរួមអ៊ីចឹងបាទ។ អ៊ីចឹងអត់មានអ្នកណាមួយប៉ានប្រឆាំងទេ ពីព្រោះគាត់ថា បើអ្នកណាមិនប៉ាននិយាយទេ ទៅចាត់តាំងទៅៗឲ្យធ្វើចាំគាត់ទៅឃោសនា។ អ៊ីចឹងបញ្ជារបស់ ចែត។ បាទ ខ្ញុំសូមអស់មតិ។

**លោក វ៉ែន ពៅ៖**

បាទ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ហើយសូមអរគុណលោកសាក្សី ហើយជាបន្តខ្ញុំសូមឲ្យសហភាតារបស់ខ្ញុំមានសំណួរបន្ថែមអាចសួរបាន។

សូមអរគុណលោកប្រធាន។

[១០:០៤:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម ជាទីគោរព។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរសួរបន្តិចបន្តួចទេ ពីព្រោះថាលោកបានពន្យល់ច្រើនហើយ ក៏ប៉ុន្តែឥឡូវនេះខ្ញុំមានបន្តិចទៀត ដើម្បីសូមឲ្យមានការបំភ្លឺទាក់ទងទៅនឹងចំណុចមួយចំនួន។

សំណួរទៅមួយរបស់ខ្ញុំគឺថា ទាក់ទងទៅនឹងលក្ខខណ្ឌជីវភាពនៅក្នុងសហករណ៍ លោកបានពន្យល់ថា លោកបានទទួលសេចក្ដីណែនាំ ថានៅក្នុងសហករណ៍របស់លោក លោកបានខំព្យាយាមធ្វើយ៉ាងណាដើម្បីឲ្យមនុស្សមានអាហារបរិភោគគ្រប់គ្រាន់ ហើយលោកក៏ខំធ្វើយ៉ាងណាឲ្យ-- ធ្វើកុំឲ្យស្ងួតមានភាពតឹងរ៉ឹង។ ខ្ញុំចង់ដឹងថា តើនៅពេលដែលលោកប្រជុំជាមួយនឹងប្រធានសហករណ៍ផ្សេងទៀត តើលោកបានឮគេនិយាយអំពីលក្ខខណ្ឌជីវភាពនៅសហករណ៍ផ្សេងទៀត ដែរឬទេ? ឧទាហរណ៍ថា បើសិនជាលោកបានឮនិយាយអំពីទីកន្លែងផ្សេង ដែលមានមនុស្ស ពុំមាន-- ចង់ដឹងថា តើលោកបានឮទេនៅកន្លែងផ្សេងទៀត ថាមានប្រជាជនមិនមានអាហារហូបគ្រប់គ្រាន់។

[១០:០៦:០៣]

**លោក យុន គីម៖**

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាជីវភាព នៅក្នុងស្រុកសំបូរ ឯស្រុកផ្សេងទៀតខ្ញុំអត់ក្ដាប់បានទេ។ ប៉ុន្តែដោយឡែកនៅស្រុកសំបូរគឺរបបជីវភាពរស់នៅ របបប្រជាពលរដ្ឋគឺគ្រាន់តែថា ឃុំភាគច្រើនគេ ៗហូបបបរ បាទ។ ប៉ុន្តែបបរនេះក៏មិនមែនបបររាវអីនេះដែរ បបរសមរម្យ ហើយក្រៅពីបបរហ្នឹង ក៏គេមានដំណាំរួមផ្សំ ដូចជាដំឡូង ដូចជាស្ពីហ្នឹងគឺមិនចោទជាបញ្ហាប៉ុន្មានទេ។ ដោយឡែកដូចខ្ញុំជម្រាបអ៊ីចឹងនៅ

កន្លែងខ្ញុំគ្រប់គ្រង សូម្បីតែនៅវឌ្ឍនៈក៏ខ្ញុំហូបបាយ នៅសំបូរក៏ខ្ញុំហូបបាយ។ នៅកន្លែងត្រង់ណាដែលខ្ញុំគ្រប់គ្រងគឺខ្ញុំតស៊ូហូបបាយរហូត បាទ។ អ៊ីចឹងខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** បាទ លោកសាក្សី សំណួរខ្ញុំមិនមែនអ៊ីចឹងទេ គឺថាខ្ញុំចង់ដឹងថា តើលោកធ្លាប់បានឮគេនិយាយនៅពេលដែលលោកប្រជុំជាមួយប្រធានសហករណ៍ផ្សេងទៀត ឬក៏មេឃុំផ្សេងទៀត តើលោកបានឮនិយាយថា នៅឃុំផ្សេងពីឃុំលោកនោះ នៅទីនោះមានបញ្ហាចំណីអាហារ ដែលមានគេពុំមានបរិភោគគ្រប់គ្រាន់ គឺថាមិនមែនចង់និយាយនៅឃុំលោកទេ និយាយឃុំផ្សេងទៀត ពីឃុំផ្សេងទៀត។

[១០:០៧:៤១]

**ឆ៖** បាទនៅឃុំផ្សេងទៀតហ្នឹង ពេលប្រជុំដូចជាមិនដែលឮសួរគេនិយាយពីការហូបចុកទេ។ ប៉ុន្តែគ្រាន់តែដឹងថា នៅតាមសហករណ៍ផ្សេងហ្នឹងគេហូបបបរ។ ហើយខ្ញុំសូមអស់មតិ។

**ស៖** តើលោកធ្លាប់បានឮគេនិយាយអំពីការងារ លក្ខខណ្ឌការងារដ៏លំបាកនៅក្នុងសហករណ៍ផ្សេងទៀត ក្រៅពីសហករណ៍លោក នៅក្នុងពេលកិច្ចប្រជុំជាមួយនឹងប្រធានសហករណ៍ផ្សេងទៀត ឬក៏នៅក្នុងរបាយការណ៍ផ្សេងៗនោះ?

**ឆ៖** ខ្ញុំធ្លាប់បានឮដែរ ជាក់ស្តែងនៅឃុំវឌ្ឍនៈ។ នៅឃុំវឌ្ឍនៈក្រោយដែលខ្ញុំចេញទៅហ្នឹង ខ្ញុំទៅលេងម្តងៗ បងប្អូនប្រាប់ថា គណៈមុខព្រួញរបស់គេហ្នឹងតឹងរ៉ឹងណាស់ ម៉ោងបីកន្លះ ម៉ោងបួនហ្នឹង វ៉ៃអាគាំងឲ្យទៅ ទៅដល់ស្រែ រួចទៅកុមារអីដេកតាមភ្លឺស្រែហ្នឹងរកេតរកូត។ អ៊ីចឹងឃើញថា បញ្ហាដែលចង់យកមុខយកមាត់របស់មុខព្រួញហ្នឹង គឺមាន មានដោយកន្លែងអ៊ីចឹង។ បាទ នេះខ្ញុំគ្រាន់តែលើកឧទាហរណ៍មួយជូន បាទ។ សូមអស់មតិ។

[១០:០៩:២៤]

**ស៖** តើលោកធ្លាប់ឮនិយាយអំពីបុគ្គលដែលធ្លាក់ខ្លួនឈឺ ដោយខ្វះអាហារ ឬក៏ធ្វើការធ្ងន់ធ្ងរហួសពេក ឬក៏អ្នកដែលស្លាប់ដោយខ្វះអាហារ ឬក៏ដោយការធ្វើការធ្ងន់ធ្ងរពេក ឬក៏ដោយសារមូលហេតុទាំងពីរនេះ តើលោកធ្លាប់ឮទេ?

**ឆ៖** ពាក់ព័ន្ធនឹងសុខភាពរបស់ប្រជាពលរដ្ឋចោទជាបញ្ហាជីវភាពនេះ នៅកន្លែងក្នុងស្រុកសំបូរនេះ មិនដែលជួបបញ្ហា មិនដែលឮថា ធ្លាក់ខ្លួនឈឺដោយសារជីវភាពទេ។ ប៉ុន្តែឃើញនៅនឹងពេទ្យមនុស្សច្រើន ភាគច្រើនដោយមានរោគផ្សេងៗ ពិសេសជំងឺគ្រុនចាញ់ បាទ ជំងឺគ្រុនចាញ់ គឺឈឺច្រើននៅដេកក្នុងមន្ទីរពេទ្យហ្នឹង។ ខ្ញុំក៏ធ្លាប់បានទៅដេកនៅនឹងមន្ទីរពេទ្យហ្នឹងដែរ ដោយជំងឺគ្រុនចាញ់ ឯឆ្នាំ

សង្កូវទៀតសោត មិនសូវសម្បូរទេ មានកម្រិត។ បាទ សូមអស់មតិ។

[១០:១០:៤៦]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកសាក្សី។ មុននឹងចូលទៅប្រធានបទមួយទៀត ខ្ញុំសូមធ្វើដូចសហព្រះរាជអាជ្ញា ហើយនិងសូមជូនដំណឹងទៅអង្គជំនុំជម្រះ និងភាគីថា យើងមានឯកសារមួយគឺថា D22/517 ដែលជាចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលរស់នៅក្នុងកន្លែងសាក្សីរស់នៅពីមុន ហើយសង្ឃឹមថា យើងផ្តល់ព័ត៌មានបន្ថែម។ ខ្ញុំមិនចង់អានសម្រង់នោះទេ ខ្ញុំគ្រាន់តែផ្តល់ឯកសារ ហើយនិងយោងឯកសារនេះ ដូចដែលសហព្រះរាជអាជ្ញា បានធ្វើកន្លងមកហើយនោះដែរ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ខ្ញុំចង់សួរ ចោទសំណួរលោកមួយទៀត ទាក់ទងប្រធានបទថ្មី។ លោកបាននិយាយនៅក្នុងចម្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេតថា លោកបានដឹងអំពីការចាប់ខ្លួនមនុស្សជាច្រើន គឺកម្មាភិបាលជាដើម។ ហើយលោកក៏បានពន្យល់ផងដែរ អំពីរបៀបចាប់ខ្លួននោះ គឺថា គេកោះហៅ លោកបានសង្កត់ធ្ងន់លើចំណុចនេះ គឺថា គេកោះហៅមនុស្សនោះទៅចូលប្រជុំ ហើយគេចាប់ខ្លួនគាត់នៅពេលប្រជុំ។ តើរវាងលោកហ្នឹង-- គ្នាលោកហ្នឹង គឺថាតើលោកធ្លាប់និយាយ អំពីរបៀបចាប់ខ្លួនដែរឬទេ? តើហើយលោកធ្លាប់និយាយអ្វីខ្លះ អំពីការចាប់ខ្លួន ឬក៏របៀបការចាប់ខ្លួននេះ? តើលោកធ្លាប់ពិភាក្សាគ្នាអំពីបញ្ហានេះទេ?

[១០:១២:២៥]

**លោក យុន គីម៖**

**ឆ៖** ពាក់ព័ន្ធនឹងការចាប់ខ្លួននេះ ខ្ញុំមិនដែលបានពិគ្រោះយោបល់គ្នា ពីព្រោះដូចជាមិត្តភក្តិចេះតែបាត់បន្តបន្ទាប់អ៊ីចឹង អត់ដែលបានជួបជុំគ្នា និយាយជាសម្ងាត់ថា អ្ហឺ! សភាពការណ៍វាអ៊ីចឹង តើទៅថ្ងៃមុន ថ្ងៃនេះ គេចាប់មិត្តយើងនេះ ថ្ងៃក្រោយយើងពិតជាចៀសមិនរួចហើយ។ អត់ដែលបានជួបគ្នាពិភាក្សាគ្នារកវិធីណា ដើម្បីដោះស្រាយទេបាទ។ ខ្ញុំសូមអស់មតិ។

**ស៖** ហេតុអីក៏លោកមិនដែលនិយាយ អំពីបញ្ហានេះជាមួយគ្នាលោក?

**ឆ៖** ពីព្រោះទីមួយ យើងបារម្ភដែរ ដូចជា ឈ្មោះ “ក” ដែលត្រូវចាប់ទៅ រួចយើងមកបញ្ជាឈ្មោះនេះមកៗនិយាយ មកវែកញែកទៅ យើងអត់ទុកចិត្តគ្នាយើងទៀត ព្រោះខ្លាចថា ស្រាប់ដល់យើង

និយាយទៅ ស្រាប់មានគេទៅរាយការណ៍ឯណាទៀត ថាយើងចេះវិភាគបញ្ហា ចេះស្អីអ៊ីចឹងទៅ នាំឲ្យគ្រោះថ្នាក់ដល់ខ្លួនបាទ។ ដូច្នេះ ហើយបានសំងំតែរៀងខ្លួន ហើយម្នាក់ៗ ដើម្បីរស់ហ្នឹង គ្រាន់តែមានគំនិតគិតថា ខ្លួនឯងហ្នឹងត្រូវធ្វើយ៉ាងម៉េច ដើម្បីឲ្យរស់បាទ។ នេះ ខ្ញុំសូមអស់មតិ។

[១០:១៤:១៥]

**ស៖** សូមអរគុណលោកសាក្សី ដែលបានពន្យល់មកខ្ញុំ។ លោកបាននិយាយផងដែរថា ថ្នាក់ស្រុកក៏បានឲ្យលោកបែងចែកមនុស្សជាបីប្រភេទ ហើយគឺថា ប្រភេទទីបី គឺថា ប្រភេទប្រជាជនថ្មី។ លោកបាននិយាយថា លោកមិនបានធ្វើការបែងចែកមនុស្សយ៉ាងដូច្នេះទេ។ តើនៅពេលដែលពេលគេពន្យល់ប្រាប់លោកអំពីការបែងចែកមនុស្សជាបីប្រភេទនេះ តើគេបានពន្យល់លោកដែរឬទេ អំពីរបៀបឬក៏តើវិធីណា ដែលនៅ-- យើងធ្វើយ៉ាងម៉េចក្នុងជីវិតប្រចាំថ្ងៃនោះ ក្នុង-- ដូចថា បែងចែកចំណីអាហារឬក៏ការងារអីជាដើមនោះ បែងចែកឲ្យគេយ៉ាងម៉េច ទាក់ទងនឹងប្រភេទមនុស្សផ្សេងៗនេះ?

**ឆ៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ គឺការហូបចុក គឺអត់មានបែងចែកថា អ្នកដែលសមាជិកពេញសិទ្ធិហូបអ៊ីចេះ អ្នកត្រៀមហូបអ៊ីចុះ អ្នកផ្ញើហូបអ៊ីចេះទេ បាទ អត់មានបែងចែកអ៊ីចឹងទេ។ គេឲ្យបែងចែកមិនដឹងជាន័យយ៉ាងម៉េចទេ គ្រាន់តែថាឲ្យបែងចែកមានអ្នកពេញសិទ្ធិ បានន័យថាប្រជាជនចាស់ដែលរស់នៅក្នុងមូលដ្ឋាន។ ឯប្រជាជនត្រៀម គឺអ្នកដែលចាស់ខ្លះ ដែលមានលក្ខណៈអីដូចថាប្រឆាំងនឹងបដិវត្តន៍ ដូចថាមិនពេញចិត្ត ការងារមិនសូវសកម្មអីហ្នឹង គេឲ្យត្រៀម។ ហើយមួយទៀតផ្ញើ គឺអ្នកថ្មីដែលទើបនឹងទៅ។ បាទ គេកំណត់អ៊ីចឹង។ ប៉ុន្តែដូចខ្ញុំជម្រាបអ៊ីចឹង មូលដ្ឋានខ្ញុំមានការបែងចែកដូចគ្នា ប៉ុន្តែអត់មានរាយការណ៍ទៅឲ្យគេខាងលើទេ នៅក្នុងតែសៀវភៅ ហើយមិនប្រកាសជាទូទៅទេ។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១០:១៦:២៧]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមចោទសំណួរមួយទាក់ទងទៅនឹងការរៀបការ ហើយនិងរបៀបរៀបការ។ លោកបានពន្យល់ថា នៅក្នុងជួរកងទ័ពការរៀបការធ្វើឡើងដោយក្រោមបង្គាប់មេ ហើយលោកនិយាយថា នៅពេលមួយនោះលោកបានទទួលសំណើពីស្រុក ឲ្យសូមស្នើសុំនារី៣០នាក់ ហើយលោកបាននិយាយថា នារីទាំងអស់នោះទទួលលេខ ហើយបុរសៗនោះក៏មានលេខដែរ ហើយគេរៀបការលេខដូចគ្នា។ តើនៅពេលណាមួយនោះ គេមានដែលពន្យល់ពីមូលហេតុដែលត្រូវរៀបការតាមរបៀបហ្នឹងទេ គឺថាដោយឲ្យលេខទៅសាមីជនមួយៗនោះ? ហើយគេមានពន្យល់មូលហេតុនេះទេ? គេ

មានប្រាប់លោកទេថា ចាប់ពីពេលហ្នឹងទៅរៀបការរបៀបហ្នឹងដែរឬទេ? ពីព្រោះថាតាំងពីណាពីណីមកនោះ គឺគេរៀបការវាលក្ខណៈឯកជនម្នាក់ៗ ហើយមានសេរីភាព។

**ផ៖** ពាក់ព័ន្ធនឹងយុវនារីដែលស្នើ ខាងយោធាស្នើពីការដ្ឋានខ្ញុំនេះ ការរៀបការខ្ញុំអត់បានដឹងទេ។ ប៉ុន្តែគ្រាន់តែខ្ញុំធ្លាប់ទៅចូលរួម នៅក្នុងការរៀបការនៅឃុំមួយជាប់នឹងឃុំខ្ញុំហ្នឹង ខាងស្រុកព្រៃកប្រសប់ គេអញ្ជើញទៅចូលរួមរៀបការ អាហ្នឹងឃើញគេមានដាក់លេខ គេច្រើន ថ្ងៃនុំងប្រហែលជា១០គូយ៉ាង។ បាទ គេមានដាក់លេខ១ ដឹងថាគូនឹងលេខ១ លេខ២ គូនឹងលេខ២។ ឯពាក់ព័ន្ធនឹងការដែលគេចាប់បង្ខំ ឬក៏គងកភាពទទួលយក-- សុខចិត្តដោយស្ម័គ្រនោះ ខ្ញុំក៏អត់បានដឹងដែរ។ ប៉ុន្តែគ្រាន់តែដឹងថា ពេលដែលគេហៅទៅរួម ទៅចូលរួមនឹងគេទៅ ព្រោះឃុំជាប់គ្នាអង្កាល់ហ្នឹង។ អាហ្នឹងគេរៀបការជាច្រើនគូ អាហ្នឹងគេដាក់លេខ។ នេះខ្ញុំសូមអស់មតិ។

[១០:១៨:៤៥]

**ស៖** សូមអរគុណ។ ក៏ប៉ុន្តែដើម្បីបញ្ជាក់បំភ្លឺ ខ្ញុំយល់ឃើញថារបៀបការនេះខុសពីរបៀបការដែលលោកបាន-- ដែលៗរបៀបរៀបការមុនរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយខ្ញុំចង់ឲ្យលោកពន្យល់ថាហេតុអ្វីបានជាចាប់ពីក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង ក្នុងរបបហ្នឹងគេរៀបការតាមរបៀបហ្នឹងដោយដាក់ឲ្យលេខទៅសាមីជនមួយៗហ្នឹង?

**ផ៖** ខ្ញុំគិតថា ការរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ គឺគេឲ្យមានដាក់លេខឲ្យច្រើនគូអ៊ីចឹង ក្នុងគោលបំណងដែលគេមិនឲ្យខាតពេលវេលាផង ខាតរបស់របរច្រើនផង។ ឧទាហរណ៍ថា ការស៊ីចុកអីអ៊ីចឹង។ អានេះគ្រាន់តែជាការស្មានរបស់ខ្ញុំទេ ព្រោះខ្ញុំអត់ដែលបានរៀបការច្រើនគូដូចគេអ៊ីចឹង។ ខ្ញុំធ្លាប់រៀបការជូននៅសហករណ៍ដែរ បាទៗរៀបការត្រឹមអស់ហើយពីរគូ មានម្តងមួយគូ ម្តងនោះពីរគូ មានអ៊ីចឹង។ ប៉ុន្តែពីរគូហ្នឹងខាតបាទអស់គោមួយ អស់ជ្រូកមួយ គឺខាតច្រើនដែរ។ នេះខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១០:២០:២៤]

**ស៖** បាទ សូមអរគុណលោកសាក្សី។ ឥឡូវជាបញ្ចប់ ខ្ញុំសូមចូលទៅប្រធានបទថ្មីមួយទៀត ហើយលោកបាននិយាយថា លោកបានទទួលការណែនាំ ឬទទួលរបាយការណ៍ ហើយលោកបាននិយាយដ៏លម្អិតអំពីឋានានុក្រម ហើយពីរបីនាទីមុននេះលោកបាននិយាយអំពីមន្ទីរ អំពីមជ្ឈិមបក្ស ហើយលោកនិយាយអំពី នួន ជា នៅក្នុងការបកប្រែជាភាសាបារាំងគឺថា គាត់មានអំណាចកំពូល ព្រោះ

ថាគាត់នៅក្នុងមជ្ឈិម។ តើពាក្យថា "អំណាចកំពូល" នេះមានន័យយ៉ាងម៉េចដែរ លោកចង់-- មានន័យយ៉ាងម៉េចដែរ ពេលលោកប្រើពាក្យ "អំណាចកំពូល" នេះ?

**ឆ៖** ពាក្យថា "អំណាចកំពូល" នេះ បានន័យថាជាថ្នាក់លើបំផុតហើយបាទ។ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១០:២១:៤១]

**ស៖** តើ-- ចំពោះលោកនោះ តើអំណាចកំពូលហ្នឹងមានន័យយ៉ាងម៉េច តាមបទពិសោធន៍របស់លោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមក្រាបថ្វាយបង្គំព្រះតេជគុណ ព្រះសង្ឃគ្រប់អង្គ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សួស្តីសហព្រះរាជអាជ្ញា សហភាគីទាំងអស់។ សាក្សីបានឆ្លើយថា៖ "មានអំណាចកំពូល ជាអ្នកនៅលើបំផុត" សំណួរថែមទៀតឲ្យឆ្លើយ។ ខ្ញុំគិតថាឲ្យឆ្លើយថាមានន័យយ៉ាងម៉េច? ឲ្យសាក្សីពន្យល់ន័យដែលគាត់បង្ហាញផ្ទាល់ខ្លួន។ ខ្ញុំយល់ថានេះជាសំណួរដែលឲ្យសាក្សីធ្វើសេចក្តីសន្និដ្ឋាន និងឧបមាណវិធីហើយ។ ខ្ញុំសូមជំទាស់។ សូមអរគុណ។

[១០:២២:៤២]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីការពារក្តីមានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយនេះទេ! សាក្សីមិនអាចឆ្លើយតបទៅនឹងសំណួរឯណា ដែលសូមឲ្យសាក្សីផ្តល់នូវគំនិតអត្តនោម័តិរបស់សាក្សីទៅនឹងបញ្ហាទាំងឡាយដែលកើតមានទេ។ សំណួរដែលសួរមកសាក្សីគឺសួរតែសាក្សីបានឃើញ បានដឹង បានឮ បានចងចាំ មានបទពិសោធន៍ ធ្លាប់ជួបប្រទះ ឬក៏បានធ្វើការសង្កេតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬព្រឹត្តិហេតុទាំងឡាយដែលពាក់ព័ន្ធទៅនឹងការតាំងសំណួរប៉ុណ្ណោះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគោរពសេចក្តីសម្រេចរបស់លោក ខ្ញុំគ្រាន់តែចង់និយាយថាដើម្បីជាប្រយោជន៍ប្រតិចារឹក។ ខ្ញុំគិតថា ដោយគាត់មាន-- សាក្សីមានឋានៈនៅក្នុងរបបនោះ អ៊ីចឹងគាត់អាចពន្យល់

ពាក្យនេះថា "អំណាចកំពូល" នោះបាន មិនមែន-- នេះជាខ្លឹមសារបច្ចេកទេស មិនមែនជាការសន្មត របស់គាត់ទេ។ ហើយខ្ញុំសូមបញ្ចប់ការចោទសំណួរទៅសាក្សីនៅត្រឹមនេះ។ ហើយលោកសាក្សី ខ្ញុំសូមអរគុណអំពីការចូលរួមវិភាគទានដ៏សំខាន់របស់លោកសាក្សី។

[១០:២៤:០៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ តើអស់លោក លោកស្រីចៅក្រម មានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរទេ? សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំមានសួរ-- សំណួរមួយចំនួនដើម្បីសួរលោក។ ជាដំបូង ខ្ញុំចង់ត្រឡប់មកនិយាយអំពីទំនួលខុសត្រូវរបស់លោកក្នុងឋានៈជាមេឃុំសំបូរ បន្ទាប់មកជាប្រធានសហករណ៍ស្រែខ្មើន។ លោកបានឆ្លើយថា៖ "ឃុំសំបូរត្រូវបានចែកជាសហករណ៍ពីរ"។ តើលោកអាចប្រាប់បានទេថា តើមានភូមិអ្វីខ្លះដែលស្ថិតនៅក្រោមសហករណ៍ស្រែខ្មើននោះ?

**លោក ខៀវ នៅ៖**

**ឆ៖** បាទ ឃុំសំបូរនេះមាន កាលពីពេលនោះមានប្រាំបីឃុំ នៅពេលដែលបែងចែកជាសហករណ៍ពីរ សហករណ៍សំបូរ និងសហករណ៍ស្រែខ្មើន។ សហករណ៍ស្រែខ្មើននេះមានបួនភូមិ គឺមួយភូមិកែងប្រាសាទ ទីពីរភូមិស្រែខ្មើន ទីបីភូមិចារថ្មោល និងទីបួនភូមិសំរោង។ បាទ សូមអស់មតិ។

**ស៖** ដោយសារតែមានបញ្ហាខាងការបកប្រែជាភាសាបារាំង ខ្ញុំចង់សួរលោកថា តើភូមិទាំងបួននោះ គឺកែងប្រាសាទ ស្រែខ្មើន ចារថ្មោល និងសំរោង។ តើបួនហ្នឹងមែនទេ? ខ្ញុំសូមអភ័យទោសផងពីព្រោះការអានជាភាសាខ្មែររបស់ខ្ញុំ វាមិនល្អទេ។

**ឆ៖** បាទ ភូមិទាំងបួននេះពិតហើយ។

[១០:២៦:០៩]

**សះ** តើសហករណ៍ស្រែខឿន ត្រូវបានស្គាល់ថាជាសហករណ៍កែងប្រាសាទដែរ តើអ៊ីចឹងមែនទេ?

**ឆះ** សហករណ៍ស្រែខឿន គឺសហករណ៍ស្រែខឿន គេអត់ហៅសហករណ៍កែងប្រាសាទ គ្រាន់តែកែងប្រាសាទនេះ វាស្ថិតនៅក្នុងសហករណ៍ស្រែខឿន ជាភូមិមួយដែលនៅក្នុងសហករណ៍ស្រែខឿនហ្នឹងបាទ។ ខ្ញុំសូមអស់មតិ។

**សះ** តើមន្ទីរសន្តិសុខគោកក្ដួចស្ថិតនៅឯណាដែរ?

**ឆះ** មន្ទីរសន្តិសុខគោកក្ដួច ស្ថិតនៅក្នុងភូមិកែងប្រាសាទ នៅ ហើយចម្ងាយពីមាត់ទន្លេចូលទៅខាងក្នុងប្រហែលជាពីរគីឡូម៉ែត្របាទ។

**សះ** តើមន្ទីរសន្តិសុខកោះសំតួច នោះស្ថិតនៅក្នុងភូមិកែងប្រាសាទដែរឬទេ?

**ឆះ** មន្ទីរសន្តិសុខកោះសំតួច អាកោះសំតួចនេះ ជាកូនកោះតូចមួយដែលស្ថិតនៅក្បាលភូមិស្រែខឿន ហើយកន្លែងនេះមិនមែនជាមន្ទីរសន្តិសុខអីធំដុំទេ គឺអ្នកទោសមួយចំនួនដែលគេយកមកដាក់នៅកោះសំតួចនេះ គឺសម្រាប់ធ្វើបន្លែបង្ការឲ្យចិញ្ចឹមកន្លែងគោកក្ដួចអីហ្នឹង ព្រោះកន្លែងហ្នឹងវាមានទឹកនៅជុំវិញ ហើយកោះហ្នឹងក៏មានដីល្អគួរសម។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១០:២៨:២៧]

**សះ** តើកោះក្ដួចនោះស្ថិតនៅក្នុងព្រំដែនសហករណ៍ស្រែខឿនដែរឬទេ?

**ឆះ** មន្ទីរគោកក្ដួចនេះ មិនស្ថិតនៅក្នុងសហករណ៍ស្រែខឿនទេ។ ពិតមែនទឹកដីនៅក្នុងសហករណ៍ខឿន ប៉ុន្តែការគ្រប់គ្រង គឺនៅក្រោមការគ្រប់គ្រងរបស់ស្រុក។ ខ្ញុំសូមអស់មតិ។

**សះ** តើលោកអាចបញ្ជាក់បានទេថា អ្នកណាជាប្រធានមន្ទីរសន្តិសុខគោកក្ដួច?

**ឆះ** ចំពោះបញ្ហាគោកក្ដួចនេះ ខ្ញុំជាប្រធានដែលនៅប្រចាំការ ខ្ញុំក្ដាប់មិនបានទេ ប៉ុន្តែគ្រាន់តែខ្ញុំដឹងថា ពីមុនសន្តិសុខគោកក្ដួចនេះនៅក្រោមការគ្រប់គ្រងរបស់ អ៊ុង សាម៉ុន។ អ៊ុង សាម៉ុនហ្នឹងដល់គេដក អ៊ុង សាម៉ុន ទៅធ្វើមេឃុំនៅវត្តខ្លះទៅ អ្ហឺ! ដូចជាឈ្មោះ គិន ជន។ ដល់ក្រោយមក គេចាប់ អ៊ុង សាម៉ុន ពីវត្តខ្លះទៅ គេយក គិន ជន ហ្នឹងទៅធ្វើមេឃុំវត្តខ្លះទៀត។ ហើយចាប់ពីពេលនោះមក ខ្ញុំអត់ដឹងថាពីណាជាប្រធានទេ គ្រាន់តែដឹងថា អ្នកនៅប្រចាំការឈ្មោះ សារឿន។ ហើយនិងគេយកម្នាក់នោះធ្លាប់ធ្វើការជាមួយខ្ញុំនៅវត្តខ្លះឈ្មោះ បេ ម៉េងអាន ហ្នឹងគេឲ្យមកធ្វើលេខានៅគោកក្ដួច។ លេខាកត់ត្រាផ្សេងៗនៅគោកក្ដួចហ្នឹង មិនមែនលេខាបក្សគោកក្ដួចទេបាទ។ ខ្ញុំសូមអស់មតិ។

**សៈ** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ ដើម្បីបានយល់ឲ្យកាន់តែច្បាស់ លោកឆ្លើយថា នៅពេលណាមួយនោះ សារុន ជាប្រធានមន្ទីរសន្តិសុខគោកក្ដួច តើមែនទេ?

**ឆៈ** ខ្ញុំសូម-- អ្ហឺ! លោកបញ្ជាក់ម្ដងទៀត តើ សារុន អ្ហឺ? សារិន-- សារឿន? បើ សារឿន គាត់ជាដូចថា អ្នកប្រចាំការនៅកន្លែងនុំងបាទ។

[១០:៣១:០០]

**សៈ** ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់បន្តិចជាងនេះទៅទៀត សូមទោសផងចំពោះការអានឈ្មោះ សារុន ថាគាត់ជាប្រធាន ប-៣ តើប្រធាន ប-៣ ក៏ជាប្រធានគោកក្ដួចដែរមែនទេ?

**ឆៈ** ប-៣ និងគោកក្ដួចនេះ គឺផ្សេងគ្នា។ គោកក្ដួចនេះ គឺជាមន្ទីរសន្តិសុខរបស់ស្រុកសំបូរ។ ឯគោកក្ដួចនោះកាលពីមុនទៅជាការដ្ឋានយុវជន យុវនារីនេះ គឺជាកន្លែងសន្តិសុខរបស់ខេត្តដែលគេប្រមូលកម្មាភិបាលទៅដាក់នៅទីនោះ។ កម្មាភិបាលពីឃុំផ្សេងៗ ពីស្រុកផ្សេងៗទៅដាក់នៅ ប-៣ ហ្នឹង អ៊ីចឹងគឺមួយជាកន្លែងរបស់ខេត្ត មួយជាកន្លែងរបស់ស្រុក។ បាទ ខ្ញុំសូមអស់មតិ។

**សៈ** ខ្ញុំសូមសួរសំណួរឡើងវិញ ពីព្រោះលោកអត់បានឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ។ តើឈ្មោះ សារឿន ដែលលោកទទួលបន្តនៅ ប-១ -- ប-៣ នោះគាត់ជាប្រធានមន្ទីរគោកក្ដួចមែនដែរឬទេ?

[១០:៣២:២៧]

**ឆៈ** សារឿន ដែលនៅកន្លែង ប-៣ ទៅគ្រប់គ្រងយុវជន យុវនារីមុនខ្ញុំនោះ មិនមែនជាប្រធានសន្តិសុខគោកក្ដួចទេ។ សារឿន នៅគោកក្ដួចនេះ ផ្សេង។ សារឿន នៅខាងយោធា ទទួលនៅ ប-៣ ហ្នឹងផ្សេង។ មនុស្សពីរនាក់ ប៉ុន្តែឈ្មោះដូចគ្នា។

**សៈ** លោកបានឆ្លើយកាលពីម្សិលមិញថា នៅពេលដែលលោកធ្វើជាប្រធានសហករណ៍ស្រែខឿន ហើយបន្ទាប់មកជាប្រធាន ប-៣ លោកមានអនុប្រធានម្នាក់ តើលោកអាចបញ្ជាក់ពីឈ្មោះអនុប្រធានរបស់លោកបានទេ?

**ឆៈ** នៅពេលដែលខ្ញុំទៅទទួលនាទីនៅ ប-៣ បាទ នៅអង្គភាពយុវជន យុវនារីហ្នឹង ខ្ញុំទៅពីរនាក់ ម្នាក់ទៀតឈ្មោះ ពេន ដែលខាងស្រុកគេចាត់តាំងឲ្យទៅធ្វើជាអនុខ្ញុំ ហើយឈ្មោះ ពេន នេះទៅនៅ ប-៣ ជាមួយខ្ញុំនុំងបានប្រហែលជាបីខែ គេដកឲ្យឈ្មោះ ពេន ហ្នឹងមកធ្វើជាប្រធានសហករណ៍នៅវត្តឫនៈវិញ ពីព្រោះប្រធានសហករណ៍វត្តឫនៈត្រូវគេចាប់ខ្លួន។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១០:៣៤:១១]

**ស៖** តើ ពេន ក៏ជាអនុប្រធានរបស់លោកដែរ មែនទេនៅពេលដែលលោកធ្វើជាប្រធានសហករណ៍ស្រែខឿននោះ?

**ឆ៖** បាទ ពេន ហ្នឹងជាអនុប្រធានរបស់ខ្ញុំនៅសហករណ៍ស្រែខឿន ដល់ពេលខ្ញុំទៅនឹង ប-៣ ខាងស្រុកគេឲ្យ ពេន ហ្នឹងទៅជាមួយខ្ញុំទៀត។ បាទ សូមអស់មតិ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ក្នុងលក្ខខណ្ឌណាដែល ពេន ត្រូវស្លាប់នោះ?

**ឆ៖** នៅពេលដែល ពេន មកធ្វើប្រធានសហករណ៍នៅវត្តនរៈនេះ រហូតដល់ពេលជម្លៀសបាទ។ ដល់ពេលជម្លៀស ដល់ក្រោយរំដោះឆ្នាំ ថ្ងៃ៧ មករា ៧៩ នេះ ពេន គាត់ត្រឡប់ពីកន្លែងរត់មកវិញ ដល់មកដល់ភូមិព្រៃកគ្រៀង អ្នកភូមិព្រៃកគ្រៀងហ្នឹងគឺវ៉ៃគាត់ងាប់ទៅ។ បាទ ខ្ញុំសូមអស់មតិ។

**ស៖** ដូច្នេះមានន័យថា ប្រជាជនជាអ្នកសម្លាប់គាត់មែនទេ? ហើយហេតុអីបានជាប្រជាជនសម្លាប់គាត់?

**ឆ៖** ខ្ញុំក្តាប់មិនបានច្បាស់ដែរ ហើយខ្ញុំក៏អត់បានស្រាវជ្រាវបញ្ហានេះ បើតាមដឹងល្អិចល្អៀងខ្លះឮថាមានគំនុំផង ហើយម្យ៉ាងទៀត ពេលរត់ហ្នឹងគាត់ផ្ញើសម្ភារៈជាមួយពួកអ្នកសម្លាប់គាត់ហ្នឹងមួយចំនួនរបស់របរប្រើប្រាស់ មានតាំងពីខោអាវជាដើមហ្នឹង ដល់ពេលគាត់ទៅយកសម្ភារៈរបស់គាត់ហ្នឹងគេវ៉ៃគាត់តែម្តង។ បាទ ខ្ញុំសូមអស់មតិ។

[១០:៣៦:៤០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំមិនដឹងថា តើយើងសម្រាកសិន ឬក៏ខ្ញុំសួរសំណួរបន្ត ពីព្រោះថាខ្ញុំមានសំណួរពីរទៀត ដូច្នេះខ្ញុំគិតថា ជាពេលសមស្របក្នុងការឈប់សម្រាកលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តឲ្យចប់ទៅ! ឲ្យចប់សំណួរលោកទៅ ពីរសំណួរទៀត។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ឥឡូវនេះខ្ញុំចង់ឲ្យលោកនិយាយឲ្យបានលម្អិតបន្តិចអំពីប-៣។ លោកបាននិយាយថា កាលពីមុន ប-៣ ជាមន្ទីរសន្តិសុខ ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ នៅពេលដែលលោកទៅដល់ ប-៣ តើលោកឃើញអ្នកណាខ្លះនៅ ប-៣ ហ្នឹង? តើជាប្រជាជនប្រភេទណា? ហើយបន្ទាប់មកតើពួកគាត់ហ្នឹងក្លាយទៅជាអ្វី?

[១០:៣៧:៣៣]

**លោក យុន គីម៖**

**ឆ៖** ប-៣ នេះគឺជាកន្លែងដែលគេប្រមូលផ្តុំគណៈសហករណ៍ ឬក៏ និងថ្នាក់ស្រុកខ្លះដែលមាន ដែលគេកំណត់ថាជាខ្មាំង ជាអ្នកដែលមានត្រូវមានទោសហ្នឹង គឺយកមកដាក់នៅ ប-៣ ហ្នឹង ប៉ុន្តែក្នុង ក្របខ័ណ្ឌមួយ គេមិនមិនកំណត់ថាជាកន្លែងទីតាំងសន្តិសុខដែលធ្ងន់ធ្ងរនោះទេ គឺរបៀបដូចជាកន្លែង កែប្រែ។ កែប្រែនេះបានន័យថា យកមកអប់រំណែនាំ ដោយពួកនេះមានសិទ្ធិសេរីភាពក្នុងការធ្វើការងារ ដូចនៅសហករណ៍អ៊ីចឹង រើរានដីធ្វើស្រែធ្វើចម្ការអីអ៊ីចឹង។ បាទ ហើយដល់ពេល-- ខ្ញុំមិនដឹងជាអង្គភាព ប-៣ នេះចេញអស់ពីពេលណាទេ។ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា នៅក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៨ គេ ប្រមូលយុវជន យុវនារីមកដាក់នៅ ប-៣ នេះដោយឲ្យឈ្មោះ សារិន ជាយោធាជាអ្នកគ្រប់គ្រង។ ហើយដល់គេប្រាប់ខ្ញុំថា សារិន គ្រប់គ្រងយុវជនយុវនារីអត់បានទេ ពីព្រោះវាប្រើតែយោធា បានន័យថា ពាក្យយោធានេះបានន័យថា ដូចថា ប្រើអំណាចខ្លាំងពេក។ អ៊ីចឹងបានគេស្នើឲ្យខ្ញុំជាមួយ ពេន ហ្នឹងមក កាន់កាប់នៅកន្លែង ប-៣ នេះវិញ។

[១០:៣៩:២០]

នៅពេលដែលខ្ញុំមកដល់ ប-៣ នេះខ្ញុំឃើញតែយុវជនយុវនារី កំពុងតែបំពេញការងារដែរ ធ្វើ គាស់រើរានដី។ គាត់រើរានដី បាទដោយមានរោងនោះ ៥០អង្កាល់ហ្នឹង។ មានរោង៥០ រោងតូចៗល្មម មួយរោងរស់នៅ៨នាក់ រោងខ្លះ១០នាក់អ៊ីចឹង។ ហើយមានមន្ទីរបាយមួយ នៅកន្លែង ប-៣ ហ្នឹង ហើយ ក្រៅពីនេះអត់មានដូចថា ផ្នែកសន្តិសុខមានខ្នោះមានឃ្នាងអត់មានទេនៅកន្លែងហ្នឹង។ អ៊ីចឹងខ្ញុំសន្និដ្ឋាន ថា អ្នកដែលមក ប-៣ នេះ មិនទាន់ចូលដល់លក្ខណៈដែលធ្ងន់ធ្ងរទេ របៀបដូចថា គេយកដកមកពី គណៈផ្សេងៗហ្នឹងមកនៅ ដើម្បីអប់រំណែនាំយ៉ាងម៉េច ខ្ញុំមិនដឹងដែរ។ នេះខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ស៖** មិនមានការដាក់ខ្នោះ ដាក់អីទេ។ តើមានអ្នកយាមទេ មានអ្នកកាន់អាវុធទេ កាន់កាំភ្លើង កាន់អីទេ ដើម្បីធានាថា អ្នកនៅមន្ទីរ ប-៣ ហ្នឹង មិនរត់ចេញពីកន្លែងនុ៎ង?

[១០:៤០:៣៦]

**ឆ៖** ដូច ខ្ញុំបានជម្រាបអ៊ីចឹង ថាខ្ញុំមក ប-៣ នេះ ខ្ញុំអត់បានជួបអីទាំងអស់ ពីព្រោះខ្ញុំមក ក្រោយទេ គឺពួកកម្មាភិបាលនៅ ប-៣ ហ្នឹង ក៏ចេញបាត់អស់ហើយ ដែលកម្មាភិបាលដែលគេហៅ គេ ចាប់មកហ្នឹង គឺចេញពីនេះអស់ហើយ អត់មាននៅកន្លែងហ្នឹងទៀតទេ ហើយនៅសល់តែយុវជន

យុវនារី ដែលគេមកតាំងពីខែ៤ ចុងខែ៤ មកនៅទីនេះ។ អ៊ីចឹងគឺ អាសភាពការណ៍ជាក់ស្តែង ប-៣ នៅពេលដែលគេប្រមូលផ្តុំពួកកម្មាភិបាលមកនៅទីនេះនោះ ខ្ញុំអត់បានឃើញ ហើយអត់បានដឹង។ បាទ ខ្ញុំសូមអស់មតិ។

**ស៖** លោកសាក្សី នៅពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោក លោកថា មានយុវជន ៤៥០នាក់ ហើយនិងមាន២៥០នាក់បន្ថែមទៀត។ ខ្ញុំគិតថា គឺប្រហែលជាមានយុវជន៦៥០នាក់ ហើយសរុបទៅនៅមន្ទីរ-- នៅប-៣ នោះ តើអ៊ីចឹងមែនទេ លោកសាក្សី?

**ឆ៖** នៅ ប-៣ នេះ គឺយុវជនដែលមានហើយ នៅពេលខ្ញុំទៅដល់មាន៤៥០នាក់ ដល់ក្រោយមកមានយុវជន យុវនារីមកពីត្រមូង ទន្លូង នៅខាងមេមត់នេះ ប្រហែល២៥០នាក់ទៀត សរុបទាំងអស់ទៅ ៧០០នាក់នៅក្នុងប-៣ នេះ ប៉ុន្តែយុវជន យុវនារីខាងត្រមូងនេះ មកបានប្រហែលជាពីរខែប្លាយប៉ុណ្ណោះទេ គឺគេដកយកទៅបាត់អស់វិញ ហើយនៅសល់តែយុវជន យុវនារី ចាស់ដែលមានប្រហែល ៤០០នាក់នៅ។ ខ្ញុំសូមអស់មតិ។

[១០:៤២:៥២]

**ស៖** យើងនឹងពិនិត្យមើលទៅលើអ្នកថ្មីនៅពេលក្រោយ។ តើលោកអាចបញ្ជាក់បានទេថា ប-៣ នោះស្ថិតនៅក្នុងព្រៃ។ តើប-៣ នេះស្ថិតនៅក្នុងកន្លែងមួយ ដែលពោពេញដោយជំងឺគ្រុនចាញ់ ឬក៏ស្ថិតនៅកន្លែងមួយ ដែលមានមិនមានការធ្វើកសិកម្មទេ មែនទេ? គឺថា នៅទីនោះគេឲ្យប្រជាជន ឲ្យមនុស្សកាប់ឆ្ការព្រៃ តើលោកអាចប្រាប់បានទេថា អាចមានរហូតទៅដល់៧០០នាក់នៅក្នុងកន្លែងមួយ ដែលមិនមានមន្ទីរពេទ្យ ហើយមិនមានការយាមកាម អត់សន្តិសុខដើម្បីដាក់យាម កុំឲ្យមានមនុស្សរត់ចេញ។ តើលោកចង់មានន័យថា អ៊ីចឹងមែនទេ?

**ឆ៖** ការដ្ឋាន ប-៣ នេះ អត់មានមែនជាកន្លែងមួយដែលព្រួយបារម្ភពីយុវជន យុវនារីរត់ចេញទេ ពីព្រោះជាកន្លែងមួយដែលសុវត្ថិភាពដែរ។ នៅកន្លែង ប-៣ នេះគេឲ្យគ្រូពេទ្យពីរនាក់នៅប្រចាំការ បាទមានគ្រូពេទ្យពីរនាក់នៅជាមួយដែរ ដោយមានថ្នាំសង្កូវអឺសមរម្យ អាចជួយទប់ស្កាប់ ហើយកន្លងក្នុងរយៈពេលដែលខ្ញុំទៅរស់នៅទីនោះ មានដែរបញ្ហាជំងឺគ្រុនចាញ់ ប៉ុន្តែមិនជាធ្ងន់ធ្ងរណាស់ណាទេ សូម្បីតែខ្លួនខ្ញុំហ្នឹង ក៏ជួបហ្នឹងជំងឺគ្រុនចាញ់ដែរ។ បាទ អ៊ីចឹង បានន័យថា នៅ ប-៣ នេះមិនមែនជា-- អត់មានការព្រួយបារម្ភពីរឿងរត់ទេ អត់មានសន្តិសុខយាមអីទេ។

[១០:៤៤:៥៤]

**ស៖** សូមអរគុណលោកសាក្សី។ ដូច្នេះ លោកបានឆ្លើយថា លោកពិបាកក្នុងការអនុវត្តតាមផែនការ ហើយខ្ញុំបន្ទាប់មកទៀត បើតាមការកត់សម្គាល់របស់លោកនោះ គឺថាលោកបានឃើញមានមនុស្សថ្មី មានយុវជនថ្មីមកដល់។ តើលោកអាចបញ្ជាក់បានទេថា យុវជនថ្មីទាំងនោះមកពីកន្លែងណា?

**ឆ៖** យុវជន យុវនារីថ្មីដែលខ្ញុំបានជម្រាបអំមិញ ដែលមកនៅ ប-៣ ក្រោយ ដែលចំនួនប្រហែល២៥០នាក់ហ្នឹងមកពីខាងស្រុកមេមត់ ក្នុងខេត្តកំពង់ចាម។ ហើយខ្ញុំអត់បានច្បាស់ពីមូលហេតុអី បានជាគេបញ្ជូនយុវជន យុវនារីទាំងអស់ហ្នឹងមកកន្លែងខ្ញុំទេ ប៉ុន្តែគ្រាន់តែដឹងថា ភូមិត្រមូង នៅក្នុងស្រុកមេមត់នេះ វានៅជិតព្រំដែនវៀតណាម។ អ៊ីចឹង ខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ទំនងជានៅមានសំណួរច្រើនទៀត ហើយពេលវេលា ក៏សមនឹងសម្រាកហើយគាត់ថា មានពីរៗសំណួរទៀត ប៉ុន្តែមិនមែនពីរដូចគាត់ថាទេ អ៊ីចឹងអាចមានច្រើនទៀត។

ឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាក ម្ភៃនាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ នៅបន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយប្រាំនាទី។

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៧ នាទី ដល់ម៉ោង ១១:០៦ នាទី)*

[១១:០៦:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅលោកចៅក្រមហ្សង់ម៉ាក ឡាវែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញលោកចៅក្រម!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី ខ្ញុំចង់ត្រឡប់មកនិយាយអំពីយុវជន ២៥០នាក់បន្ថែម ដែលមកធ្វើការនៅការដ្ឋាន ប-៣។ លោកបានឆ្លើយថា គាត់មកពីកន្លែងដូចគ្នា គឺមកពីស្រុកមេមត់។ ខ្ញុំចង់ដឹងថា តើពួកអ្នកទាំងអស់ហ្នឹង សុទ្ធតែជនជាតិចាម ឬក៏ជាជនជាតិខ្មែរ?

[១១:០៧:៤៦]

**លោក យុន គីម៖**

**ឆ៖** បាទ យុវជនទាំង២៥០នាក់ ដែលមកពីខាងមេមត់នេះ ជាជនជាតិខ្មែរទាំងអស់។

**ស៖** លោកក៏បានឆ្លើយផងដែរ ពួកគេត្រូវបានបញ្ជូន ប-៣ ដោយសារគេគិតថា មានជាប់ខ្សែជាមួយវៀតណាម ការគាំទ្រវៀតណាម។ តើលោកអាចបញ្ជាក់ពីចំណុចនេះបានទេ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា ពួកនេះ នៅជិតវៀតណាម ហើយឃើញគេបញ្ជូនមកហ្នឹង មិនដឹងជាថាវាពាក់ព័ន្ធយ៉ាងម៉េច អីយ៉ាងម៉េច ខ្ញុំក្តាប់អត់បានដែរបាទ។

**ស៖** លោកសាក្សីនៅក្នុងសក្ខីកម្មរបស់លោក ដែលមានលេខ D185/184 ឬក៏ E3/368 លោកនិយាយថា អ្នកត្រមូង ត្រូវបានចោទថា ជាប់ខ្សែជាមួយវៀតណាម។ តើលោកមាននៅចងចាំពីចម្លើយដែលលោកបានឆ្លើយនេះទេ?

**ឆ៖** បាទ ពេលនោះ ខ្ញុំបាន-- គ្រាន់បានដឹងថាអ្នកនេះ នៅជិតវៀតណាម ហើយវាមានបញ្ហាពាក់ព័ន្ធជាមួយវៀតណាម ឬក៏យ៉ាងណានោះ គឺឲ្យច្បាស់លាស់ គឺខ្ញុំអត់បានច្បាស់លាស់ដែរបាទ។ នេះគ្រាន់តែពាក្យដែលថា ពួកនេះ អាចត្រូវរ៉ូវជាមួយវៀតណាមហើយ បានគេបញ្ជូនមក។ ហ្នឹង ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១១:០៩:៥៨]

**ស៖** ស្រុក-- តើស្រុកមានបានផ្តល់ដំណឹងដល់លោកអំពីការមកដល់របស់យុវជននេះទេ ឬក៏មានការផ្តល់ដំណឹងនៅពេលប្រជុំអីទេលោក?

**ឆ៖** ពេលដែលយុវជន យុវនារី ទាំង២៥០នាក់នេះមក គឺស្រុកគេបានផ្តល់ព័ត៌មានដែរ គេផ្តល់នៅពេលដែលពួកនេះមកដល់ហើយហ្នឹង។ ដល់ចូលមកដល់កន្លែងគេគ្រាន់ថា ឥឡូវនេះបន្ថែមកម្លាំង

២៥០នាក់ទៀត ដែលជាពួកអ្នកពួកនៅឃុំត្រមូង នៅក្នុងស្រុកមេមត់ ព្រោះពួកនេះនៅជិតវៀតណាម។ អ៊ីចឹងគេបញ្ជូនមក។ ខ្ញុំសូមអស់មតិ។

**ស៖** គឺជាស្រុកដែលមិនស្ថិតនៅក្រោមតំបន់៥០៥ ទេ។ តើនៅស្រុកនោះគេមានប្រាប់លោកអំពីសំណើដែលដាក់ទៅថ្នាក់លើដើម្បីឲ្យមានការបញ្ជូនមនុស្សមកទេ?

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំអ្នកនៅការដ្ឋាននេះ គ្រាន់តែឃើញថាកម្លាំងគេមកដល់ គេប្រាប់ថា ឥឡូវបន្ថែមកម្លាំងឲ្យ២៥០នាក់ ទៀតប៉ុណ្ណឹង។ បាទ ខ្ញុំសូមអស់មតិ។

[១១:១១:៣៩]

**ស៖** ហើយយុវជនទាំង២៥០នាក់នេះ បាត់ខ្លួនភ្លាមៗតែម្តង ឬក៏មានរឿងអីកើតឡើងចំពោះពួកអ្នកទាំងនេះ?

**ឆ៖** ពួកទាំងនេះមកនៅជាមួយការដ្ឋានខ្ញុំនេះ បានប្រហែលជាពីរខែជាង ស្រាប់តែ គេថាគេដកយុវជន យុវនារី ទាំងអស់នេះទៅវិញ ហើយឮគេថាយកទៅខាងកំពង់ធំ។ ប៉ុន្តែទៅណាមកណា ខ្ញុំអត់ដឹងទេណា គ្រាន់តែដឹងថាចេញផុតពីខ្ញុំទៅ ទៅកំពង់ធំ ឬក៏យកទៅណាទៀតនោះ ខ្ញុំក្តាប់អត់បានដែរ។ ហើយមកដល់ពេលនេះ ខ្ញុំក៏បានអត់ដឹងថាតើក្នុងចំណោមយុវជន យុវនារីទាំងអស់នោះ នៅរស់ឬស្លាប់ក៏អត់ដឹង។ បាទ ខ្ញុំសូមអស់មតិ។

**ស៖** អម្បាញ់មិញនេះ ប្រហែលជាខ្ញុំស្តាប់មិនឮ ឬក៏ខ្ញុំមិនបានយកចិត្តទុកស្តាប់ឲ្យបានច្បាស់។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ឡើងវិញឲ្យបានច្បាស់ ថាតើ ប-៣ នៅឯណាដែរ?

[១១:១២:៤៧]

**ឆ៖** ប-៣ ជាទីតាំងមួយដែលបច្ចុប្បន្ននេះគឺ ទីតាំងនេះ អ៎! ស្ថិតនៅ បើយើងទៅតាមដងផ្លូវពីសណ្តាន់ទៅ-- ពីមុនផ្លូវហ្នឹងវាតែមួយទេ ផ្លូវលេខ៧ ដល់ឥឡូវនេះគេធ្វើផ្លូវថ្មីទៅ អត់ទាន់ដល់ក្រចេះគឺកាត់ទៅស្ទឹងត្រែងតែម្តង។ អានេះផ្លូវចាស់ ផ្លូវស្ទឹងត្រែងចាស់។ ទៅពីសណ្តាន់ទៅ ទៅឃុំសណ្តាន់ហ្នឹង នៅចម្ងាយពីទីរួមខេត្តក្រចេះ ២៤គីឡូ។ យើងចេញពី តាមផ្លូវចាស់ទៅស្ទឹងត្រែងហ្នឹង ពីសណ្តាន់ទៅ១៥គីឡូ យើងមានផ្លូវលំមួយចូល ចូលទៅក្នុង។ យើងទៅពីផ្លូវជាតិហ្នឹងប្រហែលជាពីរគីឡូដល់មាត់អូរតាគត់។ អូរមួយឈ្មោះអូរតាគត់ គឺប-៣ ស្ថិតនៅកន្លែងនោះតែម្តង។ ប-៣ នេះមានពីរ អ៎!មានន័ គេហៅស្រែរុំង ផង គេហៅប-៣ ផង។ ស្រែរុំងនេះ មានស្រែរុំងខាងប្រជាពលរដ្ឋ និងស្រែរុំងខាងការដ្ឋាននៅជំនាន់នោះ។ បាទ មួយផ្នែកមួយកង់ខាងលើការដ្ឋាន មួយកង់ខាងក្រោមគឺ

ប្រជាជនគេធ្វើស្រែនៅជាប់គ្នាហ្នឹងដែរ។ បាទ សូមអស់យោបល់។

[១១:១៩:២២]

**ស៖** ដូច្នេះ តើប-៣ នៅជិតភូមិមួយដែលឈ្មោះគេកត់(ស៊ីក) ជិតស្រុកសំបូរ ស្រុកក្រចេះ ខេត្តក្រចេះមែនទេ?

**ឆ៖** ប-៣ ហ្នឹងគឺទីតាំងវានៅក្បែរ គេហៅភូមិស្រែរ៉ុងរបស់ប្រជាពល ប៉ុន្តែអត់មានមនុស្សនៅជាប់ទេ កន្លែងហ្នឹងគឺស្រែរបស់ប្រជាជន។ ហើយបច្ចុប្បន្ននេះ ប-៣ ហ្នឹងគឺ បើគិតមកដល់ឥឡូវនេះ គឺទឹកដីហ្នឹងវានៅក្នុងស្រុកក្រចេះមួយចំហៀង នៅក្នុងស្រុកសំបូរមួយចំហៀង ពីព្រោះបែងចែងអូរតាគត់ហ្នឹងជាព្រំប្រទល់របស់ស្រុក។ នេះខ្ញុំសូមបញ្ចប់មតិប៉ុណ្ណេះ។

**ស៖** ឥឡូវនេះខ្ញុំចង់ត្រឡប់មកនិយាយអំពីការមកដល់របស់ប្រជាជនថ្មី។ លោកបានឆ្លើយថា នៅពេលដែលលោកធ្វើជាប្រធានសហករណ៍សំបូរ ឃុំសំបូរ គឺថាមានប្រជាជន១៧ មេសា ជាង១០០ គ្រួសារ។ តើ១០០គ្រួសារនេះ មានប្រហែលជាមនុស្សប៉ុន្មាននាក់ដែរ?

**ឆ៖** ប្រជាពលរដ្ឋឃុំថ្មីដែលជម្លៀសពីភ្នំពេញទៅៗដល់ស្រុកសំបូរនេះ មានជាង១០០គ្រួសារ។ ឯចំនួនមនុស្សខ្ញុំអត់បានច្បាស់លាស់ទេបាទ មិនអាចសន្និដ្ឋានបាន ព្រោះអត់បានចាប់អារម្មណ៍។

[១១:១៦:១៨]

**ស៖** តើមានជនជាតិភាគតិចនៅក្នុងឃុំសំបូរដែរឬទេ?

**ឆ៖** នៅក្នុងឃុំសំបូរនេះ គឺមិនមានជនជាតិភាគតិចទេ គឺខ្មែរទាំងអស់ បាទ។ ដល់ក្នុងស្រុកសំបូរបានមានជនជាតិភាគតិចច្រើន។ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំចង់ប្រគល់ជូនទៅសាក្សីនូវឯកសារមួយដែលឯកសារ D125/8។ នេះគឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សីមួយរូប ដោយសារតែជាការសម្ងាត់នោះ ខ្ញុំសូមមិនបង្ហាញឈ្មោះសាក្សីរូបនេះទេ។ ក៏ប៉ុន្តែលោក យុន គីម និងមេធាវីរបស់គាត់អាចទទួលបានព័ត៌មានពាក់ព័ន្ធនឹងឯកសារនេះ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារលេខ D125/8 ជូនទៅសាក្សី និងមេធាវីរបស់គាត់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារផ្តល់ជូនទៅមេធាវី និងសាក្សីពិនិត្យ។ មេធាវីគ្រាន់តែពិនិត្យឈ្មោះពិតប្រាកដទៅបានហើយ ដើម្បីឲ្យសាក្សីហ្នឹងបានយល់ដឹង ថា

ខ្ញឹមសារចម្លើយហ្នឹង គឺជាបុគ្គលមួយដែលនៅទីនេះយើងលាក់អត្តសញ្ញាណរបស់គាត់។ គ្រាន់តែឲ្យសាក្សីដឹងអត្តសញ្ញាណនុំងនៅក្នុងចិត្តប៉ុណ្ណោះ នៅក្នុងការគំនិតប៉ុណ្ណោះ មិនមែនឲ្យបញ្ចេញនូវឈ្មោះអត្តសញ្ញាណរបស់សាក្សីនៅក្នុងកំណត់ហេតុនោះទេ។ ពីព្រោះត្រូវអនុវត្តនូវគោលការណ៍នៃការលាក់អត្តសញ្ញាណសាក្សី។ អនុវត្តនូវវិធានការការពារសាក្សី។

[១១:១៨:៣៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកស្រីចៅក្រម ខ្ញុំសូមស្នើឲ្យមានការបំភ្លឺ ថាតើសាក្សីរូបនេះជាឈ្មោះសាក្សីត្រូវបានបង្ហាញទៅសាក្សីនេះ គឺជាសាក្សីដែលមកបង្ហាញ និងផ្តល់សក្ខីកម្មដែរឬអត់? ពីព្រោះថាគឺសាក្សីរូបនេះអាចតែយកកំណត់ហេតុសាក្សីណាដែលនឹងមិនកោះអញ្ជើញមកធ្វើសក្ខីកម្មតែប៉ុណ្ណោះ។ អ៊ីចឹងខ្ញុំសូមការបំភ្លឺពីអង្គជំនុំជម្រះ បាទ។

[១១:១៩:១៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឆ្លើយតបទៅនឹងចម្ងល់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំគិតថា ការស្នើសុំនេះត្រូវតែមានការស្រាវជ្រាវសិន ព្រោះថា ខ្ញុំមិនដឹងថាតើមាននៅក្នុងបញ្ជីដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មនោះទេ។ ប៉ុន្តែចំពោះខ្ញុំ ខ្ញុំមិនគិតថាមាននៅក្នុងបញ្ជីទេ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវតែធ្វើការពិនិត្យផ្ទៀងផ្ទាត់ ហើយខ្ញុំឃើញថាសហព្រះរាជអាជ្ញាប្រហែលជាគាត់មានព័ត៌មានពាក់ព័ន្ធទៅនឹងសាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

បាទ លោកប្រធានសាក្សីរូបនេះ គឺមិនស្ថិតនៅក្នុងចំណោមសាក្សីដែលនឹងកោះអញ្ជើញមកធ្វើសក្ខីកម្មទេ ហើយខ្ញុំមិនជឿថា សាក្សីនេះគឺ-- សាក្សីរូបនេះគឺអង្គជំនុំជម្រះប្រហែលជាមិនៗកោះអញ្ជើញគាត់មកទេបាទ។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

បាទ អរគុណ។ បាទ ខ្ញុំបានការបំភ្លឺ។

[១១:២០:៣៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សម្រាប់ជាប្រតិចារឹកនោះ ខ្ញុំសូមផ្តល់លេខ ERN នៃឯកសារនេះគឺ ERN ជាភាសាខ្មែរ 0019 4474 ទៅដល់ 00194480, ERN ជាភាសាបារាំង 00272304 ទៅដល់ 00222310, ERN ជាភាសាអង់គ្លេស 00272297 ទៅដល់ 00272303។ នេះគឺជាសាក្សីមួយដែលបានឆ្លើយថា គាត់ស្ថិតនៅក្នុងកងជីវពល ហើយគាត់បានបញ្ជាក់ថា នៅឆ្នាំ៧៦ គេដកគាត់យកទៅដាក់នៅក្នុងសហករណ៍ដែលស្ថិតនៅក្នុងភូមិកែងប្រាសាទ ហើយគាត់បានរៀបរាប់អំពីលក្ខខណ្ឌការងារនៅក្នុងសហករណ៍នេះ។

[១១:២១:៤៥]

គាត់បានឆ្លើយដូចតទៅនេះ នៅក្នុងទំព័រ៣ ជាភាសាបារាំង៖ "នៅចន្លោះខែ៦ ខែ៧ ឆ្នាំ១៩៧៦ គេបានដកខ្ញុំឲ្យធ្វើការនៅក្នុងសហករណ៍នៅក្នុងភូមិកែងប្រាសាទ។ គេបានបង្ខំឲ្យខ្ញុំធ្វើការទាំងយប់ទាំងថ្ងៃ។ ធ្វើស្រែចម្ការសព្វបែបយ៉ាង ឃ្វាលគោក្របី ធ្វើបន្លែបង្ការ គឺអត់មានពេលទំនេរទេ។ សម័យនោះគឺមិនទាន់មានម៉ាស៊ីនសម្រាប់កិនអង្ករទេ គេប្រើកម្លាំងមនុស្សពី ២០ ទៅ ៣០នាក់ ក្នុងមួយថ្ងៃសម្រាប់បុកអង្ករ។ ការហូបចុកមិនគ្រប់គ្រាន់ទេ គេហូបរួមគ្នា។ ពេលខ្លះ បានបាយមួយពេល បបរមួយពេលតែប៉ុណ្ណោះ។ នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ មានប្រជាជនថ្មីចូលមកគ្រប់សហករណ៍ទាំងអស់។ ហើយភាគច្រើនជាប្រជាជនថ្មីមកពីកន្លែងផ្សេងៗគ្នា។ មួយផ្នែកជាប្រជាជនបូព៌ាមកពីកំពង់ចាម ត្រូវគេបញ្ជូនមកតំបន់៥០៥ នេះ។ ពេលមកដល់ប្រជាជន១៧មេសា គឺអត់មាននិយាយអ្វីទេ។ គឺមានអ្នកខ្លះស្លាប់ដោយអត់ឃ្លាន។ ប្រជាជនមកពីបូព៌ាមានស្លាប់ដោយសារអត់បាយហូបចុកគ្រប់គ្រាន់ពីមុនមក និងខ្លះទៀតស្លាប់ដោយសារខ្វះថ្នាំព្យាបាលក៏មាន"។

[១១:២៣:២៧]

ហើយបន្ទាប់មកទៀត គាត់បានពន្យល់ថា-- ពន្យល់ទៀតថានេះគឺជាទណ្ឌកម្មដែលដាក់ចំពោះអ្នកដែលប្រព្រឹត្តល្មើស ហើយបន្ទាប់មកទៀតគាត់បានឆ្លើយថា បន្ទាប់មកគាត់បានដកចេញ ហើយទៅភូមិ-- ទៅសហករណ៍នៅភូមិវត្តខ្នុរ:ក្នុងរយៈពេលមួយឆ្នាំ។ ហើយគាត់មិនស្គាល់ប្រធានសហករណ៍នោះទេ។ ហើយក្រោយមកទៀតនោះ គាត់ឆ្លើយថាខ្ញុំចាំតែពីឈ្មោះ តាខាំ ដែលជាប្រធានសហករណ៍ភូមិកែងប្រាសាទ។ គាត់កើតនៅបុស្សខ្នុរ ឥឡូវនេះគាត់រស់នៅភូមិវត្តខ្នុរ: ឃុំវត្តខ្នុរ: ស្រុកសំបូរ ខេត្តក្រចេះ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែង៖**

**ស៖** នៅក្នុងដំណាក់កាលនេះលោកសាក្សី អ្វីដែលខ្ញុំបានអានអម្បាញ់មិញនេះ តើវាត្រឹមត្រូវទៅនឹងការពិតដែលបានកើតឡើងនៅសម័យនោះដែរឬទេ? ឬក៏មានខុសគ្នាពីអ្វីដែលលោកធ្លាប់បានជួបប្រទះនោះ? ហើយបើតាមលោកនោះ តើអ្នកណាជា តាខាំ ប្រធានសហករណ៍ភូមិកែងប្រាសាទនោះ?

[១១:២៤:៥៣]

**លោក យុន គីម៖**

**ឆ៖** ខ្ញុំៗសូមជម្រាបថា ការបំភ្លឺរបស់សាក្សីនេះជារឿងមួយដែលមិនបានល្អប៉ុន្មានទេបាទ ពីព្រោះឈ្មោះដែលខ្ញុំឃើញនៅក្នុងចម្លើយនេះ ដូចគាត់បានបញ្ជាក់ហើយ ថាគាត់នៅសន្តិសុខ គាត់ថាគាត់នៅជីវពល ប៉ុនតាមពិតគាត់នៅសន្តិសុខស្រុកពីមុន។ ដល់ក្រោយមក គេឲ្យគាត់ទៅធ្វើប្រធានសហករណ៍នៅស្រែខឿន។ ហើយក្រោយមកទៀត គេដកគាត់ពីប្រធានសហករណ៍ស្រែខឿន មកធ្វើសហករណ៍វត្តខ្នុរ:បាទ។ ហើយដល់ចុងបំផុត គេចាប់ខ្លួនគាត់ដែរ ប៉ុន្តែគាត់បានរួចខ្លួនអត់ស្លាប់។

ចម្លើយរបស់គាត់នេះ គាត់និយាយនេះ អត់-- គាត់មិនសូវជាច្បាស់លាស់ប៉ុន្មានទេ។ ខ្ញុំ បើតាមសម្តីរបស់គាត់ទទួលអត់បានទេខ្ញុំបាទ។ ហើយ តាខាំ នៅសហករណ៍កែងប្រាសាទនេះ នៅសហករណ៍ស្រែខឿននេះ ដែលនៅគ្រប់គ្រងនឹងភូមិកែងប្រាសាទទាំងនេះ គឺខ្លួនខ្ញុំហ្នឹងតែម្តង។ បាទ ខ្ញុំសូមមានមតិប៉ុណ្ណេះ។

[១១:២៦:២២]

**ស៖** ដើម្បីបំពេញបន្ថែមនូវចម្លើយនេះ ខ្ញុំសូមបញ្ជាក់ថា សាក្សីរូបនេះក៏បានឆ្លើយថា បន្ទាប់មកគេចាប់ខ្លួនគាត់ ហើយគេនាំគាត់ទៅមន្ទីរសន្តិសុខគោកក្តួច។ ហើយប្រធានគុកនៅគោកក្តួចនោះឈ្មោះ តន់ សារឿន ដែលបន្តពីឈ្មោះ ប៊ុន។ តើលោកមានយោបល់អ្វីចំពោះចំណុចនេះទេ?

**ឆ៖** បាទ ពាក់ព័ន្ធនឹងបញ្ហាអ្នកគ្រប់គ្រងនៅគោកក្តួចនេះ ខ្ញុំ ពិតមែនតែខ្ញុំនៅសហករណ៍ស្រែខឿន ហើយខ្ញុំនៅភូមិកែងប្រាសាទដែរ នៅក្បែរកន្លែងគោកក្តួច ប៉ុនអត់ដឹងថាអ្នកណាជាអ្នកទទួលខុសត្រូវទេ ប៉ុន្តែគ្រាន់តែឮថា សារឿន ហ្នឹងអ្នកទទួលខុសត្រូវនៅការដ្ឋានហ្នឹង។ ឯប្រធាននោះ គឺមិនដឹងជាពីណាច្បាស់លាស់ទេ។ ឯ ប៊ុន ដែលមុនហ្នឹងក៏ខ្ញុំក្តាប់អត់បានដែរ។ ប៉ុន្តែបើឈ្មោះ សារឿន នេះគឺខ្ញុំឯកភាពតាមលោក អៀម ហើយព្រោះលោក អៀម ដឹងរឿងគោកក្តួចលើសខ្ញុំ។ អូ៎! សូមអត់ទោសចេញឈ្មោះគាត់បន្តិចហើយ។ បាទ ព្រោះគាត់ដឹង ព្រោះផ្ទះគាត់ក៏នៅហ្នឹង ហើយគាត់ធ្លាប់នៅទីហ្នឹងដែរ។ ខ្ញុំសូមអស់មតិ។

[១១:២៧:៥៩]

**ស៖** តើលោកធ្លាប់ឮកន្លែងមួយដែលគេហៅថា ឃុំ១០០ ដែរទេ ដែលជាឃុំមួយដែលគេកាប់ឆ្ការព្រៃ ហើយគេបញ្ជូនមនុស្សទៅ អាចជាទាហាន លន់ នល់ ហើយនិងអតីតមន្ត្រីរាជការនៃរបបមុន តើលោកធ្លាប់ឮទេពីឃុំ១០០នេះ?

**ឆ៖** ពាក់ព័ន្ធនឹងឃុំ១០០នេះ ខ្ញុំអត់បានដឹងទេ។ ធ្លាប់ឮដែរ ឮថាឃុំ១០០ ៗហ្នឹង ប៉ុន្តែមិនដឹង១០០ហ្នឹងនៅឯណាប្រាកដប្រជាទេ ពីព្រោះខ្ញុំមានចរិតមួយដែលមិនសូវចង់ដឹងពីរឿងគេ។ ខ្ញុំសូមអស់មតិ។

**ស៖** តើមានអ្វីកើតឡើងនៅក្នុងឃុំ១០០នេះ?

**ឆ៖** ដូចខ្ញុំបានជម្រាបហើយ ថាខ្ញុំអត់បានស្គាល់ ១០០នៅត្រង់ណាផង។ អ៊ីចឹងរឿង១០០នេះខ្ញុំអត់មានដឹងអីទាំងអស់។ ខ្ញុំសូមអស់មតិ។

**ស៖** តើឃុំនេះស្ថិតនៅឯណាដែរ?

**ឆ៖** ដូចខ្ញុំបានជម្រាបជូនអ៊ីចឹង ប៉ុនអ្ហឺ! មិនដឹងជានៅក្នុងស្រុកក្រចេះ ឬស្រុកស្នួលទេ ១០០ហ្នឹង ខ្ញុំអត់ច្បាស់លាស់។ ខ្ញុំសូមអស់មតិហើយ។

[១១:២៩:៤៥]

**ស៖** ឥឡូវនេះ ខ្ញុំមានសំណួរមួយចំនួនទៀត ពាក់ព័ន្ធនឹងប្រជាជនចាម។ តើលោកធ្លាប់ឮគេនិយាយអំពីចលនាទូទៅ-- អំពីការជម្លៀសប្រជាជនចាមជាទូទៅចេញពីខេត្តរបស់ពួកគាត់ទេ បើតាមលោកដឹងនោះ តើលោកធ្លាប់ឃើញមានវត្តមានរបស់ជនជាតិចាមនៅក្នុងសហករណ៍របស់លោកទេ ហើយតើចាមនេះស្ថិតនៅក្នុងក្រុមមនុស្សសំខាន់ដែរឬទេ?

**ឆ៖** ខ្ញុំធ្លាប់បានឃើញគេជម្លៀសជនជាតិចាមទៅនឹងក្នុងឃុំវត្តស្លែន: កាលពីខ្ញុំនៅធ្វើមេឃុំនុំង បាទ។ ប៉ុន្តែអត់មានថា អ្នកនោះទៅយើងបែងចែកជាជន ជាមនុស្សប្រភេទណានោះទេ គឺគ្រាន់តែទៅជាសមាជិកនៅក្នុងសហករណ៍ បំពេញការងារជាមួយគេជាមួយឯងទាំងអស់គ្នាធម្មតា។ នេះខ្ញុំសូម--ឯចំពោះខេត្តផ្សេងៗទៀត ឬកន្លែងផ្សេងៗទៀត ការជម្លៀស ឬយ៉ាងណាៗទៀតរបស់ជនជាតិចាមនោះ ខ្ញុំបាទអត់បានដឹងបញ្ហានេះទេបាទ។

[១១:៣១:១៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ឥឡូវនេះ ខ្ញុំបង្ហាញឯកសារមួយទៀតទៅសាក្សី ហើយនិងទៅមេធាវីគាត់ផងដែរ គឺឯកសារ D106/179-- 176 ហើយខ្ញុំគិតថា យើងមិនចាំបាច់បង្ហាញឈ្មោះសាក្សីនេះទេ។ ហើយខ្ញុំគិតថា ព័ត៌មាននេះយើងគ្រាន់តែផ្ដល់ជូនទៅលោក យុន គីម ហើយនិងមេធាវីរបស់គាត់ហ្នឹងជាការគ្រប់គ្រាន់ហើយ។ ហើយខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ឯកសារនេះទៅលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីរដ្ឋបាលតុលាការយកឯកសារដាក់ជូនសាក្សី និងមេធាវីប្រឹក្សារបស់គាត់ពិនិត្យ!

លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ សូមបញ្ជាក់អំពីអត្តសញ្ញាណឯកសារ ដែលលោកមានបំណងក្នុងការសួរដេញដោល-- លើកមកសួរដេញដោលសាក្សីអម្បាញ់មិញនេះ ព្រោះមន្ត្រីរដ្ឋបាលតុលាការស្ដាប់អត្តសញ្ញាណឯកសារដែលលោកបង្ហាញអំមិញមិនច្បាស់ទេ។ សូមបញ្ជាក់ម្ដងទៀត។

[១១:៣២:៤៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លេខ គឺលេខ D166/179 ហើយលេខ ERN ជាភាសាខ្មែរគឺ 00349511 ទៅដល់ 00349520, ERN ជាភាសាបារាំងគឺ 00407022 ដល់ 00407030 និង ERN ជាភាសាអង់គ្លេស 00353491 ដល់ 00353499។ បាទ នេះគឺជាសាក្សីម្នាក់ដែលប្រាប់ថា នៅមុនថ្ងៃទី១៧ មេសា ៧៥ គាត់រស់នៅក្នុងភូមិមួយដែលមានឈ្មោះថា ព្រែកគ្រួច ស្រុកតាំងឃ្មុំ(ស៊ីក) ខេត្តកំពង់ចាម។ បាទស្រុកត្បូងឃ្មុំ គាត់និយាយថា នៅភូមិនោះមានប្រជាជន ១០០នាក់ ហើយនៅក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ --

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម ហ្សង់ម៉ាក ឥឡូវ-- មេធាវីគេឈរ មានមតិជំទាស់ ឬក៏យ៉ាងម៉េចអំពីឯកសារនេះ? ស្ដាប់ការជំទាស់របស់មេធាវីជាមុនសិន មុននឹងលើកបញ្ហាខ្លឹមសារនៃកំណត់ហេតុយកទៅដេញដោលចំពោះសាក្សី។

សូមអញ្ជើញលោកមេធាវី!

[១១:៣៤:៥០]

**លោក អេនឌ្រូ អ៊ីន្ទូហ្វី៖**

ខ្ញុំសូមទោសដែលខ្ញុំត្រូវរំខាន ប៉ុន្តែខ្ញុំគិតថា វា-- គឺយើងគួរតែអនុវត្តនូវគោលការណ៍ ឬក៏សេចក្ដីសម្រេចដែលតុលាការបានសម្រេច តើសាក្សីនេះគាត់មានបញ្ជីនៅក្នុងបញ្ជីឈ្មោះនៃសាក្សីដែលត្រូវកោះអញ្ជើញដែរឬអត់?

**លោក ឌេល លីសាក់៖**

លោកប្រធាន លោក លោកស្រីចៅក្រម សាក្សីនេះមិនមានឈ្មោះនៅក្នុងបញ្ជីនោះទេ។ ប៉ុន្តែខ្ញុំក៏សូមជម្រាបដល់អង្គជំនុំជម្រះ និងមេធាវីផងដែរថា កាលពីសប្ដាហ៍កន្លងមក មេធាវីអន្តរជាតិ នួន ជា បានស្នើសុំចោទសួរសាក្សីមួយអំពីសេចក្ដីចម្លើយតបដែលត្រូវបង្ហាញ។ ហើយពេលនុ៎ង គឺមានការអនុញ្ញាត ដោយផ្អែកទៅលើលក្ខខណ្ឌថា អត្តសញ្ញាណរបស់សាក្សីនោះមិនត្រូវបានបង្ហាញ។ នេះគឺជាការអនុវត្តដែលមិនត្រូវបង្ហាញអត្តសញ្ញាណរបស់សាក្សី នៅក្នុងចម្លើយ។ ហើយអ្វីនេះគឺធ្វើឡើងដោយមេធាវីការពារក្ដី ហើយបន្ទាប់មកគឺមានការអនុញ្ញាត។ ដូច្នេះខ្ញុំមិនប្រាកដថាតើហេតុអ្វីបានគាត់ជំទាស់នោះទេ។ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំចង់ជម្រាបថា សាក្សីរូបនេះមិនមាននៅក្នុងបញ្ជីអ្នកដែលត្រូវកោះអញ្ជើញនោះឡើយ។

[១១:៣៦:០០]

**លោក អេនឌ្រូ អ៊ីន្ទូហ្វី៖**

ការពិតខ្ញុំគ្រាន់តែបញ្ជាក់ថា មិនមែនជាការជំទាស់ទេ គ្រាន់តែជាការស្នើសុំបញ្ជាក់ឲ្យមានការបញ្ជាក់លម្អិត។ ដូច្នេះនេះគឺជាអ្វីដែលខ្ញុំចង់ស្នើព្រោះថានៅចំណុចមួយ គឺថាយើងមិនត្រូវដាក់នូវចម្លើយសាក្សី ទៅលើសាក្សីណាមួយរូប ប្រសិនបើសាក្សីដែលគេលើកចម្លើយដែលគេលើកចម្លើយមកសួរនាំនោះ គឺត្រូវបង្ហាញវត្តមានដើម្បីធ្វើអត្តសញ្ញាណ-- ដើម្បីធ្វើសក្ខីកម្ម។

ដូច្នេះហើយ នេះគឺគ្រាន់តែជាអ្វីដែលខ្ញុំចង់បញ្ជាក់។ ខ្ញុំគ្រាន់តែស្នើសុំឲ្យមានការបញ្ជាក់អំពីអង្គជំនុំជម្រះ ក៏ដូចពីភាគីទាំងអស់។ ខ្ញុំមិនមែនជំទាស់នោះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំក៏មិនជំទាស់ទេ ប៉ុន្តែខ្ញុំសូមមានសំណួរមួយ ពីព្រោះថា លោកចៅក្រម លោកចៅក្រមលោកមិនអាចនឹងលើកយកសាក្សីណាដែលជាសាក្សីដាក់បន្ទុក ឬដោះបន្ទុកទេ។ នេះសម្រាប់អង្គសវនាការ-- សម្រាប់ចៅក្រម។ ប៉ុន្តែភាគីវិញ គឺជ្រើសរើសយកតែសាក្សីដាក់បន្ទុក ឬក៏សាក្សីដោះបន្ទុកសម្រាប់ភាគី ហើយមេធាវីការពារ។ អ៊ីចឹងសម្រាប់សាក្សីនីមួយៗដែលលើកយកមកហ្នឹង យើងមិនគួរសួរតែខាងព្រះរាជអាជ្ញាថាជាសាក្សីរបស់លោកដែរឬអត់? គួរតែសួរថា ជាសាក្សីរបស់ភាគីណាផ្សេងទៀត ដែលបានស្នើឬអត់? ដើម្បីធ្វើបែបនេះបានទាល់តែៗភាគីពិនិត្យមើលផង។

[១១:៣៧:៣៣]

ដូច្នេះហើយ ខ្ញុំចង់ឲ្យសួរទៅភាគីផ្សេងទៀតដែរ ក្រែងលោក្រៅពីព្រះរាជអាជ្ញា មានភាគីណាបានស្នើសាក្សីនេះដែរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ប៉ុន្តែភាគីពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ ពិនិត្យរាល់ឯកសារដែលពាក់ព័ន្ធដែលនៅក្នុងសំណុំរឿង ដែលគ្រោងយកមកដេញដោល តាមវិធីផ្ទាល់ ឬក៏វិធីបច្ចេកទេសណាមួយដែលអាចគ្រប់គ្រងបញ្ហានេះបាន មិនមែនចាំបាច់តែអង្គជំនុំជម្រះសាកសួរគ្រប់តែបញ្ហានោះទេ។ ពីព្រោះជាការសន្សំសំចៃពេលវេលា។ យើងបានប្រឹងប្រែងដល់ដំណាក់កាលនេះ ដោយសារមូលហេតុយើងគ្រប់គ្រងកិច្ចដំណើរការពិភាក្សាដេញដោលឲ្យបានឆាប់រហ័ស និងឲ្យមានប្រសិទ្ធភាពខ្ពស់។

អង្គជំនុំជម្រះបានជម្រាបច្រើនលើកច្រើនសាហើយថ្មីៗនេះ អំពីវិធានការម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងកិច្ចដំណើរការសវនាការឲ្យប្រព្រឹត្តទៅឆាប់រហ័ស និងមានប្រសិទ្ធភាព ហើយជាសិទ្ធិរបស់ភាគីមិនមែនភាគីមានសិទ្ធិដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរហើយ ស្រាប់តែលើកមកស្នើសុំមកអង្គជំនុំជម្រះទេ។

[១១:៣៨:៥១]

ប្រសិនបើខ្លួនយល់ឃើញថា មិនត្រឹមត្រូវ គឺលើកការជំទាស់ គ្រាន់តែឲ្យការជំទាស់ខ្លួនខ្លី ហើយមានសំអាងហេតុជាក់ច្បាស់ប៉ុណ្ណោះ ដើម្បីឲ្យអង្គជំនុំជម្រះមានមូលដ្ឋានពិចារណាសម្រេចភ្លាមៗ។

សូមអញ្ជើញលោកចៅក្រមហ្សង់ម៉ាក!

សូមអញ្ជើញលោកមេធាវី មានបញ្ហាអីទៀតហើយ?

លោកមេធាវី អង្គជំនុំជម្រះសូមរំឭកលោកថា គួរតែត្រូវបានរហ័សរហួននៅក្នុងការលើកឡើងនូវបញ្ហាណាមួយ ចៀសវាងអង្គជំនុំជម្រះសម្រេចរួចហើយ ហើយលោកទើបមកលើកទៀត។ ប្រសិនបើលោកលើកបញ្ហាថ្មី រង់ចាំស្ថានភាពថ្មីសឹមលោកលើក។ ចំពោះបញ្ហាដដែល គឺយើងបានប្រាប់ហើយកាលណាឈានដល់ការសម្រេចហើយ យើងមិនអនុញ្ញាតឲ្យនិយាយទេ។

តើបញ្ហានេះយ៉ាងម៉េចទៅ?

**លោក អាកទួរ វែកកែន៖**

បាទ លោកប្រធាន ខ្ញុំនិយាយហ្នឹងខ្លីទេ ដោយហេតុផលអំពីអ្វីដែលលោកបានលើកឡើងអម្បាញ់មិញនេះ ខ្ញុំគិតថា វាមិនមែនជារឿងអីខុសឆ្គងអីទេដែលថា ឲ្យយើងទាំងអស់គ្នាហ្នឹង មានកាតព្វកិច្ចក្នុងការប្រាប់ដល់ភាគី ជូនដំណឹងដល់ភាគីផ្សេងទៀត មួយថ្ងៃមុន អំពីការសួរសំណួរទៅសាក្សី ហើយអំពីឯកសារដែលយើងចង់ប្រើ។ ហើយនេះជាបន្ទុករបស់តុលាការ ហើយទាំងអស់នេះវាអាច ឲ្យយើងធ្វើដំណើរការនីតិវិធីទៅមុខលឿន ហើយដោយប្រសិទ្ធភាពក្នុងការសួរសំណួរទៅសាក្សី ចំពោះភាគីអ្នកការពារក្តី។ នេះជាការកត់សម្គាល់របស់ខ្ញុំលោកប្រធាន។

[១១:៤០:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ដើម្បីឆ្លើយតបទៅនឹងអ្វីដែលតបអំមិញហ្នឹង គឺថា កាតព្វកិច្ចរបស់ភាគីមិនដូចនឹងកាតព្វកិច្ចចៅក្រមនោះទេ ហើយខ្ញុំពេញចិត្តដែលថា ភាគី នួន ជា នោះត្រូវគោរពនីតិវិធីទាំងអស់ ហើយអានេះក៏ជា-- ភាគីទាំងអស់ត្រូវគោរពដែរ នេះជាដំណឹងល្អសម្រាប់យើងទាំងអស់គ្នា។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ត្រឡប់មកនិយាយអំពីសក្ខីកម្មរបស់បុគ្គលរូបនេះ ដែលនៅឆ្នាំ១៩៧៥ ដែលគាត់រស់នៅភូមិមួយ ដែលមានប្រជាជន១០០នាក់ គឺភូមិចាម។ សាក្សីរូបនេះ បាននិយាយថា គ្រួសាររបស់គាត់ត្រូវបានជម្លៀសទៅភូមិសំបូរ ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ។ ហើយគាត់បញ្ជាក់ថា ប្រជាជនផ្សេងទៀត ត្រូវបញ្ជូនទៅខេត្តផ្សេងទៀត ទៅក្រចេះ បាត់ដំបង និងខេត្តដទៃទៀត។ ហើយគាត់បញ្ជាក់ផងដែរថា ទាក់ទងទៅនឹងលក្ខខណ្ឌជីវភាពនៅសំបូរ គឺនៅទំព័រ៥ ជាសំណៅភាសាបារាំង។ “នៅពេលដែលយើងទៅដល់ស្រុកសំបូរ យើងត្រូវបានអនុញ្ញាតឲ្យរស់នៅប្រជាជនមូលដ្ឋាន នៅក្នុងភូមិ ហើយគាត់គេសម្រេចថា គ្រួសារនីមួយៗត្រូវតែរស់នៅជាមួយប្រជាជនមូលដ្ឋាន។ យើងរស់នៅក្រោមផ្ទះប្រជាជនមូលដ្ឋាន ហើយមានអ្នកស្លៀកឯកសណ្ឋានខ្មៅ ហើយមានក្រមា ហើយនិងស្បែកជើងកង់ឡានបាននាំយើងទៅផ្ទះនោះ”។

[១១:៤២:៤២]

ហើយនឹងក្រោយមកទៀត មាននិយាយថា៖ “យើងចាប់ផ្ដើមធ្វើការចាប់ពីម៉ោងបីព្រឹក រហូតដល់ម៉ោងដប់មួយថ្ងៃ មុននឹងពេលសម្រាកដើម្បីហូបអាហារ។ ហើយយើងចាប់ផ្ដើមពីម៉ោងមួយថ្ងៃត្រង់ ប្រាំល្ងាច សម្រាកហូបអាហារម្ដងទៀត។ បន្ទាប់មកទៀត យើងចាប់ផ្ដើមជាន់ស្រូវបន្តទៀតពីម៉ោងប្រាំមួយ រហូតដល់ម៉ោងប្រាំបួនយប់ ទើបបានសម្រាកគេង”។ បាទ ត្រង់ចំណុចនេះ លោកសាក្សី តើហេតុការណ៍ទាំងអស់នេះវាសមស្របនឹងការចងចាំរបស់លោកដែរឬទេ? ឬក៏វាខុសពីការចងចាំរបស់លោក?

**លោក យុន គីម៖**

**ឆ៖** ពាក់ព័ន្ធនឹងការជម្លៀសជនជាតិខ្មែរអ៊ីស្លាម ទៅនៅឃុំសំបូរ ខ្ញុំអត់បានដឹងថា ពីពេលណាទេ។ នៅពេលដែលខ្ញុំទៅរស់នៅឃុំសំបូរនេះ គឺប្រជាជនហ្នឹងគឺថា រស់នៅឡូកឡំគ្នាដូចជា មិនមានបែងចែកមិនមានអីទេ។ ឯការងារ ៗជំនាន់មុនខ្ញុំទៅដល់ ខ្ញុំក្ដាប់អត់បានទេ មិនដឹងជាមានការងារធ្ងន់ធ្ងររហូតដល់កណ្ដាលយប់ទៅធ្វើម៉ោងបី ម៉ោងបួន អ៊ីចឹង បួនភ្លឺ។ នេះខ្ញុំមិនបានដឹងបញ្ហានេះទេ ពោលគឺពាក់ព័ន្ធនឹងបងប្អូនអ៊ីស្លាមនេះ។ បាទ ខ្ញុំសូមមានមិតប៉ុណ្ណឹង។

[១១:៤៤:៣៣]

**ស៖** បាទ ជាទំនាក់ទំនងជាមួយសំណួរនេះ ខ្ញុំគ្រាន់តែចង់កត់សម្គាល់ថា មាននៅក្នុងសំណុំ

រឿង គឺថា ឯកសារ E3/154 គឺជាទូរលេខមួយដែលមានចំណងជើងថា-- ទូរលេខ១៥ ដែលផ្ញើជូនទៅបងប៉ុល ជាទីស្នេហា ហើយនិងចម្លងជូន បងនួន, បងនឿន, បងហាក់, បងយ៉ែម និងទុកឯកសារ។ ហើយអ្នកចុះហត្ថលេខីហ្នឹង គឺ ឈុន។ នៅក្នុង-- ហើយតេឡេក្រាមនេះ ចុះថ្ងៃនៅទី៣០ ខែ១១ ៧៥ ដែលនិយាយអំពីការជម្លៀសប្រជាជនចាម ហើយជាការជម្លៀសទ្រង់ទ្រាយធំ ពីព្រោះថាមានដល់ទៅ ១៥០០នាក់ ពីភូមិភាគបូព៌ា។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំអស់សំណួរសួរទៅសាក្សីទៀតហើយ លោកប្រធាន។

[១១:៤៥:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ ដល់ពេលតិចតួច មុនពេលអាហារថ្ងៃត្រង់ ហើយទំនងជាការប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ក៏ដូចជាមិនសមរម្យដែរ ដោយសារពេលវេលាខ្លី។ សាក្សី យើងមានសំណួរមួយចំនួន ដែលមានបំណងចង់សួរលោក ដោយសារលោកជាបុគ្គលសំខាន់ដែលធ្លាប់កាន់ការជាអាជ្ញាធរសម័យកម្ពុជាប្រជាធិបតេយ្យថ្នាក់មូលដ្ឋាន។ ជាលេខាឃុំ ជាប្រធានសហករណ៍ ហើយនិងក៏ជាប្រធានការដ្ឋាន បេ-៣ ដែរ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សំណួរមួយថា សួរថាលោកធ្លាប់បានទទួលនូវមធ្យោបាយផលិតកម្មពីថ្នាក់លើដែរឬទេ? មធ្យោបាយផលិតកម្ម ដូចជា ចប ប៉ែល គ្រឿងបន្លាស់ នង្គ័ល ឬក៏គ្រឿងបន្លាស់ផ្សេងទៀត ដែលបម្រើដល់វិស័យកសិកម្ម តើលោកធ្លាប់ដែលបានទទួលពីថ្នាក់លើដែរឬទេ?

[១១:៤៧:១៥]

**លោក យុន គីម៖**

**ឆ៖** ពាក់ព័ន្ធសម្រាប់បង្កបង្កើនផល មានចប មានផាល មានប៉ែល មានស្លាបនង្គ័លអី អាហ្នឹងជាការផ្តល់ឲ្យពីថ្នាក់ស្រុក។ តំបន់គឺផ្តល់ឲ្យស្រុក។ ស្រុកផ្តល់ឲ្យឃុំ ទៅតាមសំណូមពរដែលមូលដ្ឋាននីមួយៗស្នើសុំ។ ហើយបើពិសេស ចប ក្រោយពីរំដោះឆ្នាំ៧៥នេះ ហើយកាលពីមុន មុនរំដោះគឺលំបាកដែលចប ខ្វះចបធ្វើការងារ។ ដល់ក្រោយពីរំដោះឆ្នាំ៧៥ ចបហ្នឹងសំបូរ អត់ៗខ្វះទេ សំបូរមែនទែន។ បាទ ខ្ញុំសូម-- ដោយឡែក ដូចខ្ញុំនៅការដ្ឋានអ៊ីចឹង នៅការដ្ឋាន ប-៣ អ៊ីចឹង ចប គេផ្តល់ឲ្យគ្រប់ដៃរបស់

យុវជន យុវនារី។ ឯប៉ែល មានចំនួនសម្រាប់ជីកប្រឡាយ ជីអីអ៊ីចឹង។ ដោយឡែក នង្គ័ល គេផ្តល់ស្លាបផ្តល់ផាលឲ្យដូចគ្នាអ៊ីចឹងដែរ។ ឯឧបករណ៍ផ្សេងៗទៀត ដូចជាកាំបិត ពូថៅ គឺយើងដោះស្រាយ។ បាទ ដូចខ្ញុំបានជម្រាបហើយ ខ្ញុំដោះស្រាយតាមរយៈសុំជាងដែកមក យកជាងដែកហ្នឹង មកផលិតនៅហ្នឹងកន្លែងតែម្តង ដោយសុំឲ្យថ្នាក់ស្រុកហ្នឹង គឺជួយផ្តល់ដែកវ៉ែកាំបិត និងសម្រាប់ធ្វើពូថៅ។ នេះ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១១:៤៨:៥៤]

**ស៖** អរគុណ។ ក្រៅពីមធ្យោបាយផលិតកម្មមួយចំនួន ដែលលោកបានរៀបរាប់អម្បាញ់មិញនេះ។ ចុះមានសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃផ្សេងទៀត ដល់ប្រជាពលរដ្ឋ ដូចជាសម្លៀកបំពាក់ ឬក៏ក្រណាត់ក្រមាអីជាដើម តើនៅកន្លែងដែលលោកកាន់កាប់ទាំងបីកន្លែង ក្នុងនាមជាប្រធានឃុំ ជាប្រធានសហករណ៍ ក៏ដូចជាប្រធានការដ្ឋាន បេ-៣ នោះ តើលោកទទួល ដែលបានទទួលដែរឬទេ? ហើយទទួលពីណាមកសម្ភារៈប្រើប្រាស់ទាំងអស់នោះ?

**ឆ៖** សម្ភារៈប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋពេលនោះ គឺពិសេសសម្លៀកបំពាក់។ សម្លៀកបំពាក់នេះ មានរបប គឺមួយឆ្នាំផ្តល់ក្រណាត់ឲ្យសម្រាប់ពីរកំផ្លេម្នាក់ បាទ ហើយនៅក្នុងសហករណ៍នេះគឺមានក្រុមអ្នកកាត់ដេរ។ ក្រុមអ្នកកាត់ដេរហ្នឹង ទទួលរ៉ាប់រងគឺដេរខោអាវជូនប្រជាពលរដ្ឋ។ ឯក្រមាដូចជាខ្ញុំនៅក្នុងសហករណ៍អ៊ីចឹង មានកម្មវិធីត្បាញ មានក្រុមអ្នកត្បាញ ត្បាញក្រមាហ្នឹងសម្រាប់ចែកជូនបងប្អូននៅក្នុងសហករណ៍ហ្នឹង។ ខ្ញុំនៅវត្តនះក៏មាន នៅសំបួរក៏មានអ៊ីចឹងដែរ។

[១១:៥០:២១]

ដោយឡែកដែលនៅការដ្ឋាន ប-៣ អត់មានកន្លែងផលិតក្រមាទេ ឯសម្លៀកបំពាក់ក៏គេចែកតាមហ្នឹងដែរ ដោយស្រុកផ្តល់សម្លៀកបំពាក់ឲ្យ។ ដោយឡែកមានក្រមានេះ គឺស្រុកក៏ផ្តល់ឲ្យដែរ អត់មានត្បាញខ្លួនឯងទេ ពីព្រោះកម្លាំងហ្នឹងទើបចូលទៅបាន គិតទៅបានប្រាំមួយខែហ្នឹងរត់ បាទ រត់តែម្តង។ នេះខ្ញុំសូមមានយោបល់ប៉ុណ្ណេះ។

**ស៖** បាទ អរគុណ។ តាមសក្ខីកម្មរបស់លោកប៉ុន្មានថ្ងៃនេះ លោកបានផ្តល់សក្ខីកម្មអំពីការអនុវត្តនូវផែនការការងារដែលថ្នាក់លើដាក់ចុះ។ នៅក្នុងនោះសំណួរសួរថា តើលោកធ្លាប់បានទទួលការអនុវត្តនូវគោលនយោបាយផែនការថ្នាក់លើឲ្យប្រឹងប្រែងធ្វើផលិតកម្មស្រូវ ក្នុងមួយហិកតាឲ្យបានបីតោនដែរឬទេ? ហើយប្រសិនបើមាន តើផែនការដូច្នេះហ្នឹងចាប់ផ្តើមយកមកអនុវត្តចាប់ពីពេលណាមក?

[១១:៥១:៣៦]

**ឆះ** នៅក្នុងរបប ប៉ុល ពត នេះគឺយើងអនុវត្តរបបប្រលងប្រណាំងនៅឆ្នាំ១៩៧៦។ នេះជាដំណាក់កាលទីមួយ ដែលឲ្យសហករណ៍មួយៗសម្រេចបាន១បីតោនក្នុងមួយហិកតា។ បាទនៅពេលនោះខ្ញុំក៏បានរួមចំណែកប្រលងប្រណាំងជាមួយនឹងសហករណ៍ផ្សេងទៀតដែរ។ ប៉ុន្តែការប្រលងប្រណាំងនេះ គឺយើង សំខាន់គឺយើងដោះស្រាយជី យើងផលិតជីអាចម៍គោ អាចម៍ក្របីយើងហ្នឹង គឺជីធម្មជាតិហ្នឹង លក្ខណៈជីកំប៉ុកហ្នឹង បាទដើម្បីយកទៅដាក់ស្រែ។ អ៊ីចឹងឃើញថានៅឆ្នាំនោះលទ្ធផលមួយខេត្តក្រចេះ ស្រុកទាំងបីហ្នឹង គឺឃុំខ្ញុំលេខមួយ។ ប៉ុន្តែខ្ញុំអត់បានបីតោនទេ ព្រោះស្រូវខ្ញុំនៅឆ្នាំនោះខ្ញុំបាន១២៦ថាំង ប៉ុន្តែខ្ញុំរាយការណ៍ជូនទៅខេត្តហ្នឹងតែមួយរយ-- អ៎! ជូនទៅស្រុកហ្នឹងតែ១១៣ថាំងទេ។ ពីព្រោះអត់ដល់ទៅ-- អត់អះអាងថាបានបីតោនទេ ឲ្យស្មើរ។ ស្មើរព្រោះខ្ញុំគិតថា បើខ្ញុំរាយការណ៍១២៦ថាំងទៅ ខ្ញុំខាតច្រើនណាស់ ពីព្រោះបើខ្ញុំរាយការណ៍១១៣ ខ្ញុំចំណេញបីដណ្តប់ថាំងក្នុងមួយហិកតា។ អ៊ីចឹងអាហ្នឹងត្រៀមហូបបាយបានហើយ។ បាទ ខ្ញុំសូមអស់មតិ។

[១១:៥៣:១៦]

**សះ** បាទ អរគុណ។ លោកមានដែលបានទទួលផែនការនៅក្នុងការបញ្ជូនចេញនូវផលិតផលដែលផលិតបានប្រចាំឆ្នាំទៅឲ្យតំបន់ផ្សេង ទៅមូលដ្ឋានផ្សេង ឬក៏បញ្ជូនទៅឲ្យថ្នាក់លើដែរឬទេ? យើងនិយាយត្រឹមតែផលិតផលស្រូវ ដែលបំណងអំមិញធ្វើឲ្យបានតាមផែនការបីតោនក្នុងមួយហិកតា។ ឥឡូវថាធ្វើបានហើយ ឬក៏កំពុងតែអនុវត្តផែនការ។ សំណួរថា តើផលិតផលដែលធ្វើបានហើយនេះ តើមានធ្លាប់មានបានត្រូវថ្នាក់លើបញ្ជាឲ្យបញ្ជូនចេញទៅផ្គត់ផ្គង់កន្លែងតំបន់ផ្សេងទៀត ឬក៏ប្រគល់មកឲ្យថ្នាក់លើដែរឬទេ?

**ឆះ** ពាក់ព័ន្ធនឹងបញ្ហាស្រូវ កន្លងមកនេះខ្ញុំនៅសហករណ៍វឌ្ឍនៈនេះ គឺបានស្រូវដូចខ្ញុំបានជម្រាបជូនអ៊ីចឹង លទ្ធផលបានល្អប្រសើរ។ ប៉ុន្តែពេលដែលខ្ញុំនៅនេះ អត់ទាន់មានបានយកស្រូវនេះចេញទៅណាទេ ខ្ញុំត្រូវផ្លាស់ទៅនៅឃុំសំបូរ។ ហើយពេលដែលខ្ញុំនៅឃុំសំបូរនោះ ស្រូវក៏អត់មានដែលបានបញ្ចេញទៅណា ប៉ុន្តែមានម្តងនោះគឺខាងស្រុកគេឲ្យចុះវាល់ស្រូវតាមជង្រុក។ ហើយដល់ចុះទៅដល់វាល់ស្រូវតាមជង្រុក អ្នកទៅវាល់ហ្នឹងខាងសេដ្ឋកិច្ចពីរនាក់ទៅ ទៅជាមួយនឹងខាងសន្តិសុខ។ រួចដល់ខ្ញុំបានបញ្ជាក់ប្រាប់អ្នកនុ៎ងថា យករបាយការណ៍ខ្ញុំបណ្តោយទៅ មិនចាំទៅវាល់ទេ។ ព្រោះបើទៅវាល់ក៏គ្មានហួសពីហ្នឹងដែរ វានៅដដែលហ្នឹងទេ។ ហើយពួកនោះក៏អត់វាល់ អត់អីទៅ យកតាមរបាយការណ៍

ខ្ញុំទៅ ក៏អត់មានបញ្ហាពាក់ព័ន្ធនឹងដកហូតស្រូវអង្ករទៅណាដែរ។ ព្រោះបញ្ញើខ្ញុំ ខ្ញុំគិតរួចស្រេចហើយ គិតថាសម្រាប់ប្រជាជនហូបប៉ុនណា រាយការណ៍ប៉ុណ្ណឹងទៅ យើងបានប៉ុណ្ណឹងបានហើយ។ ព្រោះដើម្បីទប់ស្កាត់នូវផលវិបាកដែលនឹងជួប។

ឯ ក្រោយខ្ញុំចេញពីឃុំវត្តស្លនៈមក ខ្ញុំក៏ដឹងថានៅឃុំវត្តស្លនៈនោះ គេទៅយកស្រូវចង់អស់ បាទគេវាល់ចង់អស់ពីជង្រុកនោះ។ គេ-- ដូចថាគេលទុកឲ្យប៉ុនណា ទុកប៉ុណ្ណឹងហើយ គេមិនហ៊ានយកចេញ។ ឯកន្លែងខ្ញុំ អត់ដែលមានឃើញយកចេញដែរ។ ខ្ញុំសូមអស់មតិ។

[១១:៥៦:១០]

**ស៖** អរគុណ ហើយយើងចង់បានព័ត៌មាននេះ ឥឡូវលោកបានឆ្លើយហើយ ប៉ុន្តែមិនទាន់ច្បាស់លាស់។ សូមលោកបង្ហាញឲ្យកាន់តែច្បាស់លាស់ថែមទៀត នូវស្ថានភាពខុសគ្នាព្រោះលោកបានផ្តល់សក្ខីកម្មហើយថា នៅពេល ខណៈពេលដែលលោកធ្វើការងារជាលេខាឃុំ ឬក៏ជាប្រធានសហករណ៍ ឬក៏ប្រធានការដ្ឋាន បេ-៣ គឺលោកតែងតែផ្តល់ជីវភាពហូបចុកគ្រប់គ្រាន់ ជាការហូបបាយដល់ប្រជាពលរដ្ឋ ឬក៏កម្លាំងពលកម្មដែលនៅក្រោមឱវាទការគ្រប់គ្រងរបស់លោក។ ប៉ុន្តែកន្លែងផ្សេង គឺហូបបបរ។ ហើយអម្បាញ់មិញ លោកបានបញ្ជាក់ហើយអំពីបញ្ហានេះ។ សំណួរសួរឲ្យសូមបញ្ជាក់ឲ្យបានច្បាស់ទៀតអ្វីដែលលោកដឹង ថាតើតំបន់ផ្សេងទៀតដែលជាប់ៗលោកដែលមានការហូបខ្វះខាតនោះ ហូបបបរ ធ្វើការច្រើន តើវាមានមូលហេតុអីដែលនាំឲ្យប្រជាពលរដ្ឋហូបបបរ បើគាត់ធ្វើការច្រើន ហើយផលិតផលនៅម្តុំតំបន់ក្បែរៗគ្នា បើវាមានផលអន្តរាយដោយសារគ្រោះមហន្តរាយផ្សេងៗ ទំនងជាទាំងអស់គ្នា? តើវាមានហេតុផលយ៉ាងម៉េចទៅ ដែលនាំឲ្យតំបន់ផ្សេង-- សហករណ៍ផ្សេងទៀត ឬក៏ឃុំផ្សេងទៀតជាប់តំបន់ដែលលោកគ្រប់គ្រងហ្នឹង បែរជាមានការខ្វះខាតហើយហូបបបរ?

[១១:៥៧:៤១]

**ឆ៖** ពាក់ព័ន្ធនឹងបញ្ហាហូប អ្វី នៅកន្លែងខ្លះមានការខ្វះខាតក្នុងការហូបហ្នឹង ខ្ញុំសូមលើកឧទាហរណ៍មួយ។ កាលពីខ្ញុំនៅឃុំវត្តស្លនៈ ឃុំមួយទៀតនៅក្នុងជ្រោយបន្ទាយ ជាប់នឹងឃុំខ្ញុំរស់នៅ។ ឃុំជ្រោយបន្ទាយនេះនៅក្នុងភូមិភាគកណ្តាល។ ភូមិនេះគឺមានការលំបាក លំបាកមែនទែនក្នុងការស៊ីចុកបាទ។ កន្លងទៅ ដល់ឃើញលំបាកអីចឹងខ្លាំងពេក ខ្ញុំធ្លាប់ផ្តល់ដំឡូងមីឲ្យ ដែលពួកខ្ញុំដាំលើកោះព្រំប្រទល់ហ្នឹងឲ្យៗទាំងកោះតែម្តង ឲ្យបងប្អូនយើងមកគាស់ទៅហូប។ រួចចេកអី បងប្អូនយើងមករកហ្នឹង អត់ឲ្យឈ្លបអីឃាត់ឃាំងទេ ចែកចាយ ដូចជាផ្លែឈើអីចឹង។ ខ្ញុំឃើញខាងហ្នឹង ខ្ញុំមិនដឹងមូល

ហេតុយ៉ាងម៉េចទេ បានជាគេតឹងរ៉ឹងខ្លាំងម្ល៉េះនៅខាងនុ៎ង។ ដីស្រែមានដូចគ្នា ស្ទីមានដូចគ្នា អាហ្នឹងភូមិភាគកណ្តាល។ ឯដោយឡែក ខ្ញុំទៅនៅសំបូរ ដូចជាអត់មានបញ្ហាចោទប៉ុន្មានទេក្នុងស្រុកសំបូរ បើគេហូបបបរ ក៏បបរហ្នឹងសមរម្យដែរ។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹង ពាក់ព័ន្ធនឹងបញ្ហាហូបចុក។

**ស៖** លោកឆ្លើយមុននេះអំមិញហ្នឹងថា មានការវាល់ វាល់ ឬក៏ថ្លឹងឡើងវិញនូវស្តុកស្រូវនៅក្នុងឃ្លាំងនៃសហករណ៍នីមួយៗ ឬក៏ឃុំនីមួយៗ។ ហើយលោកលាក់ទូរលេខ ដើម្បីបន្ថយទូរលេខដើម្បីឲ្យផលិតផលហ្នឹង វានៅអាចបម្រើដល់តម្រូវការប្រចាំថ្ងៃចំពោះប្រជាពលរដ្ឋនៅក្រោមឱវាទលោកបាន ប៉ុន្តែកន្លែងផ្សេងអត់បានទេ ត្រូវគេដកចេញ។ សំណួរសួរថា លោកដឹងថាកន្លែងផ្សេងដែលគេដកចេញនេះ គេដកចេញទៅឯណា?

[១១:៥៩:៤១]

**ឆ៖** ដូចខ្ញុំបានជម្រាបបញ្ជាក់ជូនអំមិញហើយថា នៅឃុំវត្តល្អនៈស្រូវឆ្នាំហ្នឹងបាន ឆ្នាំ៧៦ហ្នឹងបានលើសពីបីតោន។ ឯជង្រុកស្រូវនៅវត្តល្អនៈ មានតែជង្រុកធំៗតាមភូមិ ភូមិមួយមានជង្រុកៗ។ អ៊ីចឹងគេអាចវាល់ គេអាចវាស់ គេអាចដឹង ដល់អ៊ីចឹងគេដកចេញមួយចំណែកធំ ប៉ុន្តែការដកចេញនេះ ខ្ញុំអត់បានដឹងគេដកយកទៅណាទេ។ គ្រាន់តែដឹងថា នៅវត្តល្អនៈនេះ គេយកស្រូវអស់ច្រើនហើយ។ អ៊ីចឹងប្រជាជនបានត្រឹមកម្រិតហូបបបរ ក្រោយពីខ្ញុំចេញទៅ។ នេះខ្ញុំសូមអស់យោបល់ប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ សំណួរចុងក្រោយគឺ តើលោកមានបាន ដែលបានដឹងព័ត៌មានអំពីពាណិជ្ជកម្ម ព្រោះលោកបានប្រាប់ហើយថា មានសមាជិកតំបន់ទទួលបន្ទុកពាណិជ្ជកម្ម ឬក៏សមាជិកស្រុកទទួលបន្ទុកពាណិជ្ជកម្ម។ តើពាណិជ្ជកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គេធ្វើពាណិជ្ជកម្មទៅតាមរបៀបយ៉ាងម៉េចដែរ? សកម្មភាពពាណិជ្ជកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១២:០១:០៩]

**ឆ៖** សកម្មភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះគឺ នៅពេលដែលចាយលុយមុនយើងរំដោះឆ្នាំ៧៥ មានជាខ្សែសង្វាក់របស់គេ។ នៅក្នុងឃុំក៏មានពាណិជ្ជកម្មរបស់ឃុំ។ ស្រុកក៏មានពាណិជ្ជកម្មរបស់ស្រុក។ អីវ៉ាន់ដែលយកមកនេះគឺ ដឹក-- ស្រុកទៅដឹក-- ឃុំទៅដឹកពីស្រុកយកមកសម្រាប់ចែកជូនប្រជាពលរដ្ឋដូចជា អំបិល ដូចជាថ្នាំសង្កូវខ្លះ ដូចជា បញ្ហាចាំបាច់មួយចំនួនដែលពាក់ព័ន្ធនឹងជីវភាពរបស់ប្រជាជនហ្នឹង នៅស្រុកក៏អ៊ីចឹងដែរ។ ឯពេលនោះគឺទីផ្សារអីវាចង់ វាមានការលំបាក ដល់មកឆ្នាំ៧៤ ហ្នឹងទីផ្សារនៅឯកជនហ្នឹងចង់រលាយបណ្តើរៗហើយ។ អ៊ីចឹងគឺមានតែតាមរយៈស្រុកហ្នឹង។

តាមរយៈពាណិជ្ជកម្មខេត្តហ្នឹងដែលលុយអីនៅចាយ គឺប្រជាជនចាយអត់បានទេ។ ឯតាមរយៈពាណិជ្ជកម្មហ្នឹងគេអាចចាយបាន ព្រោះគេចេញចូល គេមានទំនាក់ទំនងយ៉ាងម៉េចខ្ញុំអត់បានដឹង។ បាទ គ្រាន់ដឹងថា ស្រុកគេមានពាណិជ្ជកម្ម ហើយឃុំក៏យកបន្តមកទៀត។ នេះ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១២:០២:៤១]

**ស៖** លោកដែលបានទទួលព័ត៌មានពីប្រភពណាមួយ ព្រោះលោកបានលើកឡើងថា មានអ្នកស្គាល់លោកនោះ លោកស្គាល់មនុស្សច្រើនណាស់នៅក្នុងជួរគណៈស្រុក ឬក៏គណៈតំបន់៥០៥ ហើយតើលោកបានទទួល ដែលបានទទួលដំណឹងពីការធ្វើពាណិជ្ជកម្ម ការនាំស្រូវចេញ ស្រូវអង្កររបស់កម្ពុជាប្រជាធិបតេយ្យចេញទៅលក់នៅឯក្រៅប្រទេសដែរទេ?

**ឆ៖** ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មចេញក្រៅស្រុក តែចេញក្រៅខេត្តនេះ ក៏ខ្ញុំអត់បានដឹងដែរ។ ខ្ញុំបានដឹងតែត្រឹមក្របខ័ណ្ឌដែលដូចថា គេយកចេញពីមូលដ្ឋាន ដូចជាចេញពីវត្តនះអឺចឹង ដឹងតែថាគេយកចេញ ប៉ុន្តែយកពីហ្នឹងទៅទៀត ទៅណាក៏ខ្ញុំអត់បានដឹងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណច្រើន។ ឥឡូវនេះដល់ពេលសមល្មមសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅកន្លែងបម្រុងទុកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលម៉ោងមួយសាមសិបនាទី។

[១២:០៤:១០]

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោម ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការនេះវិញនៅវេលាម៉ោង-- ឲ្យបានមុនម៉ោងមួយសាមសិបនាទី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម ហើយយើងបានស្នើ ដែលខ្ញុំបានលើកពីព្រឹកម្សិលមិញ គឺ E209 គឺតាមវិធាន៨៧ ដើម្បីដាក់ភស្តុតាងថ្មីជូនសាក្សីនេះដើម្បីសួរផ្ទាល់គាត់។ ដូច្នេះ តើអង្គជំនុំជម្រះបានសម្រេចហើយឬនៅបាទ?

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៤:២០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនចាំបាច់ឆ្លើយតបទៅនឹងសំណើសុំរបស់លោកមេធាវី ដែលបានដាក់នោះទេ ព្រោះឯកសារដែលលោកមេធាវីស្នើសុំដាក់នោះ គឺមិនមែនជាឯកសារភស្តុតាងថ្មីទេ។ គឺជាសេចក្តីសម្រេចទៅលើបំពេញកិច្ចដំណើរការនីតិវិធី ដោយសហចៅក្រមស៊ើបអង្កេត។ ទំនងជាមេធាវីអាចមានការយល់ច្រឡំលើបញ្ហានេះ ហើយដីកា និងឯកសាររបស់តុលាការ ដូចជា ដីកាចាត់តាំងឲ្យស៊ើបសួរជំនួសជាដើមនុ៎ង វាមិនមែនជាភស្តុតាងនោះទេ ហើយឯកសារទាំងអស់នេះ បើសិនបើដាក់ដេញដោលក៏មិនមានតម្លៃជាភស្តុតាងដែរ។

ដើម្បីបញ្ជាក់បន្ថែម ឲ្យកាន់តែច្បាស់ហ្នឹង អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅលោកចៅក្រមហ្សង់ម៉ាក ដើម្បីឆ្លើយបញ្ជាក់បញ្ហានេះឲ្យបានច្បាស់ថែមទៀត។

[១៣:៣៥:៤៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា អ្វីដែលលោកប្រធានបាននិយាយនេះ គឺច្បាស់លាស់

ហើយ។ ខ្ញុំគិតថាអ្វីដែលយើងអាចទទួលយកបាននោះ គឺថា សេចក្ដីសម្រេចដែលលោកបានយោងនោះ លោកមេធាវី វាមិនមែនជាភស្តុតាងទេ។ ដូច្នេះ វាមិនគោរពទៅតាមវិធាន៨៧ នោះទេ។ វិធាន៨៧ នេះ គឺអនុវត្តទៅលើការបង្ហាញភស្តុតាងថ្មី ក៏ប៉ុន្តែអង្គជំនុំជម្រះនឹងវាយតម្លៃថា តើសំណួរដែលផ្អែកទៅលើ សេចក្តីសម្រេចដែលលោកយោងនោះ ពាក់ព័ន្ធ ឬក៏មិនពាក់ព័ន្ធនោះ យើងនឹងពិចារណាទៅតាមពេល ក្រោយ។ ដូច្នេះ លោកប្រធានមានសិទ្ធិក្នុងការដឹកនាំការសួរសំណួរ ហើយនិងកាត់ផ្តាច់ចំពោះសំណួរ ទាំងឡាយណា ដែលមិនពាក់ព័ន្ធនៅក្នុងសវនាការ។ ក៏ប៉ុន្តែពិតណាស់ គឺថាលោកអាចយោងទៅលើ ឯកសារនោះបាន ពីព្រោះថា នេះជាកិច្ចនៃនីតិវិធី។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណចំពោះការបំភ្លឺ ប៉ុន្តែយើងខ្ញុំមិនយល់ស្របទេ ប៉ុន្តែយើងយល់ស្របគឺថា អ្វីដែល យើងយកមកប្រើ និងសួរផ្ទៀងនេះគឺថា វាមិនមែនភស្តុតាងនោះទេ។ ប៉ុន្តែយើងនឹងគោរពតាមនីតិវិធី ដែលអង្គជំនុំជម្រះ បានសម្រេចផ្អែកទៅលើវិធាន៨៧(៤)--

**ប្រធានអង្គជំនុំ៖**

យើងឲ្យផ្តល់វេទិកាជូនទៅលោកតាំងសំណួរ ដេញដោលចំពោះសាក្សី។ យើងមិនឲ្យលោកធ្វើ អត្ថាធិប្បាយអ្វីទេ។ អង្គជំនុំជម្រះបានសម្រេចរួចហើយ។ ចូរលោកចងចាំថា តុលាការមិនផ្តល់ឱកាស ឲ្យលោកធ្វើសេចក្តីថ្លែងការណ៍អី ឆ្លៀតឱកាសនៅក្នុងកិច្ចដំណើរការនេះ ធ្វើសេចក្តីថ្លែងការណ៍អី ផ្សេងៗទៀតទេ។

[១៣:៣៧:៣៤]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណ។ ខ្ញុំនឹងមិនធ្វើដូច្នោះទេ ខ្ញុំគ្រាន់តែបញ្ជាក់ឲ្យមានកំណត់ត្រាតុលាការ ផ្អែកទៅលើ ការសម្រេចរបស់តុលាការនេះ។ ខ្ញុំមិនអាចនឹងសួរដេញដោលសាក្សីនេះ តាមគំនិតនេះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ប្រហែលជាលោកមិនយល់ទេ។ តុលាការមិនទាន់បានសម្រេចថា លោកមិនអាចយោងទៅរក ឯកសារនេះទេ។ លោកអាចយោងទៅរកឯកសារនេះបាន ដូចដែលបានបញ្ជាក់ មិនមែនជាភស្តុតាងទេ

ឯកសារនេះ។ នេះគឺជា ដីការបស់សហចៅក្រមស៊ើបអង្កេត។ ដូច្នេះ លោកអាចយោងទៅរកឯកសារនោះបាន។ តើលោកច្បាស់ទេលោកមេធាវី? ទីពីរ លោកប្រធាន នឹងសម្រេចប្រសិនបើលោកតាំងសំណួរទៅសាក្សី ផ្អែកទៅលើដីកា នៃសហចៅក្រមស៊ើបអង្កេតនេះ។ ប្រសិនបើមានចំណុចណា ដែលពាក់ព័ន្ធទាក់ទងទៅនឹងសំណួររបស់លោក។ តើលោកច្បាស់ទេលោកមេធាវី?

[១៣:៣៨:៤៥]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំមិនច្បាស់ទេតាមពិត។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ដូច្នេះគឺថា លោកអាចធ្វើតាមអ្វីដែលលោកចង់។ តើឥឡូវលោកចង់តាំងសំណួរ ឬអត់?

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សំណួររបស់ខ្ញុំគឺថា ដីកានោះ គឺមានអង្គហេតុ ហើយអង្គហេតុនោះអាចជាភស្តុតាង។ នេះហើយដែលខ្ញុំច្បាស់ ប៉ុន្តែក្នុងករណីនេះ បើតុលាការមិនសម្រេចទេ ខ្ញុំមិនសួរទេ ខ្ញុំនឹងជូនវេទិកាទៅសហសេវិករបស់ខ្ញុំ គឺទាក់ទងទៅនឹងបញ្ហាដែលទាក់ទងទៅនឹងការជម្លៀសប្រជាជន ចេញពីទីក្រុងភ្នំពេញបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។

ខ្ញុំជឿជាក់ថា យើងបានជួបបញ្ហានេះពីមុនហើយ មុនពេលដែលឲ្យជនជាប់ចោទ ធ្វើយោបល់។ លោក នួន ជា គាត់ត្រូវរងការសួរដេញដោលពីបញ្ហានេះ ប៉ុន្តែមេធាវីមិនគប្បី ប្រើពេលសួរសាក្សីនេះ ដើម្បីឲ្យកូនក្តីខ្លួន លោក នួន ជា មកធ្វើយោបល់នៅពេលនេះទេ។ ដូច្នេះ ប្រសិនបើមេធាវីចង់ធ្វើដូច្នេះគឺថា បើសិនជាមេធាវីចង់សួរសំណួរបាន។ ប៉ុន្តែមេធាវីមិនអាចប្រើឱកាសនេះ ដើម្បីបញ្ជាក់ យោបល់អ្វីទៅលើភស្តុតាងសក្ខីកម្មនោះបានទេ។

[១៣:៤០:១៧]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

បាទ លោកប្រធាន យើងក៏មានគោលជំហរដូចដែលពីរបីអាទិត្យមុន-- ពីរបីខែមុនដែរ គឺគោលជំហរ ដូចសហព្រះរាជអាជ្ញា។ ដូច្នេះ នួន ជា មិនអាចប្រើតាមចិត្តចង់ ប្រើពេលវេលា ដើម្បីធ្វើសេចក្ដីប្រកាសក្នុងពេលដែលត្រូវចោទសំណួរទៅសាក្សីនោះទេ។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

លោក នួន ជា គាត់ចង់បញ្ជាក់ ហើយគាត់នៅខាងផ្នែកការពារក្ដី ហើយគាត់បញ្ជាក់យោបល់មួយ ចំនួនទាក់ទងទៅនឹងសក្ខីកម្មមួយចំនួនខាងដើម ដែលគាត់ចង់។ ហើយខ្ញុំមិនគិតថា អង្គជំនុំជម្រះមិនចង់ស្ដាប់អ្វីដែលលោក នួន ជា និយាយទេ។ ដូច្នេះ គិតថាគាត់និយាយវាអាចនឹងបង្ហាញនឹងការពិតដែលតទល់ ដែលបញ្ច្រាំងទៅនឹងសក្ខីកម្ម។ ដូច្នេះហើយ គាត់នឹងចង់សម្ដែងយោបល់ក្រៅពីអ្វីដែលគាត់ចង់ទទួលសំណួរពីភាគីនោះ ទៅវិញនោះបាទ។

[១៣:៤១:២៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

បាទ លោកប្រធាន។ ប្រសិនបើលោក នួន ជា គាត់ដាក់ខ្លួនគាត់សម្រាប់ឱ្យទទួលសំណួរ ឬក៏សួរនោះ គឺថាទាក់ទងចំណុចនេះ មិនគប្បីយកមកប្រើនៅចំពោះកណ្ដាលពេលដែលសាក្សីមកទីនេះនោះទេ។ ប្រសិនបើគាត់ចង់ធ្វើយោបល់ទាក់ទងនឹងបញ្ហានេះ គឺហើយគាត់ចង់ទទួលសំណួរនោះ គឺថាយើងអាចនឹងកំណត់កាលវិភាគមួយ ដើម្បីឱ្យធ្វើនៅពេលក្រោយ ពេលដែលបញ្ចប់ជាមួយសាក្សីនេះសិន។ ហើយប្រសិនបើឱ្យពេលគាត់សួរដេញដោលផ្ទាល់មកសាក្សីពាក់កណ្ដាលសក្ខីកម្មបែបនេះ គឺមិនសមស្របតាមនីតិវិធីនោះទេបាទ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

បាទ ខ្ញុំ-- យើងគាំទ្រគោលជំហរសហព្រះរាជអាជ្ញា។ បើសិនជាលោក នួន ជា គាត់ចង់-- អាចចង់ឆ្លើយនឹងសំណួរ យើងយល់ព្រម។ តែករណីនេះ វាខុសគ្នា ព្រោះថាឥឡូវនេះ មិនមែនជាពេលសមស្របនោះទេ។ តែយើងមានសាក្សីមកផ្ដល់សក្ខីកម្មច្រើនមកហើយ។ ហើយយើងត្រូវបញ្ចប់ការស្ដាប់សក្ខីកម្មនេះសិន មុននឹងចូលទៅដល់ការចោទសំណួរទៅលោក នួន ជា នោះ។

[១៣:៤២:៥១]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

លោកប្រធាន។ នេះគឺថា។ឥឡូវនេះ គឺថាយើងចង់ធ្វើនៅពេលនេះ គឺថាក្នុងពេលដែលសាក្សីដែលអាចនឹងឆ្លើយ ឬក៏លោក នួន ជា នឹងឆ្លើយ និងធ្វើយោបល់តទល់ជាមួយសាក្សី។ នេះគឺថាអ្វីដែលទាក់ទងទៅនឹងអ្វីដែលសាក្សីបានឆ្លើយនៅពេលនេះ។ គឺនៅពេលនេះ គឺយើងនៅមានពេលគ្រប់គ្រាន់ ហើយយើង បើប្រើពេល ពេលក្រោយ យើងនឹងកត់កំណត់ពេលកាលបរិច្ឆេទ រៀបចំច្រើន បើពេលឱកាសពេលនេះហើយ វាជាសមស្រប និងតុលាការ គប្បីតែអនុញ្ញាត។

[១៣:៤៣:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៥:៤២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ហើយជនជាប់ចោទតាំងសំណួរចំពោះសាក្សីគឺឆ្លងកាត់យើង ជាប្រធានអង្គជំនុំជម្រះសាលាដំបូង។ ដូច្នេះរបៀបតាំងសំណួរត្រូវសួរតាមរយៈយើង។ យើងនឹងបញ្ជូនសំណួរនេះទៅឲ្យសាក្សី ឬក៏មិនបញ្ជូន នោះជាសិទ្ធិរបស់យើង។ សាក្សីរង់ចាំស្តាប់យើងសម្រេច ថាតើឲ្យលោកឆ្លើយតបទៅនឹងសំណួរ ឬក៏មិនចាំបាច់ឆ្លើយទេ។ ប៉ុន្តែទន្ទឹមនេះគឺលោកស្តាប់តែម្តង ព្រោះគ្រាន់តែជាការបញ្ជូនប៉ុណ្ណោះ យើងមិននិយាយសាឡើងវិញអំពីសំណួរតទល់នោះទេ។ សូមអញ្ជើញ!

[១៣:៤៧:០៨]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

ខ្ញុំគិតថា វាជាភាពសមស្របប្រសិនបើលោកទាក់ទងផ្ទាល់ជាមួយកូនក្តីរបស់ខ្ញុំនៅពេលនេះ គឺថាសូមឲ្យសាក្សី និងកូនក្តីរបស់ខ្ញុំហ្នឹងផ្ទាល់គ្នា។

**ប្រធានអង្គជំនុំ៖**

លោកពិនិត្យមើលនីតិវិធីឡើងវិញ! ភាគីដែលមិនមែនជាមេធាវីទេ គឺត្រូវតាំងសំណួរសាក្សីតាមរយៈប្រធានសវនាការ។ សូមលោកអាននូវបទប្បញ្ញត្តិពាក់ព័ន្ធជាមួយនឹងការតទល់បែបនេះឡើងវិញ!

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

បាទ ពិតហើយលោកប្រធានចៅក្រម គឺជាដល់ពេលដែលលោកប្រធាន និងកូនក្តីរបស់ខ្ញុំដើម្បី

ប្រាស្រ័យទាក់ទង ទាក់ទងនឹងការសួរដេញដោលនេះបាទ។

**លោក នួន ជា៖**

សូមគោរពបងប្អូនរួមជាតិ សូមគោរពលោកប្រធាន។ អំពីការ-- ខ្ញុំសូមនិយាយអំពីការជម្លៀសប្រជាជនដោយបង្ខំ។ ខ្ញុំសូមធ្វើការឆ្លើយតបមួយចំនួនចំពោះសក្ខីកម្មរបស់លោករូបនេះទាំងប៉ុន្មាន និងទាំងប៉ុន្មានកន្លងមកនេះ អំពីការជម្លៀសប្រជាជន។ លោកសាក្សីបាននិយាយពីហេតុផលដ៏ត្រឹមត្រូវខ្លះៗក្នុងការជម្លៀសប្រជាជនចេញពីទីក្រុង គឺដើម្បីចៀសពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក និងការអត់ឃ្លាន និងសង្គ្រាមដណ្ដើមគ្នាទៅវិញទៅមក។ តែលោកសាក្សីភាគច្រើនមិនបានដឹងពីមូលហេតុច្បាស់ និងច្រើនជាងនេះទេ ហើយដែលហាក់ដូចជាបង្ហាញថា ចេតនា ឬក៏មធ្យោបាយជម្លៀសដូចជាមិនល្អទៅវិញ។

[១៣:៤៩:៤២]

តទៅនេះ ខ្ញុំសូមធ្វើការឆ្លើយតបដូចតទៅ៖ ជាដំបូង ខ្ញុំសូមជម្រាបថា យើងខ្ញុំជាអ្នកចាញ់សង្គ្រាមត្រូវបានចោទប្រកាន់ពីការជម្លៀសប្រជាជនដោយបង្ខំ។ ក៏ប៉ុន្តែសម្មភាពកុំ-- ក្នុងពេលបច្ចុប្បន្ននេះមានភាពមិនសមរម្យ បើប្រៀបទៅការជម្លៀសនៅបន្ទាប់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទៅទៀត។ ខ្ញុំសូមនិយាយដើម្បីប្រជាជនក្រីក្រ ដែលត្រូវបានជិះជាន់ និងធ្វើទុក្ខបុកម្នេញដល់អាយុជីវិត ដោយពួកអ្នកមានលុយ មានបុណ្យសក្តិ ដែលកំពុងប្លន់ដីធ្លីស្រែចម្ការ--

**ប្រធានអង្គជំនុំ៖**

លោក នួន ជា ចាកឆ្ងាយពីកិច្ចដំណើរការនីតិវិធីសវនាការថ្ងៃនេះហើយ។ គោលបំណងនៃកិច្ចដំណើរការសវនាការថ្ងៃនេះ គឺសួរស្ដាប់សក្ខីកម្មសាក្សីនៅចំពោះមុខនេះ ពាក់ព័ន្ធទៅនឹងអង្គហេតុមួយចំនួននៅក្នុងនោះ គឺមានរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន រចនាសម្ព័ន្ធសហករណ៍ ហើយដោយឡែកគឺមន្ទីរសន្តិសុខគោកក្ដួច។

[១៣:៥១:៤៥]

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើសេចក្ដីថ្លែងការណ៍ឯណាក្រៅពីអង្គហេតុ ពាក់ព័ន្ធទៅនឹងសាក្សីរូបនេះបានដឹង បានឆ្លើយផ្ដល់សក្ខីកម្មឲ្យច្រើនហើយ។ មិនផ្ដល់វេទិកាឲ្យលោកយកវេទិកានេះទៅធ្វើអ្វីស្រេចតែចិត្តលោកទេ។ សំណួរយើងចុងក្រោយ តើលោកមានសំណួរអ្វីពាក់ព័ន្ធទៅនឹងសាក្សីរូបនេះដែរឬទេ នូវអង្គហេតុនៅក្នុងសំណុំរឿង០០២ ទាំងមូល និងដោយឡែកអង្គហេតុពាក់ព័ន្ធនឹងការដឹង

របស់សាក្សីរូបនេះ ដែលលោកបានដំណើរការស្តាប់រយៈពេលមួយថ្ងៃកន្លះមកហើយនេះ?

**លោក នួន ជា៖**

ខ្ញុំសូមនិយាយអំពីការជម្លៀសប្រជាជន--

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យលោកនិយាយទេ ប្រសិនបើលោកគ្មានសំណួរទេគឺ-- គ្មានសំណួរតទល់ជាមួយនឹងសាក្សីរូបនេះទេ គឺបញ្ឈប់មិនឲ្យលោកធ្វើត្រឹមនេះ។

[១៣:៥៣:២០]

**លោក នួន ជា៖**

*(និយាយដោយក្បាលមីក្រូហ្វូនមិនដំណើរការ)*

**ប្រធានអង្គជំនុំ៖**

យើងមិនឲ្យលោកនិយាយទៀតទេ លោក នួន ជា ចប់ត្រឹមហ្នឹងហើយ ករណីបរិបទនេះ គឺមិនឲ្យលោកបន្តធ្វើសេចក្តីថ្លែងការណ៍អ្វីទៀតទេ វាខុសជាមួយនឹងគោលបំណងនៃការស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងសាក្សីរូបនេះ។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ពាក្យកូនក្តីរបស់ខ្ញុំក្តីនោះមិនទាន់បានបកប្រែចប់ទាំងអស់នោះទេ។ ប្រហែលជាយើងសូមកត់ប្រតិចារឹក គឺថាវាមានការពាក់ព័ន្ធទៅនឹងប្រធានបទរឿងក្តីនេះ។ ជាពិសេសគឺអ្វីៗដែលកូនក្តីរបស់ខ្ញុំនិយាយ គប្បីតែឮ ហើយនិងបានបកប្រែ។

[១៣:៥៤:៣៨]

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យនិយាយទេ។ ខុសគោលបំណងនៃការកំណត់ហេតុ-- កំណត់កាលបរិច្ឆេទធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ។

ប្រសិនបើលោកចង់ធ្វើរបៀបនេះ គឺអាចធ្វើនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។

[១៣:៥៥:០០]

បើលោកមិនសំណួរអីសួរតាំងសំណួរដេញដោលជាក់លាក់ចំពោះសាក្សីរូបនេះទេ សូមលោក

អង្គុយចុះ! អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីផ្សេងទៀត។

**លោក ម៉ៃខល ផេសមិនៈ**

ខ្ញុំមិនដឹងថា កូនក្តីរបស់ខ្ញុំនិយាយអ្វីទេ ខ្ញុំស្តាប់មិនបាន វាមិនទាន់បានបកប្រែទៅជាភាសាអង់គ្លេស ឬក៏បារាំងទេ ពីព្រោះយើងអ្វីដែលស្តាប់បាន គឺចម្លើយលោកប្រធានតែប៉ុណ្ណោះ គឺថាយើងមិនយល់ថាអ្វីទេ ចម្លើយរបស់គាត់នោះ។ ដូច្នេះ គឺថាសុំអនុញ្ញាតឲ្យកូនក្តីរបស់ខ្ញុំនិយាយម្តងទៀត ឬក៏និយាយបន្តអ្វីដែលមិនទាន់បានឮក្នុងប្រព័ន្ធ ហើយបកទៅជាភាសាអង់គ្លេស និងបារាំងនោះបាទ។

[១៣:៥៦:០៧]

**ប្រធានអង្គជំនុំៈ**

បើលោកមេធាវីស្តាប់មិនច្បាស់ទេ សូមអញ្ជើញសួរ សាកសួរមេធាវីជាតិការពារក្តីលោក នួន ជា ទៅបានហើយ។ យើងមិនអនុញ្ញាតឲ្យយកវេទិកានេះទៅធ្វើខុសគោលដៅ គោលបំណងនៃការកំណត់វិភាគសម្រាប់ធ្វើសវនាការ សម្រាប់ថ្ងៃនីមួយៗ សម្រាប់សាក្សីនីមួយៗទេ។

អង្គុយចុះ!

មានសំណួរអ្វីពាក់ព័ន្ធត្រូវសួរសាក្សីរូបនេះទេមេធាវី? បើសិនជាមាន សូមអញ្ជើញ! បើអត់មានទេ គឺប្រគល់ទៅឲ្យក្រុមមេធាវីការពារក្តីផ្សេងទៀត។

**លោក ម៉ៃខល ផេសមិនៈ**

បាទ លោកប្រធាន។ មេធាវីជាតិនឹងមានសំណួរមួយចំនួន ហើយខ្ញុំនឹងស្នើធម្មតា សូមឲ្យកូនក្តីរបស់ខ្ញុំទៅតាមដាននៅបន្ទប់ខាងក្រោម ពីបន្ទប់ខាងក្រោមនេះ។ បាទ ហើយខ្ញុំនឹងដាក់ជូនតុលាការនូវលិខិតបោះបង់សិទ្ធិរបស់គាត់។ បាទ ដោយសារថា គាត់មិនមានសិទ្ធិក្នុងការនិយាយ គាត់មិនចង់ចូលនៅក្នុងសាលសវនាការនេះទេ។

[១៣:៥៧:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៨:១១]

**ប្រធានអង្គជំនុំៈ**

ម៉េចទៅលោក នួន ជា? លោកសុំ ពិតជាការសុំរបស់លោកទៅបន្តតាមដាននៅបន្ទប់ឃុំខ្លួនខាងក្រោមតាមរយៈប្រព័ន្ធសោតទស្សន៍ ដូចមេធាវីស្នើសុំនេះពិតមែនដែរឬទេ លោក នួន ជា?

**លោក នួន ជា៖**

ជម្រាបលោកប្រធាន បើមិនឲ្យខ្ញុំនិយាយតទៅទៀត ខ្ញុំសូមទៅនៅខាងក្រោម។

**ប្រធានអង្គជំនុំ៖**

បានស្ដាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ និងបានស្នើសុំដោយផ្ទាល់មាត់ខ្លួនគាត់សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលសវនាការបន្តទៅរហូតដល់ចប់នៅថ្ងៃនេះ ដោយគាត់លះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ហើយមេធាវីបានសន្យាថាខ្លួននឹងប្រគល់មកអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។

[១៣:៥៩:៤៣]

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំដោយផ្ទាល់ និងតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីជនជាប់ចោទ នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះរហូតដល់ចប់។

[១៤:០០:៤៤]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ទៅកាន់បន្ទប់ឃុំខ្លួនមួយខាងក្រោមសាលសវនាការនេះ ដែលមានរៀបចំទុកជាស្រេចនៅឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមកិច្ចដំណើរការសវនាការពីចម្ងាយ។

លោកមេធាវី-- ក្រុមមេធាវីការពារក្ដី នួន ជា មានសំណួរអីសួរដល់សាក្សីរូបនេះទេ?

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

**សួរដោយលោក សុន អរុណ៖**

**ស៖** សួស្តីសាក្សីលោក យុន គីម ខ្ញុំឈ្មោះ សុន អរុណ មេធាវីរបស់-- សហមេធាវីជាតិរបស់លោក នួន ជា។ កាលពីម្សិលមិញលោកសាក្សីបានឆ្លើយជម្រាបព្រះរាជអាជ្ញាថា វត្តនៅក្នុងតំបន់របស់លោកដែលលោកកាន់កាប់នោះបានចប់សព្វគ្រប់។ ខ្ញុំសូមសួរថា លោកសឹកពេលនុ៎ង លោកសឹកអស់ពីវត្តទៅនុ៎ងតើមូលហេតុ លោកអាចជម្រាបតុលាការបានទេថា សឹកដោយមានមូលហេតុលោកសឹកដោយអត់បាយឆាន់ លោកសឹកដោយរដ្ឋអាជ្ញាកាលសម័យហ្នឹងបង្ខំឱ្យផ្សឹក ឬក៏មានមូលហេតុអ្វីដែលធ្វើឱ្យលោកសឹកអស់?

[១៤:០២:៤៤]

**លោក យុន គីម៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា នៅឆ្នាំ១៩៧៦ នេះ គឺមានចលនាវត្តមួយៗចេះតែនាំគ្នាសឹកអស់ៗទៅ ដោយមានការបញ្ជាក់ពីអាជ្ញាធរដែរ គឺថាសម័យដូចខ្ញុំជម្រាបពីម្សិលមិញអ៊ីចឹងថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ ធ្វើបដិវត្តន៍គេមិនធ្វើពីរដងទេ។ គេធ្វើបដិវត្តន៍ហ្នឹងទាំងបដិវត្តន៍វប្បធម៌ទៅជាមួយគ្នាតែម្តង។ ដូច្នេះបានន័យថា សាសនាហ្នឹងក៏ត្រូវរលំរលាយនៅពេលដែលដំណើរការនៃសហករណ៍របស់យើងកាន់តែឆ្ពោះទៅមុខអ៊ីចឹង។ អ៊ីចឹងហើយបានជាការបាត់បង់សាសនានេះ គឺបាត់បង់ដោយមិនបាច់បង្ខំអីធំដុំទេ គឺគ្រាន់ថា វត្តត្រូវរលាយពីព្រោះប្រជាជនរវល់អស់ទៅមានអ្នកណាយកចង្ហាន់មកប្រគេនលោក ដល់អ៊ីចឹងវាចប់ទៅស្វ័យប្រវត្តិតែម្តងបាទ។ ដូចខ្ញុំបញ្ជាក់ថា កុំឱ្យបដិវត្តន៍ហ្នឹងពីរដង។ បដិវត្តន៍ក្នុងប្រជាជនពីយើងឯកជនទៅជាសហគមន៍ម្តង ហើយបដិវត្តន៍មួយទៀតបំបាត់ជំនឿសាសនា គេអត់ធ្វើអ៊ីចឹងទេ។ គឺតែម្តងទៅជាមួយគ្នាតែម្តង។ ដូចស្រុកចិនយើងដឹងហើយថា គេធ្វើបដិវត្តតាំងពី៤៩មកដល់ឆ្នាំឆ្នាំ១៩៦៦ បានគេធ្វើបដិវត្តន៍វប្បធម៌ម្តងទៀត។ បាទ ខ្ញុំសូមមានមតិប៉ុណ្ណេះ។

[១៤:០៤:៣៨]

**ស៖** ពីម្សិលមិញដែរ លោកបានឆ្លើយជាមួយនឹងព្រះរាជអាជ្ញាដដែលថា លោកបានឃើញទង់

បដិវត្ត។ នៅក្នុងទង់បដិវត្តនោះមានបាននិយាយអំពីវត្តអារាមទេ?

**ឆ៖** ពាក់ព័ន្ធនឹងទង់បដិវត្តនេះ ដោយរយៈពេលយូរពេក ឯកសារដែលនៅក្នុងនោះ គឺជាការណែនាំរបស់មជ្ឈិមបក្សនេះ បាទខ្ញុំចាំមិនច្បាស់ទេ។ អ៊ីចឹង គឺក្នុងន័យនេះ គឺអាចមានគោលនយោបាយធំៗច្រើន។ តែពាក់ព័ន្ធនឹងវត្តអារាមនេះ គឺជាការណែនាំបន្តបន្ទាប់គ្នារបស់ស្រុក។ អ៊ីចឹងខ្ញុំមិនអាចសន្និដ្ឋានបានថាម៉េចទេ ព្រោះវាយូរពេកពេលវេលាបាទ ៣០ប្លាយឆ្នាំហើយ។

**ស៖** អរគុណលោកសាក្សី។ លោកបានជម្រាបទៅអង្គសវនាការថា លោក នួន ជា ដែលធ្លាប់ទៅតំបន់របស់លោក គឺស្រុកសំបូរ ដើម្បីទៅធ្វើការអប់រំ ហើយនិងបង្រៀនប្រជាពលរដ្ឋនៅតំបន់នុ៎ង។ ពេលដែលលោក នួន ជា បានទៅអប់រំ និងធ្វើការបង្រៀនដល់ប្រជាជននៅតំបន់ហ្នឹង លោកនួន ជា មាននិយាយអំពីរឿងខ្មាំង ដែលកម្ពុជាប្រជាធិបតេយ្យបានចោទថា ខ្មាំងប្រឆាំងនឹងកម្ពុជាប្រជាធិប-តេយ្យហ្នឹងមានបី គឺខ្មាំងផ្ទៃក្នុង ខ្មាំងអាមេរិកាំង និងខ្មាំងវៀតណាម តើលោកនួន ជា បាននិយាយពីរឿងហ្នឹង អស់ហ្នឹងទេ?

[១៤:០៦:៥១]

**ឆ៖** នៅឆ្នាំ១៩៧៣ លោក នួន ជា អត់បានទៅដល់មូលដ្ឋានរបស់ខ្ញុំទេ គឺគាត់ទៅនៅឃុំដារ។ ឃុំដារនេះវានៅក្បែរក្រចេះ នៅក្នុងស្រុកក្រចេះ ប៉ុន្តែម៉ាខេត្តក្រចេះទាំងបីស្រុកហ្នឹងមកចូលរួម។ ហើយនៅពេលនោះ ដូចខ្ញុំបានជម្រាបជូនអ៊ីចឹងថា គាត់បានជម្រាបអង្គប្រជុំវគ្គទីមួយ គឺនិយាយអំពីសភាពការណ៍ខ្មាំងហើយ។ បាទ ខ្មាំងក្នុងនោះយើងដឹងហើយថា ពេលនោះគឺមានខ្មាំងអាមេរិកាំង មានខ្មាំងខាងវៀតណាម ហើយនិងខ្មាំងផ្ទៃក្នុង។ នេះគឺជាការធម្មតានៃការប្រជុំអំពីសភាពការណ៍ខ្មាំង គឺវាមានបែងចែកយ៉ាងដូច្នេះ។ ហើយក្រៅពីនេះគឺគាត់បានណែនាំអំពីការធ្វើប្រវាស់ដៃសហករណ៍។ ខ្ញុំសូមអស់មតិ។

**ស៖** អរគុណ។ លោកសាក្សី លោកបានជួបលោក នួន ជា តែម្តងហ្នឹងទេ ឬក៏ក្រោយមកទៀតលោកបានដែលជួបគាត់ទៀតទេ?

**ឆ៖** ថ្នាក់ដឹកនាំខាងលើរបស់ខ្មែរក្រហម ខ្ញុំបានជួបតែលោក នួន ជា ម្តងគត់ ក្រៅពីនេះខ្ញុំអត់ដែលបានជួបលោកណាទាំងអស់បាទ។ ខ្ញុំសូមអស់យោបល់។

**ស៖** អរគុណ។ ពេលដែលលោកបានទៅជួប នួន ជា នៅពេលហ្នឹង គឺលោកបានជួបផ្ទាល់បានពិភាក្សានិយាយគ្នាសំណេះសំណាលជាមួយគ្នាទេ ឬក៏លោកគ្រាន់តែចូលក្នុងបន្ទប់សិក្សាហ្នឹងទេ?

ឬក៏ថាលោកបានជួបនិយាយគ្នាបានសំណេះសំណាលជាមួយគ្នាដែរ?

[១៤:០៨:៥៥]

**ឆ៖** នៅពេលដែលជួបលោក នួន ជា គឺយើងនៅក្នុងសិក្ខាសាលា។ បាទ សិក្ខាសាលាគាត់នៅវេទិកាឯលើ ឯខាងខ្ញុំងនេះ ខ្ញុំនៅអង្គុយក្នុងសាលហ្នឹង គឺមានតុ មានអីអ៊ីចឹង បាទ។ អ្នកដែលចូលរួមគឺមានមេឃុំគ្រប់ឃុំក្នុងខេត្តក្រចេះយើង។ ដូចខ្ញុំជម្រាបអ៊ីចឹង ខេត្តក្រចេះអង្កាល់នោះគឺមានតែបីស្រុកទេ គឺមានស្រុកស្នួល ស្រុកក្រចេះ និងស្រុកសំបូរ ឯស្រុកឆ្លូងគេកាត់ទៅខាងភូមិភាគបូព៌ា ឯស្រុកព្រែកប្រសប់គេកាត់ទៅភូមិភាគកណ្ដាល។ អ៊ីចឹងគឺមានមនុស្សមិនជាច្រើនប៉ុន្មានទេបាទ។ ហើយក្នុងពេលប្រជុំនោះ គឺយើងស្ដាប់ការណែនាំរបស់គាត់ ហើយគាត់ក៏បានសួរមកខាងសិក្ខាកាមទាំងអស់ដែរ អំពីការពិបាក ការស្រួលក្នុងដំណើរការនៅក្នុងមូលដ្ឋានមួយៗ។ នេះខ្ញុំសូមអស់មតិប៉ុណ្ណេះ។

[១៤:១០:០៣]

**ស៖** អរគុណ។ បើអ៊ីចឹង លោកគ្រាន់តែស្គាល់តាមរយៈធ្វើសិក្ខាសាលា មានន័យថា ស្គាល់ប្រយោល មិនបានជិតដិត មិនបានពិភាក្សាស្និទ្ធស្នាលអីជាមួយគ្នាទេ។ មិនអ៊ីចឹងណ៎ា យ៉ាងម៉េច? ដូចលោកមិនបាននិយាយអី ជាមួយគាត់ហ្នឹង ឲ្យបានគឺថា ស្គាល់ បានស្គាល់សម្ដីគាត់ បានជួបពិភាក្សាអីគ្នាមិនមានអ៊ីចឹងទេ គ្រាន់តែបានទៅចូលទៅរួមសិក្សាតែប៉ុណ្ណឹងទេ?

[១៤:១០:៣៨]

**ឆ៖** បាទ ពិតជាអ៊ីចឹងហើយ គឺអត់បានជជែកគ្នា អង្គុយនិយាយគ្នា ដូចថា ផ្ទាល់ទៅមកអីទេ គឺអង្គុយស្ដាប់គាត់ ហើយនិងពេលដែលគាត់សួរមកខាងពួកខ្ញុំឯណេះ ពួកខ្ញុំក៏ឆ្លើយទៅវិញ ទៅតាមដំណើរហ្នឹង។ នេះ ខ្ញុំសូមអស់មតិ។

**ស៖** អរគុណ។ លោកបានចូលទៅធ្វើសិក្ខាសាលា ជាមួយនិងបងប្អូនថ្នាក់ដឹកនាំស្រុកឃុំអីទាំងអស់ជាមួយលោក នួន ជា ដែលជាអ្នកបង្រៀន។ លោកតាមលោកសង្កេតមើលទៅ ឃើញលោក នួន ជា ដែលនៅលើវេទិកាហ្នឹង លោកជាមនុស្សយ៉ាងម៉េច? មានចរិតយ៉ាងម៉េច? ចរិតគាត់ជាមនុស្សឃោរឃៅកាប់សម្លាប់ បញ្ជូនមនុស្សឲ្យទៅដាក់គុក ឬក៏មនុស្សមានចរិតល្អ ត្រឹមត្រូវសមរម្យ មានគតិឧត្តមគតិល្អ គួរគោរព ឬក៏យ៉ាងម៉េច? អាហ្នឹង សូមលោកបញ្ជាក់បន្តិច។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹង-- ដោយសារស្នើសុំឱ្យសាក្សីរូបនេះ គឺធ្វើការប៉ាន់ស្មាន នូវបរិបទ ដែលពាក់ព័ន្ធទៅនឹងលោក នួន ជា នោះ ដោយសារធ្វើឱ្យសាក្សីរូបនេះ ឆ្លើយដោយស្មានៗ។

[១៤:១២:២០]

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅព្រះរាជអាជ្ញា។ នេះមិនមែនការស្មានទេ ការនេះគឺសាក្សី បានទៅផ្ទាល់នឹងភ្នែក ហើយខ្ញុំសួរថា តើផ្ទាល់ភ្នែកហ្នឹង បានឃើញចរិតយ៉ាងម៉េច? អាហ្នឹង ការឃើញរបស់គាត់ហើយ មិនមែនរឿងស្មានទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា គ្មានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរ ដែលសួរដោយមេធាវីអម្បាញ់មិញនេះ។

**លោក យុន គីម៖**

**ឆ៖** ខ្ញុំសូមមានមតិបន្ត។ ពាក់ព័ន្ធនឹងការណែនាំ និងអត្តចរិតរបស់លោក នួន ជា នៅពេលនោះគឺ គាត់មានលក្ខណៈល្អ សមជាថ្នាក់ដឹកនាំ ពីព្រោះក្នុងភាសានិយាយស្ដីក្ដី ការណែនាំក្ដី គាត់តម្រង់ទិសមួយទៅឱ្យធ្វើយ៉ាងម៉េច ក្នុងតួនាទីជាកម្មាភិបាលត្រូវមានលក្ខណៈល្អប្រសើរ ហើយនិងឱ្យមានការជួបជាមួយនឹងប្រជាជន។ ខ្ញុំសូមអស់មតិ។

[១៤:១៣:៤៦]

**លោក សុន អរុណ៖**

**ស៖** ខ្ញុំសូមសួរសំណួរមួយផ្សេងទៀត។ មុនពេល និងក្រោយពេលលោកសាក្សី បានចូលធ្វើបដិវត្តនោះ លោកដែលឃើញ ឬបានជួបប្រទះ ដោយខ្លួនឯងនូវការទម្លាក់គ្រាប់បែក ពីសំណាក់យន្តហោះអាមេរិកាំងឬទេ?

**ឆ៖** ពាក់ព័ន្ធទៅនឹងការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនេះគឺ មុនពេលខ្ញុំចូលរួមជាមួយចលនាបដិវត្តន៍ ខ្ញុំមិនដែលបានឃើញទេ ធ្លាប់តែដឹងថា មាននៅតាមព្រំដែន ដូចជា នៅដាក់ដាំ ក្នុងខេត្តមណ្ឌលគិរី នៅចន្ទ្រា ក្នុងខេត្តព្រះវិហារ ហ្នឹងធ្លាប់ឮថា អាមេរិកាំងទម្លាក់គ្រាប់បែក។ ប៉ុន្តែនៅពេលដែលយើងមានរដ្ឋប្រហារ ឆ្នាំ១៩៧០ ១៨ មីនា ៧០ មក គឺមាន មានឃើញសកម្មភាពរបស់យន្តហោះ

អាមេរិកាំងហ្នឹងគឺបាញ់រះនៅតាមទន្លេ បាទ។

[១៤:១៥:០៥]

ហើយដល់ក្រោយមក នៅឆ្នាំ១៩៧២, ៧៣ នេះ គឺការទម្លាក់គ្រាប់បែក បាទ នៅក្នុងខេត្តក្រចេះ ដូចស្ទើរស្ពាន ស្ទើរតែដាច់ទាំងអស់ ស្ពាននៅក្នុងខេត្តក្រចេះ ព្រោះទម្លាក់ ជាក់ស្តែង ដូចជាភូមិគគុតមួយ នៅព្រំដែនស្រុកសំបូរ និងស្រុកក្រចេះ នៅចំពីមុខភូមិខ្ញុំហ្នឹងហើយ មានទម្លាក់មួយថ្ងៃពីរដង បីដង ស្ពានដាច់ហើយ ក៏នៅទម្លាក់ដែរ បាទ ទម្លាក់ច្រើនផ្ទះប្រជាជនអីឆេះខ្ទេចខ្ទាំ។ ស្ពាន នៅសណ្តាន់ បាទ ស្ពាននៅកាំពី បាទ។ ហើយនិងនៅភូមិរបស់ខ្ញុំនេះ ក៏មានទម្លាក់បេ-៥២ ពីរដងដែរ បាទ ហើយនិងទម្លាក់អាអេស-១១១ អាដែងវៃពេលយប់ បាទ អាហ្នឹងក៏មានច្រើនដងដែរ។ នេះ ខ្ញុំសូមបញ្ជាក់ជូន។ នេះ ខ្ញុំនិយាយតែក្រុបខ័ណ្ឌនៅជុំវិញខ្លួនទេ ខ្ញុំដឹង។ ឯនៅកន្លែងឆ្ងាយទៀត ឮសូរតែស្នូរទេ មិនដឹងជាកន្លែងណាៗ ទេ។ ខ្ញុំសូមអស់មតិ។

[១៤:១៦:១៩]

**សៈ** អរគុណ។ បើតាមសម្តីលោកជម្រាបទៅព្រះរាជអាជ្ញាពីម្សិលមិញថា នៅពេលដែលយោធាខ្មែរក្រហមមកដល់ស្រុកសំបូរ ពេលនុ៎ង មានសភាពច្របូកច្របល់ គឺប្រជាជនមានភាពច្របូកច្របល់ ដោយមានចាប់មនុស្ស ដឹកនាំ-- ចាប់មនុស្ស មនុស្សដែលថ្នាក់ដឹកនាំស្រុក ដឹកនាំខេត្ត ដឹកនាំមណ្ឌល-- តំបន់ (សូមទោស) និងឃុំជាទូទៅហ្នឹង គឺថាសឹងតែមិនសល់ៗ សឹងច្រើនណាស់ អស់ច្រើនណាស់ ព្រមទាំងឃុំក៏ចាប់ដែរ តើពេលនោះ លោកយល់ទេ តើមានផលវិបាកយ៉ាងណាខ្លះ នៃការចាប់ប្រជាជនរបៀបនេះ? ចំពោះការវិបាករបស់ប្រជាជន តើភៀសខ្លួន ឬក៏ថាប្រជាជនទាំងអស់ហ្នឹង ទ្រាំនៅកន្លែងហ្នឹង ដើម្បីឲ្យគេចាប់អ៊ីចឹង ឬយ៉ាងម៉េច សភាពទូទៅនៅក្នុងតំបន់របស់លោក?

**ឆៈ** បាទ ក្នុងសភាពការណ៍ដែលយោធាទៅក្តាប់អំណាចនៅដើមឆ្នាំ១៩៧៨ នៅក្នុងស្រុកសំបូរខ្ញុំ គឺមានការច្របូលច្របល់ដែរ។ ពីព្រោះក្នុងពេលនោះ គឺការចាប់នេះ គឺចាប់ភាគច្រើនគឺថ្នាក់ដឹកនាំ ឯប្រជាជនមិនសូវចាប់ចងអីទេ គឺថ្នាក់ដឹកនាំនេះ មានថ្នាក់ស្រុក ថ្នាក់ឃុំមួយចំនួន ហើយដូចជានៅក្នុងឃុំរបស់ខ្ញុំនៅនេះ ពេទ្យ។ ពេទ្យខ្ញុំហ្នឹងក៏គេចាប់ដែរ ខ្ញុំអត់ដឹងមូលហេតុអីដែរ ស្រាប់តែបាត់ពេទ្យទៅ ឃើញគេចាប់អ៊ីចឹងបាទ។ ឯនៅកន្លែង ដូចជានៅខេត្តអី ឮ គ្រាន់តែឮដំណឹង ថាគេចាប់អស់ហើយ ថ្នាក់តំបន់ រត់រប៉ាត់រប៉ាយ។ នេះ ខ្ញុំសូមមានមតិប៉ុណ្ណឹង។

[១៤:១៨:៥១]

**ស៖** អរគុណ។ ពេលនុ៎ង មានចលាចលដោយសារយោធាចុះមកចាប់ ហើយយោធាទាំងអស់ហ្នឹង បើតាមលោកមានប្រសាសន៍-- ជម្រាបតុលាការពីម្សិលមិញ គេច្រើនប្រើពាក្យ ញោម១ ហៅគ្នាអី ហៅញោមអ៊ីចឹង។ លោកយល់ទេ ថាតើដែងមនុស្សយោធាដែលចុះមក ហៅញោមហ្នឹង ជាមនុស្សជាខ្មែរ ឬក៏ជាជនជាតិអីផ្សេង ឬក៏ជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនិយាយពីដើមមក ថាមានខ្មាំងផ្ទៃក្នុង មានអាមេរិកាំង មានយៀកណាម មានអី១ អ៊ីចឹងទៅ បើតាមលោកយល់ ថាតើខ្មាំងអ៊ីចឹងមកចាប់ ឬក៏យោធារបស់កម្ពុជាប្រជាធិបតេយ្យ?

[១៤:១៩:៤៨]

**ផ៖** ពេលដែលយោធាចូលមកចាប់ថ្នាក់ស្រុក ថ្នាក់ឃុំ ថ្នាក់សហករណ៍អីខ្លះហ្នឹង ពេលនោះខ្ញុំគិតថា ជាយោធារបស់កម្ពុជាប្រជាធិបតេយ្យ។ ពីព្រោះយោធានេះគឺវាមានជាខ្សែសង្វាក់របស់វា ឯអ្នកដែលចាប់នោះ ខ្ញុំ-- ពេលចាប់ខ្ញុំអត់ដឹងថាទៅណាទេ ប៉ុន្តែយោងទៅតាមឯកសារដែលខ្ញុំបានឃើញពីម្សិលនេះ ដូចជាមិត្តភក្តិរបស់ខ្ញុំ ដូចជាឈ្មោះ នី ឈ្មោះ ផាន ជាដើម មកដល់គុកស-២១។ អ៊ីចឹងបានន័យថា ជាកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមអស់មតិ។

**ស៖** សូមអរគុណជាថ្មី។ សំណួរមួយទៀត លោកសាក្សីនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺថ្ងៃ លន់ នល់ ធ្លាក់ពីតំណែង គឺពេលហ្នឹងគឺកម្ពុជាប្រជាធិបតេយ្យវ៉ៃចូលភ្នំពេញ។ តើលោកពេលហ្នឹងលោកនៅឯណា?

**ផ៖** នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គឺពេលនោះ ខ្ញុំនៅនឹងភូមិវត្តរុន៖ កំពុងតែជីកប្រឡាយ បាទកំពុងតែជីកប្រឡាយ ដាក់វ៉ាដ្យូស្តាប់អ៊ីចឹង ដល់រួចថាភ្នំពេញរំដោះអ៊ីចឹង។ បាទ ខ្ញុំសូមអស់មតិ។

[១៤:២១:៣៨]

**ស៖** អរគុណ។ ពេលដែលឮថាភ្នំពេញរំដោះអ៊ីចឹង ពេលនោះទិដ្ឋភាពទូទៅនៅតំបន់របស់លោករស់នៅ ហើយនិងទិដ្ឋភាពទូទៅនៃខេត្តក្រចេះទាំងមូល បើលោកអាចជម្រាបតុលាការបាន តើមានទិដ្ឋភាពយ៉ាងម៉េច ច្របូកច្របល់ ឬក៏ថាស្ងាត់ស្ងៀមធម្មតា ឬក៏សប្បាយរីករាយ?

**ផ៖** ជាធម្មតាប្រទេសដែលកំពុងតែមានសង្គ្រាម ការភ័យខ្លាចនឹងគ្រាប់ផ្លោង ការភ័យខ្លាចនឹងយន្តហោះទម្លាក់គ្រាប់បែក ដល់ឮថាប្រទេសជាតិបានរំដោះ គឺសប្បាយរីករាយទាំងអស់គ្នាបាទ។ នៅពេលនោះ គឺការដ្ឋានថ្ងៃហ្នឹងមួយថ្ងៃ អត់មានធ្វើការអីទេនាំគ្នាឈប់ពីការដ្ឋានហ្នឹងមកបណ្ដោយ។ នេះខ្ញុំសូមអស់មតិ។

**ស៖** ចុះប្រជាជននៅក្នុងក្រុងក្រចេះ មានភៀសខ្លួនទៅនៅតាមស្រុកស្រែចម្ការអីទេ ឬក៏នៅធម្មតា?

**ឆ៖** ប្រជាជននៅក្នុងក្រុងក្រចេះនេះ បើតាមខ្ញុំដឹងគឺតាំងពីពេលដែលរៀបចំមានសហករណ៍មកគឺប្រជាជនហ្នឹងចេញពីទីក្រុងចង់អស់ទៅហើយ។ បាទ ចេញអស់ហើយ លើកលែងតែអ្នកនៅធ្វើការអីនឹងក្រុងទេបាននៅ ពីព្រោះបើយើងមិនចុះទៅស្រែចម្ការបានអីហូប? អ៊ីចឹងគឺមិនបាច់បង្ខំទេហ្នឹង ចេញអូតូម៉ាទិកបណ្តោយហើយ។ បាទ សូមអស់យោបល់។

[១៤:២៣:២៦]

**ស៖** ចុះដល់ថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ពេលទ័ពវៀតណាមចូលវាយលុកដល់ក្រុងភ្នំពេញ និងខេត្តទូទៅ ទូទាំងប្រទេស លោកដឹងថាទិដ្ឋភាពទូទៅយ៉ាងណាដែរ ទូទាំងប្រទេស? លោកអាចឮ ឬក៏ថាតាមវិទ្យុ ឬក៏ឮតាមមិត្តភក្តិប្រាប់ ឬក៏ថាលោកបានដំណឹងពីណា មានសភាពយ៉ាងម៉េចពេលនុ៎ង?

**ឆ៖** នៅពេលដែលមុននឹងរំដោះខ្ញុំនៅការដ្ឋាននេះបានជម្លៀសចេញៗពីការដ្ឋាន ហើយខ្ញុំបានឆ្លងទន្លេមេគង្គពីត្រើយម្ខាងទៅត្រើយស្តាំៗ ពេលនោះគឺខ្ញុំទៅរស់នៅភូមិមួយនៅជិតភូមិខ្ញុំនៅដែរ គេហៅថាភូមិដងទង់។ ឯប្រជាជនចាស់រត់ចោលអស់រលីង រត់ចោលខ្ញុំអស់រលីងហើយ ព្រោះខ្ញុំនៅជាមួយយុវជននារី ដល់មានតែប្រជាជនថ្មី ប្រជាជន១៧ មេសាដែលធ្លាប់រស់នៅជាមួយខ្ញុំនៅឃុំសំបូរហ្នឹងគាត់ថាខ្ញុំទៅណា គាត់ទៅនុ៎ងដែរ។ គាត់នៅជាមួយខ្ញុំប្រហែលជា៣០-៤០គ្រួ បាទ នៅនឹងមាត់ទន្លេ។ ល្ងាចនុ៎ងគ្រាប់ផ្លោងមួយគ្រាប់ចូលមកជិតកន្លែងខ្ញុំរស់នៅហ្នឹង ហើយមិត្តភក្តិខ្ញុំមួយចំនួនដែលជាប្រជាជនចាស់សួរខ្ញុំថា ម៉េចឥឡូវគ្រាប់ផ្លោងមកហើយ គេច ឬមិនគេច? ខ្ញុំថាខ្ញុំអត់គេចទេ។ ទាល់តែប្រាំមួយគ្រាប់ថែមទៀត បានខ្ញុំគិតថាទៅ អ្អីមិនទៅ? បាទ ហើយដល់ចូលតែមួយគ្រាប់ហ្នឹងទៅ ស្រាប់តែព្រឹកឡើងឃើញកងទ័ពយួនចូលពេញមកកន្លែងហ្នឹង។ បាទ ហើយព្រឹត្តិការណ៍ហ្នឹង គឺយើងមិន--សប្បាយក៏មិនសប្បាយ ពីព្រោះពេលដែលកងទ័ពវៀតណាមមក ឲ្យជម្លៀសចេញទៅនៅសំបូរ បាទ។ ដោយឡែកខ្លួនខ្ញុំនេះក៏បានសុំគេទៅនៅវត្តរនះវិញ គេក៏ព្រមឲ្យទៅនៅ។ ប៉ុន្តែក្រោយមកទៀតជម្លៀសចុះជម្លៀសឡើង។ ដល់មកថ្ងៃ១៦ ខែមករា ខ្ញុំត្រូវវៀតណាមចាប់ ហើយបញ្ជូនទៅជាប់គុកនៅវៀតណាមរហូតដល់ថ្ងៃ១៦ ខែ៤ ឆ្នាំ៨០ បានខ្ញុំមកដល់ផ្ទះវិញ។ គិតទៅ១៥ អ៎! ១៥ ខែគត់។ បាទ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

[១៤:២៦:០៧]

**សៈ** អរគុណ។ ខ្ញុំយកបែរទៅក្រោយវិញបន្តិចវិញ ពេលដែលលោក នួន ជា ទៅធ្វើសិក្ខាសាលានៅខាងតំបន់ ខាងស្រុកសំបូរ ដូចខ្ញុំបានសួរនៅសំណួរលើកមុនអ៊ីចឹង។ ពេលហ្នឹងលោកបានប្រាប់ទៅសិក្ខាសាលា ឬបង្រៀងទៅសិក្ខាសាលាហ្នឹងថាឲ្យបង្កើតជាសហករណ៍តូច សហករណ៍ធំ។ ប៉ុន្តែពេលនោះក្រោយពីលោកបានបង្រៀនហើយ លោកត្រឡប់មកភ្នំពេញវិញ ពេលហ្នឹងលោកសាក្សីបានជម្រាបអង្គសវនាការថា មានចៅហ្វាយស្រុកឈ្មោះ ចែត បានទៅជាបង្កើតទៅជាសហគមន៍ទៅវិញ។ តើប្រជាពលរដ្ឋទាំងអស់នៅក្នុងតំបន់ហ្នឹង នៅក្នុងស្រុកហ្នឹង មានប្រតិកម្មអ្វីទេ ចំពោះថ្នាក់ដឹកនាំកំពូលចុះទៅធ្វើសិក្ខាសាលា ទៅឲ្យគោលការណ៍ហើយ បែរទៅជាចៅហ្វាយស្រុកម្នាក់ចាត់ការអនុវត្តគោលការណ៍ហ្នឹងផ្ទុយទៅវិញ? តើប្រជាពលរដ្ឋនៅតំបន់ហ្នឹងមានប្រតិកម្មអ្វីទេ?

[១៤:២៧:៣៤]

**ឆៈ** ខ្ញុំសូមជម្រាបជូនលោក លោក នួន ជា មិនបានទៅស្រុកសំបូរទេ។ លោក នួន ជា បានទៅប្រជុំនៅគេហៅមន្ទីរ ដ-៣ នៅក្នុងឃុំដារស្រុកក្រចេះ ហើយនៅពេលនោះគាត់បានណែនាំឲ្យធ្វើក្រុមប្រវាស់ដៃ សហករណ៍កម្រិតទាប ឬកម្រិតខ្ពស់។ នៅពេលដែលចេញពីសិក្ខាសាលានេះទៅ ឈ្មោះ ចែត ឈ្មោះដើម ឈឹម យោង គាត់ជាសាស្ត្រាចារ្យដែរ ហើយហៅ ចែត ឈ្មោះបដិវត្តន៍គាត់។ គាត់អត់ឲ្យទៅមូលដ្ឋានវិញទេ អ្នកនៅក្នុងស្រុកសំបូរ ទៅជួបជុំគ្នានៅមន្ទីរគាត់។ បាទមន្ទីរពេលនោះនៅកំពង់លើ បាទក្នុងឃុំកោះខ្ញែរ។ ហើយទៅដល់គាត់ជម្រាបថាយើងមិនបាច់ធ្វើប្រវាស់ដៃសហករណ៍កម្រិតទាប ឬកម្រិតខ្ពស់តាមការណែនាំរបស់លោក នួន ជា ទេ។ យើងធ្វើសហគមន៍តែម្តង។ ហើយនៅពេលដែលលោក ចែត និយាយអ៊ីចឹង អ្នកទាំងអស់គ្នាបែរមកមើលមុខខ្ញុំ ហើយមិត្តភក្តិខ្ញុំ ដូចជា មិត្តពី ហើយ មិត្តផាន ហ្នឹង គាត់ថាឲ្យខ្ញុំនិយាយទៅ ព្រោះខ្ញុំជាមួយលោក ចែត ហ្នឹងខ្ញុំអត់ដែលខ្លាចគាត់ ហើយខ្ញុំក៏និយាយ។ ខ្ញុំថា "អ៊ីចឹងមិនក្បត់ពីគោលការណ៍ខាងលើហើយ" ហើយគាត់ស្រែកមកឲ្យខ្ញុំវិញថា "ឥឡូវស្តាប់បញ្ជាគាត់ បើគាត់ឲ្យធ្វើអីយើងត្រូវធ្វើតាម។ ឲ្យទៅចាត់តាំងទៅ បើមិនបានឃោសនា ចាំគាត់ទៅនិយាយ"។ ដូចនៅឃុំខ្ញុំគាត់ទៅនិយាយមែន បាទ រួចប្រជាជនមិនសប្បាយចិត្តទេចំពោះការធ្វើសហគមន៍នេះ។ ពីព្រោះកន្លងមកយើងដឹងហើយថា ហូបរួម ធ្វើការរួម ស៊ីរួមនេះ វាមិនមែនតម្រូវតាមចិត្តរបស់ម្នាក់ៗបានទេ។ ពីព្រោះសូម្បីតែយើងនៅផ្ទះ ម៉្ងៃទៅចង់ហូបសម្លនេះ ម៉្ងៃចង់ហូបសម្លនោះ ហើយដល់ចូលទៅដល់ក្នុងទ្រុងហ្នឹង ស្រេចតែគេកំណត់។ អ៊ីចឹងគ្មានអ្នកណាមួយរីករាយចិត្តទេ សូម្បីតែខ្ញុំថ្នាក់ដឹកនាំក៏មិនៗពេញចិត្តប៉ុន្មានដែរ យើងធ្វើដោយបង្ខំ។

[១៤:៣០:០២]

ប៉ុន្តែយើងបញ្ចៀសយ៉ាងណា ចៀសវាងកុំឱ្យមានប្រតិកម្មនៅក្នុងប្រជាជនយើង ពីព្រោះយើងបារម្ភពីអាយុជីវិត។ បើកាលណានាំគ្នាប្រឆាំងទៅ គេចោទថាយើងជាខ្មាំងរបស់គេ។ នេះខ្ញុំសូមជម្រាបអ៊ីចឹង។ ហើយខ្ញុំសូមបញ្ជាក់អំពីបុគ្គលិកលក្ខណៈរបស់លោក ចែត ហ្នឹង។ លោក ចែត ហ្នឹងគាត់ អ្ហឺ! ខ្ញុំតែងនិយាយថា អ្វីក៏ដោយធ្វើកន្លងមក គាត់អត់ដែលជឿអ្នកក្រោមទេ។ ខ្ញុំលើកឧទាហរណ៍មួយ នៅក្រោយសំបូរហ្នឹងមានទំនប់ពីរ ទំនប់ពីសម័យសម្តេចសីហនុមួយ គេហៅថា ទំនប់បក្ស។ ទំនប់មួយទៀត ដែលលើកថ្មី គេហៅថា ទំនប់គោកស្វាយ។ ទំនប់គោកស្វាយហ្នឹងមានទឹក ហើយយើងអាចរៀបចំជាប្រឡាយបង្ហូរទឹកចូលស្រែបាន។ ខ្ញុំឱ្យយោបល់អ៊ីចឹងទៅ គាត់ថាខ្ញុំនេះ ចង់បំភ្លៃមាគ៌ារបស់គាត់។ គាត់ឱ្យជីកប្រឡាយៗ ហើយឱ្យបង្ហូរទឹកដាក់ប្រឡាយ ឱ្យមនុស្សជន់ដាក់ស្រែវិញ។ បានខ្ញុំ ខ្ញុំថាធ្វើរបៀបនេះខ្មាំងហើយ អត់ត្រឹមត្រូវទេ ហើយគេឱ្យខ្ញុំទៅជីកមួយខែដែរ ខ្ញុំអត់ទៅធ្វើទេ ខ្ញុំនៅដាំបាយ។ នេះរឿងជាក់ស្តែងមួយដែលខ្ញុំឃើញលក្ខណៈបុគ្គលិករបស់ឈ្មោះ ចែត នេះវាអត់ល្អ។ បាទ ខ្ញុំសូមអស់មតិ។

[១៤:៣១:៣១]

**ស៖** អរគុណ។ ជាការជាក់ស្តែង លោកបានឃើញចរិតរបស់លោក ចែត ហ្នឹងជាប្រធានស្រុកប្រឆាំងនឹងគោលការណ៍របស់ថ្នាក់លើ។ ចុះជាសព្វថ្ងៃ-- រាល់ថ្ងៃហ្នឹង ការអនុវត្តបទបញ្ជាពីស្រុកមកឃុំតើលោក ចែត ហ្នឹងគាត់ធ្វើតាមបទបញ្ជាមកពីតំបន់ដែរឬទេ តាមលោកដឹង?

**ឆ៖** ការងារដែលខ្ញុំដឹងច្បាស់ជាងគេ គឺតែការឱ្យរៀបចំ ក្រុមប្រវាស់ដៃ ក្រុមសហករណ៍ និងកម្រិតទាប កម្រិតខ្ពស់ ដែលថ្នាក់លើណែនាំខ្ញុំដឹងផ្ទាល់។ ឯការងារណែនាំជាបន្តបន្ទាប់ទៅទៀត ខ្ញុំមិនដែលបានទទួលពីថ្នាក់តំបន់ទេ ពីព្រោះលោក ចែត ហ្នឹងគាត់ជាគណៈតំបន់។ ប៉ុន្តែលោក ចែត នេះគឺក្រោយមក គឺត្រូវផ្លាស់ទៅនៅក្រចេះ ហើយក្រោយមកគេចាប់ខ្លួន។ ខ្ញុំសូមអស់មតិ។

**ស៖** ប្រជាពលរដ្ឋនៅក្នុងតំបន់របស់លោកយល់ច្បាស់ទេ អំពីពាក្យ "សហករណ៍" និង "សហគមន៍"?

**ឆ៖** ខ្ញុំដឹងថា បញ្ហាសហករណ៍ ប្រជាពលរដ្ឋនៅក្នុងឃុំរបស់ខ្ញុំ នៅក្នុងមូលដ្ឋានរបស់ខ្ញុំ មិនសូវដឹងច្បាស់ប៉ុន្មានទេ។ ពីព្រោះសហករណ៍ជាការងាររួម តែចែកភោគផលគ្នា។ រីឯសហគមន៍ ប្រជាពលរដ្ឋដឹងជាទូទៅ ពីព្រោះក្នុងការធ្វើសហគមន៍ យើងអត់បានឆ្លងកាត់សហករណ៍ ព្រោះយើងចាប់ធ្វើ

សហគមន៍តែម្តង។ អ៊ីចឹងគឺប្រជាជនយល់ច្បាស់ណាស់ថា ធ្វើរួម ស៊ីរួម។ ខ្ញុំសូមអស់មតិ។

[១៤:៣៣:៤៤]

**លោក សុន អរុណ៖**

ខ្ញុំសូមអរគុណលោកសាក្សី ខ្ញុំសូមអរគុណលោកប្រធាន។ ខ្ញុំអស់មានសំណួរតទៅទៀតហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុម-- អ៊ូ! មេធាវីការពារក្តីលោក អៀង សារី។

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សួស្តីសហព្រះរាជអាជ្ញា សហភាតាទាំងអស់ជាថ្មី។ ហើយសួស្តីលោកអ្នកទាំងឡាយចូលរួមសវនាការនៅក្នុងបន្ទប់ក្តី នៅក្រៅបន្ទប់ក្តី។ ហើយសួស្តីលោក យុន គីម។ ខ្ញុំ អាង ឧត្តម ជាសហមេធាវីការពារលោក អៀង សារី។ នៅពេលនេះ ខ្ញុំគ្មានសំណួរនឹងសួរលោកទេ។ ក៏ប៉ុន្តែយ៉ាងណាក្តី តាងនាមលោក អៀង សារី ខ្ញុំសូមអរគុណលោក ដែលបានឡើងមកផ្តល់សក្ខីកម្មនៅតុលាការ ដើម្បីជួយស្វែងរកការពិត និងយុត្តិធម៌។ សូមអរគុណលោកប្រធាន។

[១៤:៣៤:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាកិច្ចបន្ត គឺដល់វេទិកាក្រុមមេធាវីការពារក្តីលោក ខៀវ សំផន តើមានសំណួរ ត្រូវការពេលវេលាប្រហែលប៉ុន្មានដែរលោកមេធាវី?

**លោក អាកឡូរ វ៉ែកគែន៖**

បាទ លោកប្រធានខ្លីទេ ខ្លីមែនទែន។ ខ្ញុំមានសំណួរតែពីរបីទេ លោកប្រធាន។

[១៤:៣៥:២៧]

**សួរដោយលោក អាកឡូរ វ៉ែកគែន៖**

**ស៖** លោកសាក្សីគឺជាសំណួរដែលខ្ញុំចង់ដឹងទេ។ ខ្ញុំឆ្ងល់គឺថាមានចំណុចមួយទាក់ទងទៅនឹងការចូលប្រលូកក្នុងបដិវត្តន៍របស់លោកដែលខ្ញុំមិនយល់ ខ្ញុំហាក់ដូចជាថាឃើញមាន-- គឺថាមានភាពខុសគ្នា

នៃសំណួររបស់លោកដែលលោកឆ្លើយតបកាលពីម្សិលមិញ ហើយនិងថ្ងៃនេះ។ ម្សិលមិញគឺថា នៅទំព័រទី២២-២៣ នៃសំណៅ-- នៃប្រតិចារឹកជាភាសាបារាំងគឺនៅទំព័រទី២០ ហើយនិងជាភាសាអង់គ្លេស-- នៅវគ្គនោះគឺថា គេសួរលោកថា "មុនពេលដែលលោកចូលក្នុងបក្ស តើលោកមានបានទទួលរង-- ទទួលការបណ្តុះបណ្តាល ឬក៏ការណែនាំទាក់ទងនឹងមាគ៌ាបក្សដែរឬទេ?" លោកបានឆ្លើយតបថា "បន្ទាប់ពីរដ្ឋប្រហារស្ថានភាពច្របូកច្របល់ ហើយមានអ្នកឆ្លៀតឱកាសនិយមមាន អ្នកជាតិនិយមជាច្រើនក្រុម ហើយនិងមានមនុស្សស្លាប់ផងដែរ ហើយខ្ញុំមិនបានចូលក្នុងក្រុមទាំងអស់នោះទេ ព្រោះខ្ញុំភ័យខ្លាច ខ្ញុំគិតថាចលនាបដិវត្តន៍មិនអាក្រក់នោះទេ។ ខ្ញុំទទួលការបណ្តុះបណ្តាល ហើយថ្នាក់ស្រុកបានជ្រើសរើសយកខ្ញុំ ហើយឲ្យខ្ញុំចូលទៅក្នុងបក្សក្នុងឋានៈជាសមាជិក។"

[១៤:៣៦:៥៥]

ហើយថ្ងៃនេះ មានគេសួរលោកថា ខាងដើមបណ្តឹងរដ្ឋប្បវេណីសួរលោក សូមឲ្យលោកពន្យល់ថា "ហេតុអ្វីបានជាលោកចូលចលនាបដិវត្តន៍ តើដោយស្ម័គ្រចិត្ត ឬក៏យ៉ាងណា?" លោកបានឆ្លើយថា "ក្នុង-- ដោយសារខ្ញុំជាប្រជាជននៅភូមិវត្តខ្សាន: បើ-- កាលនោះបើសិនជាខ្ញុំមិនចូលរួម-- ចូលចលនាវិញនោះទេ គឺថាខ្ញុំប្រហែលជាមានប្រថុយប្រថាននឹងគ្រោះថ្នាក់ ហើយដើម្បី-- ខ្ញុំចូលនោះដើម្បីយល់ពីបដិវត្តន៍ ហើយដើម្បីការពារខ្លួនខ្ញុំផង និងការពារអ្នកដទៃផង។" តើការពន្យល់មួយណាដែលខ្ញុំត្រូវចាំ? តើលោកអាចពន្យល់ពីភាពនៃចម្លើយខុសគ្នាទាំងពីរនេះដែលលោកឲ្យ-- ដែលលោកឆ្លើយ-- ផ្តល់ឆ្លើយទៅគេនេះក្នុងថ្ងៃតែមួយតែម្តង មានចម្លើយពីរខុសគ្នាយ៉ាងដូច្នេះ តើខ្ញុំត្រូវជ្រើសរើសយកចម្លើយមួយណា?

[១៤:៣៨:០៨]

**លោក យុន គីម៖**

**ឆ៖** ពាក់ព័ន្ធនឹងការចូលរួមបដិវត្តន៍គឺ ដូចខ្ញុំបានជម្រាបជូនអ៊ីចឹង គឺក្រោយរដ្ឋប្រហារ ១៧ មេសា ឆ្នាំ១៩៧០ នេះគឺមានចលនាមុននឹងមានបដិវត្តន៍ខ្មែរក្រហមមកដល់ មានចលនាដូចជានៅខាងស្រុកសំបូរខ្ញុំមានពួក យុត ឧត្តមវង្សវឌ្ឍនា ពួកនេះថាខ្លួនគេជាអ្នកមកជួយ ជួយជាតិបាទ។ ពេលនោះហើយដែលនាំប្រជាជននៅស្រុកសំបូរនេះទៅ-- មកកំពង់ធំ មកវ៉ៃពួក លន់ នល់ មកហ្នឹងងាប់មួយចំនួនធំដែរ។ បាទ អ្នកមួយចំនួនទៀតដែលនៅរស់រត់ទៅផ្ទះវិញ ខ្ញុំឃើញសភាពហ្នឹងគឺខ្ញុំអត់ចូលរួមជាមួយពីព្រោះមើលបុគ្គលិកលក្ខណៈរបស់បុគ្គល របស់ក្រុម យុត ឧត្តមវង្សវឌ្ឍនា នេះវាជាមនុស្សដែលយើង

មើលទៅវាមិនគួរឲ្យយើងចូលរួមបាន។

[១៤:៣៩:០៥]

បាទ ដល់ក្រោយមកយើងឃើញថា មានចលនាបដិវត្តន៍ខ្មែរក្រហមនេះចូលមកដល់ ខ្ញុំក៏បានត្រូវពេលគេចុះមកតាមភូមិអីចឹង ក៏គេបានហៅឲ្យរៀនសូត្រអីចឹងទៅ។ ក្រោយមកគេហៅខ្ញុំទៅរៀនសូត្រនៅសំបូរអីចឹងទៅ បាទ ដល់ទៅដល់លោក ចែត ហ្នឹងហើយគាត់អ្នកហៅខ្ញុំមុនគេ គាត់អត់ៗមានណែនាំខ្ញុំអីប៉ុន្មានទេ គាត់បោះសៀវភៅបីបួនក្បាលយកមកឲ្យខ្ញុំថា រៀនខ្លួនឯងទៅ ចេះមើលហើយរៀនទៅ។ បាទ ដល់អីចឹងទៅគេហៅខ្ញុំជាហូរហែទៅប្រជុំទៅអី ទៅចូលរួមមីទ្ទិងចូលរួមអីអីចឹងទៅ។ បាទ ដល់ពេលក្រោយមកក៏គេបានប្រគល់តួនាទីឲ្យខ្ញុំធ្វើជាមេឃុំនៅវឌ្ឍនៈហ្នឹងទៅ។ នេះខ្ញុំសូមជម្រាបអីចឹង ហើយក្នុងការចូលនេះ ខ្ញុំគិតថាបើសិនណាជាយើងមិនចូលរួមក្នុងចលនាបដិវត្តន៍យើងអត់មានដឹងបញ្ហាទេ។ អត់ដឹងបញ្ហា បើសិនណាជាគេចោទមកលើយើងយ៉ាងម៉េចក៏បានដែរ។ បើយើងចូលរួម យើងអាចដឹងជម្រៅនៃបញ្ហា ហើយបើយើងប្រឡូកហើយ ដើម្បីចេះរស់ យើងត្រូវប្រយ័ត្នប្រយែងយ៉ាងម៉េច ខ្ញុំសូមលើកឧទាហរណ៍មួយជាក់ស្តែងទៅចុះ។ ខ្ញុំដែលរស់ ដូចខ្ញុំជម្រាបអីចឹង ថ្ងៃដើមឆ្នាំ៧៨ យោធាទៅកាន់កាប់នៅស្រុកសំបូរ។ មេឃុំស្ទើរទាំងអស់នៅស្រុកសំបូរ គេចាប់រលីង នៅសល់តែខ្ញុំ។ មូលហេតុអី? មូលហេតុ ដោយខ្ញុំឃើញថា យោធា ជាមួយនឹងអាជ្ញាធរនៅជំនាន់នោះអត់សូវត្រូវគ្នា អត់សូវត្រូវគ្នា ហើយកងពលនៅជុំវិញខ្ញុំមានពីរ មានកងពល៩២០ និង៨០១។ អាហ្នឹងកងពលដែលទីតាំងគេនៅរតនគិរីនៅអី គ្រាន់មានបោះទីតាំងនៅកន្លែង ហើយពួកទាំងអស់ហ្នឹង ខ្ញុំស្គាល់មេៗគេ។ ដល់អីចឹងចេះតែរាប់អានគ្នាទៅ ពឹងពាក់គ្នាទៅ ទំនាក់ទំនងគ្នាទៅ គេត្រូវការស្អីខ្ញុំ ខ្ញុំចេះតែជូនទៅ ត្រូវការទូក ខ្ញុំឲ្យទូក ត្រូវការគោ ខ្ញុំឲ្យគោ ត្រូវការក្របី គេឲ្យក្របីអីចឹង។ ដល់អីចឹងទំនាក់ទំនងល្អ ដល់ពេលគេប្រើបអីចឹងមក ខ្ញុំរួចខ្លួន តែអនុខ្ញុំក៏គេចាប់ ពេទ្យខ្ញុំគេចាប់។ អីចឹងបានថា ក្នុងសភាពការណ៍នេះ បើមិនចេះរស់ត្រូវងាប់។ ខ្ញុំសូមអស់មតិ។

[១៤:៤១:៣៦]

**ស៖** បាទ សូមអរគុណ ដែលបានឆ្លើយយ៉ាងដូច្នេះ។ ខ្ញុំកត់សម្គាល់ឃើញថា ឧទាហរណ៍ ដែលលោកទើបនឹងផ្តល់ឲ្យនេះ គឺថា ទាក់ទងនឹងឆ្នាំ១៩៧៨ តើលោកអាចរំឭកជូនអង្គជំនុំជម្រះ បានដែរឬទេថាលោកចូលចលនាបដិវត្តន៍នៅឆ្នាំណា?

**ឆ៖** ខ្ញុំចូលចលនាបដិវត្តន៍តាំងពីឆ្នាំ១៩៧១។ ១៩៧១។

**សៈ** បាទ ដូច្នេះដើម្បីឲ្យយល់ខ្លឹមសារ ចម្លើយរបស់លោកឲ្យបានកាន់តែច្បាស់លាស់ គឺថា តើនៅពេលដែលលោកចូលចលនាបដិវត្តន៍នៅឆ្នាំ១៩៧១នោះ តើលោកត្រូវបានគេបង្ខំដោយហេតុ ដោយមូលហេតុណាមួយ ដែលលោកអាចពន្យល់យើងបាន ឬក៏ជាការស្ម័គ្រចិត្តរបស់លោក? ចង់និយាយថា ឆ្នាំ១៩៧១ នេះ?

**ឆះ** ការដែលខ្ញុំចូលរួមចលនាបដិវត្តន៍នៅឆ្នាំ១៩៧១ គឺជាការមួយដែលខ្ញុំមានគំនិតថា បានចូលរួមក្នុងការអភិវឌ្ឍន៍ប្រទេសជាតិដែរ ពីព្រោះខ្ញុំរាល់ដំណាក់ការ ក៏ខ្ញុំ *(ឮមិនច្បាស់)* មានគំនិតមួយថា ចង់ធ្វើយ៉ាងណាឲ្យជីវភាពប្រជាជនបានរុងរឿង។ បាទហើយ ស្របគ្នានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានគំនិតមួយ ដែលគិតគូរដោះស្រាយទឹកអីជូនប្រជាជនអ៊ីចឹង ខ្ញុំរីករាយណាស់បាទ។ នេះខ្ញុំសូម ជម្រាបបញ្ជាក់អ៊ីចឹង។ ខ្ញុំសូមអស់មតិហើយ។

[១៤:៤៣:៣៥]

**សៈ** បាទ សូមអរគុណលោក។ តែដើម្បីឲ្យច្បាស់លាស់តែម្តង គឺថា នៅឆ្នាំ១៩៧១ នោះលោកមិនត្រូវបានគេបង្ខំឲ្យចូលក្នុងចលនាបដិវត្តន៍ទេ តើអ៊ីចឹងមែនទេ?

**ឆះ** បាទ នៅឆ្នាំ១៩៧១នេះ គឺការចូលរួមក្នុងចលនាបដិវត្តន៍នេះ គឺចូលដោយ បាទដោយចិត្តខ្លួនឯង បាទ មិនមានអ្នកណាបង្ខំទេបាទ។ ខ្ញុំសូមអស់។

**សៈ** បាទ សូមអរគុណ។ ហើយខ្ញុំនិយាយដោយខ្លី ហើយក្រោយមកបញ្ចប់ ហើយជម្លោះរវាងយោធា ហើយនិងអាជ្ញាធរ ដែលកើតមានឡើងនៅឆ្នាំ១៩៧៨ តើលោកដឹងអំពីមូលហេតុ នៃជម្លោះរវាងយោធា ហើយនិងអាជ្ញាធរដែនដីនេះទេ? បើសិនជាលោកមិនដឹងមូលហេតុទេ គឺថា លោកជម្រាបប្រាប់យើង បើមិនដឹង ក៏យើង-- បើសិនជាលោកមិនដឹងមិនបាច់និយាយទេ បើលោកដឹងសូមជម្រាបជូនអង្គជំនុំជម្រះ។

**ឆះ** ពាក់ព័ន្ធនឹងបញ្ហាជម្លោះយោធា ជាមួយនឹងអាជ្ញាធរខេត្តអីនេះ ខ្ញុំអត់ដឹងច្បាស់មកពីមូលហេតុអីទេ ប៉ុន្តែថ្ងៃមួយ ខ្ញុំដឹងថា មានឈ្មោះ សុវណ្ណ។ លោក សុវណ្ណ នេះ គឺជាភស្តុភារកងពល៩២០។ គាត់មកជួបខ្ញុំនៅសំបូរ កាលហ្នឹងខ្ញុំនៅធ្វើមេឃុំសំបូរ។ គាត់ថា គាត់យកសំបុត្រលោក សាន។ លោក សាន ហ្នឹង ប្រធានកងពល៩២០ មកឲ្យខ្ញុំ។ នៅក្នុងលិខិតនោះ គាត់សុំគោខ្ញុំ៥០ក្បាល បាទ។ ដល់សុំគោខ្ញុំ៥០ក្បាល ខ្ញុំថាអត់អីទេ គោ៥០ក្បាល មិនពិបាកទេ មាន ប៉ុន្តែឲ្យស្រុកដឹងផង អ៊ីចឹង សុវណ្ណ ឯងទៅជួបស្រុកជាមួយខ្ញុំ។ បានលោក សុវណ្ណ ឆ្លើយថា អត់ទេ បង គាត់ថា បង ចង់និយាយថា បងសាន

ហ្នឹងហើយ។ បងផ្តាំមកថា ឲ្យមកជួបតែបងឯងមួយទេ ឲ្យមកជួបតែនឹងខ្ញុំទេ បើបងឯងមិនឲ្យទៅវិញ។ អ៊ីចឹង ខ្ញុំអត្តនោម័តិ ខ្ញុំឲ្យគោ៥០ក្បាលហ្នឹងទៅ។ ហើយដល់ពេលគេយកកាណូតពីរមកយកកប៉ាល់ អាកប៉ាល់ពីរជាន់ ពីរមកយកគោហ្នឹង ស្រុកគេឃើញដែរ គេថា យី! គោយកទៅណា? ខ្ញុំថាកងពលសុំ គេក៏អត់ថាអីខ្ញុំទៅ វាចប់ទៅដែរបាទ។ ខ្ញុំ-- ដោយមានបច្ច័យនេះហើយ ដែលខ្ញុំសន្និដ្ឋានថាថ្នាក់ដឹកនាំខាងរដ្ឋអំណាច ថ្នាក់ស្រុក ថ្នាក់ខេត្ត ជាមួយនឹងកងពលមិន-- ពិតជាមិនស៊ីសង្វាក់គ្នាហើយបាទ។ បានជា សុវណ្ណ ថាបើខ្ញុំមិនឲ្យ មិនចាំបាច់ទៅឯណាទៀតទេ។ ខ្ញុំសូមអស់មតិ។

[១៤:៤៦:៤៥]

**លោក អាកទូរ វែកតែន៖**

បាទ លោកប្រធាន ខ្ញុំអស់មានសំណួរសួរទៅកាន់សាក្សីនេះទៀតហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណច្រើនលោក យុន គីម។ ឥឡូវនេះ កិច្ចដំណើរការសវនាការពិភាក្សាស្តាប់សក្ខីកម្មរបស់លោក អង្គជំនុំជម្រះបានស្តាប់ចប់សព្វគ្រប់ហើយ ហើយអង្គជំនុំជម្រះសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេលពីរថ្ងៃ ប្រកបដោយភាពអត់ធ្មត់ ខិតខំអស់ពីសមត្ថភាពនិងលទ្ធភាពដែលមាន។ ហើយរួមវិភាគទាន ក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ ហើយលោក យុន គីម អាចវិលត្រឡប់ទៅលំដ្ឋានរបស់លោកវិញ ឬក៏ទៅកាន់គោលដៅដែលលោកមានបំណងទៅហើយ ហើយសូមឲ្យលោកធ្វើដំណើរប្រកបដោយសុវត្ថិភាព។ មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីគាំ-- អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការបញ្ជូនសាក្សីនេះ វិលត្រឡប់ទៅកាន់លំដ្ឋានរបស់គាត់ ឬក៏គោលដៅដែលគាត់មានបំណងទៅបានហើយ។ ហើយកិច្ចដំណើរការសវនាការនៅម៉ោងបន្ទាប់នេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-321។ សូមភាគី និងសាធារណជនជ្រាប។

[១៤:៤៨:០១]

ហើយឥឡូវនេះ ក៏ដល់ពេលសមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ហើយចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី ប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៨នាទី ដល់ម៉ោង ១៥:០៨នាទី)*

[១៥:០៨:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-321 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៥:១០:៤៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកសាក្សី! តើលោកឈ្មោះអ្វីដែរ លោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ?

**លោក ខៀវ នៅ៖**

**ឆ៖** សូមគោរពលោកប្រធាន សូមសួរបញ្ជាក់ថែមបន្តិចទៀត។

**ស៖** តើលោកអាចប្រាប់នាមត្រកូល និងនាមខ្លួនរបស់លោកបានឲ្យអង្គជំនុំជម្រះដឹងបានដែរទេ? តើលោកមាននាមត្រកូល និងនាមឈ្មោះអ្វីដែរ?

**ឆ៖** ឈ្មោះ ខៀវ នៅ។

**ស៖** បាទ អរគុណ។ ក្រៅពីឈ្មោះ ខៀវ នៅ ហ្នឹង តើលោកដែលប្រើប្រាស់ឈ្មោះអ្វីផ្សេងទៀតដែរឬទេ?

**ឆ៖** មិនដែលទេ គឺឈ្មោះតែមួយហ្នឹង។

**ស៖** បាទ អរគុណ។ តើលោកអាចប្រាប់អំពីថ្ងៃខែឆ្នាំកំណើតរបស់លោកបានដែរទេ? តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ថ្ងៃសកល ខែសកល មិនចាំទេ ចាំតែចន្ទ-- តាមចន្ទគតិ។ កើតថ្ងៃសៅ ខែមិគសិរ អំ

ខែបុស្ស ឆ្នាំចរ មកទល់សព្វថ្ងៃនេះអាយុ៧៩ ហើយ។

[១៥:១២:១៥]

**ស៖** បាទ អរគុណ។ ហើយសព្វថ្ងៃលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** សព្វថ្ងៃនេះ ខ្ញុំមិនបានធ្វើអីធំដុំទេ គ្រាន់តែនៅមើលកូន មើលប្រពន្ធ មើលការខុសត្រូវ ហើយនិងទៅជួយវត្ត ជួយខាងវត្ត។

**ស៖** អរគុណ។ តើឪពុកបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឈ្មោះ ណុប ឯនាមត្រកូលគឺ ខៀវ ណុប ដែរ។

**ស៖** បាទ អរគុណ។ ចុះម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអ្វីដែរ?

**ឆ៖** អៀង សួរ នាមត្រកូល។

**ស៖** ចុះប្រពន្ធរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ឈ្មោះ អឿន នាមត្រកូល ងិន អឿន។

[១៥:១៣:២០]

**ស៖** បាទ អរគុណ។ តើលោកមានកូនប៉ុន្មាននាក់?

**ឆ៖** មានកូនប្រាំមួយនាក់។

**ស៖** បាទ អរគុណ។ តាមក្រឡាបញ្ជី-- តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ បានរាយការណ៍ថា តាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយភាគីនៃរឿងក្ដីនេះទេ គឺជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាជាមួយនឹងជនជាប់ចោទទាំងបីនាក់ដែរ តើជាការពិតមែនដែរឬទេ?

**ឆ៖** រឿងនេះពិតមែនហើយ។

**ស៖** តើលោកបានធ្វើសម្បថនៅមុខអ្នកតាដំបងដែកហើយឬនៅ មុនពេលចូលមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បាទ ធ្វើរួចសព្វគ្រប់ហើយ។

[១៥:១៤:២៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាក្សីដូចខាងក្រោមនេះ៖

លោក ខៀវ នៅ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធនៅក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថាដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ករណីយកិច្ចក្នុងនាមជាសាក្សី លោកត្រូវតែផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ។ លោកត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះតាំងសំណួរចំពោះលោក លើកលែងតែករណីឆ្លើយតបទៅនឹងសំណួរ ឬធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។

លោកជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ ធ្លាប់បានមានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការអង្កេត អ៎!ធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ខៀវ នៅ កន្លងមកពីប៉ុន្មានឆ្នាំមុន លោកធ្លាប់បានទទួលនូវការធ្វើសម្ភាសជាមួយនឹងមន្ត្រីទៅពីការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**លោក ខៀវ នៅ៖**

**ឆ៖** ធ្លាប់បានសម្ភាស។

**ស៖** លោកចងចាំទេ ថាតើការធ្វើសម្ភាសហ្នឹង លោកបានធ្វើសម្ភាសប៉ុន្មានដង ហើយធ្វើនៅពេលនៅក្នុងឆ្នាំណា ហើយធ្វើនៅកន្លែងណាដែរ?

[១៥:១៦:៣០]

**ឆ៖** ឆ្នាំមុននោះ មិនបានចាំថាឆ្នាំណា ឆ្នាំណាទេ ហើយប៉ុន្តែក្នុងឆ្នាំនេះមានបានម្តង ហើយឆ្នាំមុននោះម្តង។ កន្លងហ្នឹងប៉ុន្មានទេ មិនបានចាំថាឆ្នាំណាៗទេ។

**ស៖** អ៊ីចឹងបានន័យថា គេធ្វើសម្ភាសលោកពីរដង ឬក៏ធ្វើតែម្តងទេ?

**ឆ៖** សម្ភាសហ្នឹងតាមនឹកឃើញពីរដង។

**ស៖** ឈប់! ធ្វើពីរដង ហើយធ្វើនៅកន្លែងណាដែរ លោក ខៀវ នៅ?

**ឆ៖** ធ្វើនៅអន្លង់វែង។

**ស៖** ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យមើល ឬក៏បានអាន ឬអាន ស្តាប់ការអានរបស់អ្នកម្នាក់នូវកំណត់ហេតុស្តាប់ចម្លើយរបស់លោកដែលបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

[១៥:១៧:៤៩]

**ឆ៖** បានស្តាប់ ប៉ុន្តែចំណុចខ្លះ ខ្ញុំនឹកបកក្រោយទៅ ឃើញកត់ត្រាហ្នឹងមានខ្វះបន្តិចបន្តួច។

**ស៖** អ៊ីចឹងមានន័យថា តាមសមត្ថភាពដែលលោកអាចដឹង អាចចងចាំបានហ្នឹង គឺថាការស្តាប់ចម្លើយដែលលោកបានស្តាប់ការអាន ឲ្យស្តាប់ដើម្បីរំឭកការចងចាំហ្នឹង គឺពិតជាមានភាពត្រឹមត្រូវ និងស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសពីមុនៗមក លើកលែងតែចំណុចបន្តិចបន្តួចដែលមានភាពលម្អៀង ឬក៏ខុសគ្នា។ អ៊ីចឹងពិតមែនទេ?

**ឆ៖** ពិតមែនហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមជម្រាបតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាតាំងសំណួរចំពោះសាក្សីរូបនេះមុនភាគីឯទៀត។

សូមអញ្ជើញ!

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីឲ្យលោក អៀង សារី!

[១៥:១៨:០៣]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ខ្ញុំសូមការបំភ្លឺថា ហេតុអីសាក្សីនេះ អត់មានមេធាវីប្រឹក្សា? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សាក្សីរូបនេះ លោកបានអះអាងថា លោកមិនចាំបាច់ត្រូវការមេធាវីប្រឹក្សាទេ។ អ៊ីចឹងហើយបានជាអង្គជំនុំជម្រះដំណើរការដោយមិនចាំបាច់មានមេធាវីទេ។

សូមអញ្ជើញ!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** សួស្តីលោក ខៀវ នៅ។ ថ្ងៃនេះ ខ្ញុំ វ៉េង ហ៊ត់ មកពីការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំសូមសួរសំណួរមួយចំនួនទាក់ទងទៅនឹងជីវិតរបស់លោកមុនខែមេសា ឆ្នាំ១៩៧៥ ដែលជាជីវប្រវត្តិ ហើយបន្ទាប់មកនឹងសួរអំពីព្រឹត្តិការណ៍ដែលលោកបានឃើញ បានដឹង នៅក្នុងឆ្នាំ៧៥ និង៧៦។ សំណួរទីមួយរបស់ខ្ញុំ ខ្ញុំសូមអាន ឬក៏សូមរំឭកឡើងវិញនូវចម្លើយរបស់លោកដែលបានផ្តល់ឲ្យចៅក្រមស៊ើបសួរថា លោកបួសជាសង្ឃនៅក្នុងឆ្នាំ១៩៥១ នៅវត្តត្រពាំងធំ នៅក្នុងឃុំត្រពាំងធំ ស្រុកត្រាំកក់ ហើយលោកបាននិយាយថា បានជួប តាម៉ុក ដែលបួសជាសង្ឃនៅវត្តនេះដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[១៥:២១:១៦]

**លោក អាកទូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំឆ្ងល់ថា ហេតុអ្វីក៏ព្រះរាជអាជ្ញាចាប់ផ្តើមដោយរំឭកដល់សាក្សីអំពីពាក្យពេចន៍ដែលលោកសាក្សីនេះបាននិយាយកាលពីរបីឆ្នាំមុនមកហើយ។ ខ្ញុំមិនយល់ពីហេតុផលនៃការសួរយ៉ាងដូច្នេះសោះ ព្រោះថាសាក្សីនេះមកទីនេះកំពុងតែផ្តល់សក្ខីកម្ម ហើយយើងនៅទីនេះដើម្បីទទួលយកចម្លើយគាត់ដោយលក្ខណៈធម្មជាតិ អ៊ីចឹងហើយការរំឭក ការចងចាំសាក្សីនេះយើងធ្វើក្នុងករណីចាំបាច់តែប៉ុណ្ណោះ។ ហើយអ៊ីចឹងខ្ញុំគិតថា ដូចជាមិនមានការចាំបាច់អីទេ ត្រឹមត្រូវអីទេ ត្រូវចាប់ផ្តើមភ្លាមសួររំឭកគាត់ភ្លាម ហើយមិនទាន់ទាំងបាននិយាយអំពីប្រធានបទអ្វីដែលពាក់ព័ន្ធផងនោះ។

[១៥:២២:០៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមឆ្លើយតបទៅនឹងមេធាវីការពារក្តី។ មូលហេតុដែលយើងប្រើវិធីសាស្ត្រនេះ គឺថាតាមពិតគឺជាកិច្ចព្រមព្រៀង អ៎! គឺជាកិច្ចប្រឹងប្រែងរបស់យើងដើម្បីអនុវត្តនូវសេចក្តីសម្រេច អ្វីដែលសហសេវិករបស់ខ្ញុំធ្វើនេះ គឺថាដើម្បីឲ្យសាក្សីនឹកឃើញនូវឡើងវិញនិងអំពីចម្លើយរបស់គាត់នៅក្នុងចម្លើយពេលមុន

ដែលវាមិនមែនជាបញ្ហាចម្រូងចម្រាសនោះទេ ហើយអង្គជំនុំជម្រះក៏បានណែនាំថា ឲ្យផ្តោតអារម្មណ៍ទៅលើអ្វីដែលវាមានសារៈប្រយោជន៍។ ដូច្នេះហើយបានយើងគោរពទៅតាមហ្នឹង ហើយ នេះហើយជាវិធីសាស្ត្រដែលសហសេវិកខ្ញុំ និងខ្ញុំនឹងអនុវត្តតទៅ។ រីឯបញ្ហាទាក់ទងទៅនឹងប្រវត្តិបដិវត្តន៍កម្ពុជាជាដើមហ្នឹងគឺយើងមិនលម្អិតជ្រៅទេ ដោយសារថា យើងគោរពទៅតាមការណែនាំ ដីកា ការសម្រេចរបស់តុលាការ ហើយនិងគោរពទៅតាមនីតិវិធី ហើយយើងនិងត្រូវធ្វើសំណួរទៅតាមគំនិតនេះបាទ។

[១៥:២៣:២០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកឆ្លើយតបលើសេចក្តីតបភាគីម្ខាងទេ លោកមេធាវី។

[១៥:២៣:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៣:៥៥]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន គ្មានប្រសិទ្ធភាព។

លោកតំណាងសហព្រះរាជអាជ្ញាអាចតាំងសំណួរសាជាថ្មីចំពោះសាក្សី!

ហើយសាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** ខ្ញុំរំឭកសាក្សីឡើងវិញចុងក្រោយ។ ខ្ញុំសួរថា លោកបាននិយាយថា លោកបានជួប តាម៉ុក ដែលបួសនៅវត្តត្រពាំងធំនេះ។ អ៊ីចឹងសំណួរខ្ញុំសួរថា តើលោកៗដឹងថា តាម៉ុក នោះបួសនៅត្រពាំងធំនេះអស់រយៈពេលប៉ុន្មានដែរ?

**លោក ខៀវ នៅ៖**

**ឆ៖** មិនចាំឆ្នាំពិតប្រាកដទេ ប៉ុន្តែប្រហែលជាបើគាត់បានបួសនេន បួសភិក្ខុអីប្រហែលជាដប់ឆ្នាំ ឬតិចជាងដប់ឆ្នាំ។

**ស៖** អរគុណលោក។ តើលោកជិតដិតជាមួយនឹង តាម៉ុក ដែរទេនៅក្នុងអំឡុងពេលនុ៎ង?

**ឆ៖** សូមសួរបញ្ជាក់បកទៅវិញ ថាតើក្នុងពេលនុ៎ងហ្នឹង គឺពេលណា?

**ស៖** ខ្ញុំសួរលោកឡើងវិញ ថាលោកបានជួប តាម៉ុក ហើយលោកប្រាប់ថា តាម៉ុក ហ្នឹងនៅវត្តត្រពាំងធំហ្នឹង ប្រហែលជាដប់ឆ្នាំ។ អ៊ីចឹង ខ្ញុំចង់សួរលោកថា តើពេលនោះ ដែលលោកជួប តាម៉ុក ហើយលោកដឹងថា តាម៉ុក បួស១០ឆ្នាំនោះ ពេលនុ៎ងលោកជិតស្និទ្ធជាមួយ តាម៉ុក ឬទេ?

[១៥:២៦:០៦]

**ឆ៖** ពេលដែលគាត់នៅបួស ខ្ញុំនៅក្មេង ហើយមិនទាន់នៅវត្តផង គ្រាន់តែដឹងថាបួស ថាអីឯភាពជិតស្និទ្ធនោះ របៀបក្មេង និងលោក។ ក្មេង ដែលមិនទាន់នៅវត្ត។

**ស៖** សំណួរបន្តទៀត។ តើលោកដឹងថា តាម៉ុក គាត់បានសឹក ហើយតើគាត់ធ្វើការអ្វីបន្ទាប់មកទៀត?

**ឆ៖** គាត់លាចាកសិក្ខាបទមក ខ្ញុំនៅក្មេងមិនទាន់ដឹងក្ដីសព្វគ្រប់ទេ តែមិនឃើញគាត់ធ្វើអីទេ សឹកមកហើយគឺ រៀបការគ្រួសារ ប្ដីប្រពន្ធ ជាមួយនឹងភរិយារបស់គាត់ ហើយធ្វើការងារអីៗមិនឃើញមានធ្វើអីទេ នៅរកស៊ីធម្មតា។

**ស៖** កាលនោះនៅប្រហែលជាអំឡុងឆ្នាំណាដែរ លោកចាំទេ?

**ឆ៖** ជំនាន់នោះ ខ្ញុំនៅក្មេងមិនទាន់បានរៀនសូត្រអីផងនៅ-- ប៉ុន្តែគិតរយៈកាល កាលណោះកើតឥស្សរៈនៅម្ដុំស្រុកត្រាំកក់ នៅក្បែរភ្នំហ្នឹង កើតឥស្សរៈហៅថា ឥស្សរៈត្រពាំងស្ដៅ តែមិនដឹងឆ្នាំប៉ុន្មានទេ បើតាមការស្មានរង្វង់ឆ្នាំសែ១ជាងបន្តិចបន្តួចប៉ុណ្ណឹង មុនឥស្សរៈទូទាំងប្រទេស។

**ស៖** អរគុណលោក ខៀវ នៅ។ ខ្ញុំនឹងបន្តសំណួរទៀត។ លោកបាននិយាយនៅក្នុងចម្លើយជាមួយចៅក្រមស៊ើបអង្កេតថា នៅឆ្នាំ១៩៧៥ តាម៉ុក ជាលេខាភូមិភាគនិរតី។ តើលោកដឹងថាគាត់ជាលេខាភូមិភាគនេះ តាំងពីពេលណា?

[១៥:២៩:១០]

**ឆ៖** ក្នុងការដឹងនេះ មិនដឹងជាផ្លូវការមែនទែនច្បាស់លាស់ទេ គ្រាន់តែឮៗគេថា ដូច្នេះ មិនកំណត់ថាឆ្នាំណាជាឆ្នាំណាទេ។

**ស៖** ខ្ញុំសួរលោកទៀត ទាក់ទងជាមួយនឹងភូមិភាគនិរតី តើភូមិភាគនេះមានស្រុកណាខ្លះជាផ្នែក នៃភូមិភាគហ្នឹង?

**ឆ៖** បើរាប់ជាស្រុកច្រើនណាស់ ខ្ញុំមិនចាំទេ។

**ស៖** អរគុណលោក។ តើលោកមានទំនាក់ទំនងជាមួយ តាម៉ុក មុនខែមេសា ឆ្នាំ៧៥ ដែរទេ?

**ឆ៖** កាលណោះ ខ្ញុំនៅបួស នៅក្នុងវត្តត្រពាំងធំ។ គាត់ដើរធ្វើការតែងតែចូលមកវត្ត ហើយគាត់និយាយពីសភាពការណ៍ផ្សេងៗ។ ការទាក់ទងគឺមានកម្រិតប៉ុណ្ណឹង។

**ស៖** អរគុណលោក។ ខ្ញុំសូមរំឭកចម្លើយលោកសាឡើងវិញទៀត លោកនិយាយនៅក្នុងចម្លើយជាមួយចៅក្រមស៊ើបអង្កេតថា នៅក្នុងខែមេសា ឆ្នាំ៧៥។ ខ្ញុំរំឭកលោកឡើងវិញ ថានៅក្នុងខែមេសា ឆ្នាំ១៩៧៥ លោកនៅជាសង្ឃនៅឡើយ តើមានរឿងអ្វីកើតឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ នោះ? បន្ទាប់ពីលោកដឹងថា របប លន់ នល់ ដួលរលំនោះ?

**ឆ៖** សូមបញ្ជាក់សំណួរសាដើមវិញ។

**ស៖** អរគុណលោក។ នៅខែមេសា ឆ្នាំ៧៥ លោកនៅជាសង្ឃនៅឡើយទេ លោកប្រាប់នឹងចៅក្រមស៊ើបអង្កេតថាអ៊ីចឹង ហើយបន្ទាប់មក នៅថ្ងៃទី១៧ ខែមេសា ៧៥ នោះ បន្ទាប់ពីរបប លន់ នល់ ដួលរលំនោះ តើមានអ្វីកើតឡើងចំពោះលោកទេ?

[១៥:៣១:៥៦]

**ឆ៖** បន្ទាប់មក លោកដែលចេញមកពីក្នុង មកពីក្រុង ក្រុងភ្នំពេញ ក្រុងតាកែវ មកមូលគ្នា ជួបជុំគ្នា ឃើញ-- ឮថា អង្គការឲ្យលាចាកសិក្ខាបទ សឹក ហើយខ្ញុំក៏លាចាកសិក្ខាបទជាមួយគ្នាហ្នឹង ប៉ុនមិនចាំថ្ងៃខែច្បាស់លាស់ទេ។ ប៉ុន្តែគ្រាន់តែបន្ទាប់ពី មេសា ហ្នឹងមក តៗមក។

**ស៖** ខ្ញុំសូមរំឭកលោកមួយសាទៀត លោកបានឆ្លើយប្រាប់នឹងចៅក្រមស៊ើបអង្កេតថា ផែនការឲ្យលោកសង្ឃសឹកនេះ មានតាំងពីយូរមកហើយ ជាទូទៅលោកសង្ឃដឹងជាមុនស្រេចទៅហើយ។ តើលោកដឹងដែលផែនការសឹកលោកសង្ឃជាមុនហ្នឹង តើដឹងរបៀបម៉េចលោក?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ សូមអញ្ជើញលោកមេធាវី!

[១៥:៣៣:២៧]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន។ សហព្រះរាជអាជ្ញាបានលើកអំណះអំណាងខ្លះ ដែលខ្ញុំរកមិនឃើញនៅក្នុងចម្លើយរបស់សាក្សី។ ម្យ៉ាងទៀតសាក្សីឆ្លើយថា ចម្លើយគាត់មានលើសពីមួយទៅទៀត ហើយខ្ញុំផ្ទៀងចម្លើយរបស់គាត់នៅពេលនេះ ដូចមិនឃើញចំណុចដែលព្រះរាជអាជ្ញាលើកសោះ។ ឧទាហរណ៍

ដូចជាទាក់ទង តាម៉ុក បួសដប់ឆ្នាំអីណានោះ អ៊ីចឹងខ្ញុំរកមិនឃើញ អ៊ីចឹងស្នើសុំឲ្យព្រះរាជអាជ្ញាចង្អុលបង្ហាញ ហើយលេខ ERN ឬលេខឯកសារ ដែលលោកយោងនោះផង ដើម្បីឲ្យភាគីតាមដាន។ សូមអរគុណ។

[១៥:៣៤:១១]

**លោក វ៉េង ហ៊ត់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារហ្នឹង ទៅមេធាវីបន្តិច ក៏ប៉ុន្តែខ្ញុំមិនមានបំណងបង្ហាញនៅក្នុងអេក្រង់ទូរទស្សន៍ទេបាទ។ បើលោកប្រធានអនុញ្ញាត ខ្ញុំសូមអានជូនមេធាវីបន្តិច?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកមេធាវី អាង ឧត្តម។ ឯកសារនេះ មាននៅក្នុង E3/507។ ERN ខ្ញុំមិនបានព្រាងទុក អ៊ីចឹងសូមលោកអធ្យាស្រ័យ ខ្ញុំឲ្យ ERN ជាខ្មែរទេ 00355438 ដល់ 00355442។

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** សាក្សី ខ្ញុំសូមសួរលោកបន្តទៀត។ ក្រោយថ្ងៃ១៧ មេសា តើប្រជាជនធម្មតានៅភូមិភាគនិរតីអាចប្រតិបត្តិតាម-- ប្រតិបត្តិសាសនាព្រះពុទ្ធបានដែរឬទេ?

**លោក ឌៀវ នៅ៖**

**ឆ៖** អាចប្រតិបត្តិបាន ប៉ុន្តែបន្តិចបន្តួច មិនបានពេញអង្គទេ។ នេះចំពោះតែស្រុកត្រាំកក់ ដែលខ្ញុំដឹង កន្លែងផ្សេងៗទៀត ខ្ញុំមិនដឹងទេ។ មិនពេញភូមិភាគទេ ខ្ញុំដឹងតែៗក្នុងស្រុកត្រាំកក់ ហើយដឹងតែពីរកន្លែងទៀត គឺលោកវត្តអង្គរកា និងឈិតជ្រំ(?) តែប៉ុណ្ណឹង។

[១៥:៣៦:៣០]

**ស៖** ហើយក្រោយថ្ងៃ១៧ មេសា នេះព្រះសង្ឃគេឲ្យប្រតិបត្តិ ឬក៏កាន់សាសនាព្រះពុទ្ធនៅក្នុងវត្តដែរទេ?

**ឆ៖** នៅ-- ដែលខ្ញុំលាចាកសិក្ខាបទជាមួយព្រះសង្ឃភាគច្រើនហើយ នៅសល់ខ្លះទៅឯវត្តឈិតជ្រំ ត្រង់នេះខ្ញុំភ្ជាប់មិនបានសព្វគ្រប់ទេ ប៉ុន្តែខ្ញុំមានទៅថ្វាយបង្គំលោក សមគួរនឹងលោកដែរ លោកដែលមិនទាន់លាចាក។ ហើយតមកក្រោយទៀត ក៏អត់បានទៅចាំច្បាស់តាមមើលក្នុងពេលដែលលោក

លាចាកសិក្ខាបទទៀត ថ្ងៃណាខែណា គឺអត់បានចាំទេ គ្រាន់ដឹងថានៅសល់ប៉ុណ្ណឹង។ ហ្នឹងក្នុងស្រុកត្រាំកក់។ ហើយតែពីវត្តហ្នឹងទេ ដឹងបាទ។

**សៈ** អរគុណលោក។ ឥឡូវនេះ ខ្ញុំសួរលោក ខៀវ នៅ ទាក់ទងជាមួយនឹងការជម្លៀសប្រជាជនវិញម្តង។ លោកនិយាយនៅក្នុងចម្លើយជាមួយចៅក្រមស៊ើបអង្កេតថា "នៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ លោកឃើញមនុស្សជាច្រើនធ្វើដំណើរនៅតាមផ្លូវ ហើយលោកថា មនុស្សទាំងនោះត្រូវបានគេជម្លៀសពីភ្នំពេញ និងតាកែវ"។ លោកអាចប្រាប់តុលាការបានទេ អំពីអ្វីដែលលោកបានឃើញនៅពេលនោះ?

[១៥:៣៨:២៣]

**ឆៈ** ក្នុងៗការឃើញ ឃើញត្រឹមវត្តចំប៉ា មកដល់ត្រពាំងធំទេ ដែលចេញពីភ្នំពេញ ចេញពីតាកែវ ចេញពីអីគ្រាន់ឮៗគេនិយាយតគ្នាទេ មិនបានឃើញទេ។ ហើយជាពិសេសគឺអ្នកស្រុកខ្ញុំ មកជួបជុំគ្នា ដែលស្គាល់គ្នាហ្នឹង។ ឯដំណើរវែងឆ្ងាយ ពីភ្នំពេញ ពីតាកែវមកមិនបានឃើញផ្ទាល់ទេ មកឃើញចុងដំណើរ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី លោកចង់និយាយរឿងអីទៅនុ៎ង។

**លោក អាកទូរ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។ ដោយខ្លី នៅពេលដែលខ្ញុំធ្វើការជំទាស់អម្បាញ់មិញទាក់ទងទៅនឹងការរំឭកការចងចាំរបស់សាក្សី ទៅលើសំណួរទីមួយរបស់សហព្រះរាជអាជ្ញាមានការឆ្លើយមកខ្ញុំវិញថា ជារឿងធម្មតាទេ ជាការប្រើប្រាស់ធម្មតា ហើយ-- គឺពីព្រោះថាគាត់សួរទាក់ទងទៅនឹងបរិបទទូទៅនៃប្រធានបទដែលគាត់នឹងនិយាយ។ ឥឡូវនេះ យើងចូលមកនិយាយពីអង្គហេតុទាក់ទងទៅនឹងរយៈពេលបន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហើយចាប់គ្រាន់តែពីសំណួរទីមួយមកភ្លាមហ្នឹង សហព្រះរាជអាជ្ញាជាតិបាននិយាយឡើងវិញដដែល គឺថាគាត់ធ្វើរំឭកទៅដល់សាក្សី អំពីអ្វីដែលគាត់ធ្វើពីមុនមក ហើយដែលចោទសំណួរបើកចំហ។ ខ្ញុំគិតថា ហាក់ដូចជា ព្រោះថា ត្រូវគិតថាឥឡូវនេះ យើងវាទាក់ទងទៅនឹងអង្គហេតុទេ ដែលយើងត្រូវនិយាយនោះ។ ហើយខ្ញុំមិនដឹងថា ខ្ញុំនិយាយនេះបានច្បាស់លាស់ដែរឬក៏អត់នោះទេ។

**ប្រធានអង្គជំនុំ៖**

លោកនិយាយសាជាថ្មីម្តងទៀតឲ្យច្បាស់ ពីព្រោះដល់ មកដល់៧៩ ដូចជា យើងជាប្រធានអង្គជំនុំជម្រះហ្នឹងស្តាប់អត់មានឮដល់៧៩ទេ។ ក្រោយ៧៥ ដែលលោកមកថ្លែងការណ៍ថាក្រោយ៧៩នេះ វាឆ្ងាយពីគ្នាពេក។ លោកបញ្ជាក់ឲ្យច្បាស់លាស់មើល៍ ជំហររបស់លោកយ៉ាងម៉េចលើបញ្ហាជំទាស់នេះ។

អង្គជំនុំជម្រះសូមរំឭកមេធាវី និងភាគីថា ប្រសិនបើត្រូវការជំទាស់ងើបឈរ ឬក៏លើកដៃជំទាស់ភ្លាមមុនពេលសាក្សីឆ្លើយតបទៅនឹងសំណួរ។ មិនមែនឆ្លើយចប់ហើយ បានជំទាស់នោះទេ។

ឥឡូវដើម្បីដោះស្រាយបញ្ហាឲ្យច្បាស់លាស់ដដែលៗ លោកបញ្ជាក់ឲ្យច្បាស់លាស់សាជាថ្មីម្តងទៀតមើល៍លើបញ្ហាគំនិតជំទាស់នេះ វាយ៉ាងម៉េច?

[១៥:៤១:៤៤]

**លោក អាកទូរ វែកគែន៖**

បាទ លោកប្រធាន។ ខ្ញុំគិតថា ខ្ញុំនិយាយអំមិញច្បាស់គួរសមហើយ ក៏ប៉ុន្តែប្រហែលជាមានបញ្ហាបកប្រែបន្តគ្នាហ្នឹងគឺមានបញ្ហា បង្កឲ្យមានថាមានការនិយាយច្បាស់លាស់ហើយ បកប្រែទៅមិនសូវច្បាស់ទៅដល់អ្នកស្តាប់។ ខ្ញុំមិនរិះគន់ទៅដល់អ្នកបកប្រែនោះទេ។

សហព្រះរាជអាជ្ញាជាតិ កំពុងតែសួរសំណួរទាក់ទងទៅនឹងការជម្លៀស គឺជាអង្គហេតុដែលអង្គជំនុំជម្រះត្រូវបានប្តឹងហើយ ហើយគាត់និយាយអំពីនេះ ចៀសជាងសួរសាក្សីដោយប្រើសំណួរចំហ។ សំណួរទីមួយរបស់គាត់ គឺមានបំណងចង់រំឭកឲ្យសាក្សីនូវអ្វីដែលសាក្សីបាននិយាយពីពេលមុនមកនៅពេលដែលគាត់ត្រូវបានស្តាប់ដោយអ្នកស៊ើបអង្កេត នៃចៅក្រមស៊ើបអង្កេត ហើយក៏ខ្លឹមសារនៃការជំទាស់របស់ខ្ញុំនោះ ចង់ជម្រាបជូនអង្គជំនុំជម្រះថា ខ្ញុំយល់គឺថានៅពេលដែលយើងនិយាយអំពីបរិបទទូទៅ ដែលមិនមានការជំទាស់។ អ៊ីចឹងគឺថា ការអនុវត្តបែបនេះយើងអាចទទួលបាននូវពេលនិយាយពីបរិបទទូទៅ។ ក៏ប៉ុន្តែនៅពេលដែលយើងនិយាយពីអង្គហេតុនៅជាបឋមនោះ យើងត្រូវចោទសំណួរជាចំហសិន ចៀសជាងក្នុងការរម្លឹកការចងចាំរបស់សាក្សីភ្លាមៗតែម្តងនោះ។

[១៥:៤៣:២៦]

**ប្រធានអង្គជំនុំ៖**

កុំអាល! សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តី-- អន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ទាក់ទងនឹងចំណុចនេះ ខ្ញុំហាក់ដូចជាមិនយល់អំពីអនុស្សរណៈរបស់អង្គជំនុំជម្រះលើកមុន ក៏ប៉ុន្តែ ក្នុងថា អង្គជំនុំជម្រះបាននិយាយថា មិនចាំបាច់ចោទសំណួរ សំណួរជាស្វ័យប្រវត្តិដើម្បីផ្ទៀងផ្ទាត់ចម្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយនោះទេ។ ដោយគិតថា ខ្លឹមសារនៅក្នុងកំណត់ហេតុនេះអាចចាត់ទុកថាជាការពិតបាន។ ដូច្នេះ យើងអាចចោទសំណួរឲ្យហួសពីអ្វីដែលមាននិយាយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី។ ហើយអាស្រ័យហេតុដូច្នេះហើយ បានជាសហព្រះរាជអាជ្ញាចោទសំណួរយ៉ាងដូច្នេះ ដែលធ្វើឲ្យយើងអាចចំណេញពេលវេលា។

[១៥:៤៤:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះចេញអនុស្សរណៈមុននេះ ប្រហែលជាអស់លោកទាំងអស់គ្នាមិនទាន់បានដឹងទេ តែគំនិតរបស់អង្គជំនុំជម្រះ គឺថា គឺធ្វើយ៉ាងណាឲ្យការប្រើពេលវេលាឲ្យមានប្រសិទ្ធភាព ជាពិសេស គឺថានៅពេលដែលយើងត្រូវស្តាប់ចម្លើយសាក្សីដែលត្រូវបានស្តាប់ដោយសហចៅក្រមស៊ើបអង្កេតហើយៗ គឺសាក្សីដែលយើងអនុញ្ញាតឲ្យគាត់អានចម្លើយសាក្សីរបស់គាត់ ហើយលោកប្រធានរាល់ពេលស្តាប់ចម្លើយសារភាពគាត់បានសួរសំណួរទៅគាត់ ហើយថា តើគាត់យល់ស្របនឹងចម្លើយរបស់គាត់ឬអត់? ចម្លើយដែលគាត់ឆ្លើយទៅសហចៅក្រមស៊ើបអង្កេត។ ដូច្នេះនៅពេលដែលពុំមានការជំទាស់ទេ ដូច្នេះយើងមិនចាំបាច់ចោទសំណួរទៅលើសាក្សីនោះ សួរគាត់តាំងពីដើមមកវិញ គឺថាយើងត្រូវសួរតែសំណួរបន្ថែមទៅបានហើយ ដោយសារហេតុនេះហើយបានថា ការសង្ខេបនៃចម្លើយពីមុនៗមកនោះវាជាមិនរឿងអីចម្លែកទេនោះ។ យើងត្រូវដឹង ថាតើនៅពេលមានការយល់ស្របពីគាត់ឬអត់ មានភាពខុសគ្នា ឬអត់ អ៊ីចឹងយើងត្រូវសង្កត់ធ្ងន់លើចំណុចនេះ។

[១៥:៤៦:០៦]

**លោក អាកទួរ វែកគែន៖**

ខ្ញុំបាទ ខ្ញុំសូមបញ្ជាក់ថា សាក្សីនេះបានជម្រាបជូនអង្គជំនុំជម្រះហើយថា មានភាពខុសគ្នានៅខ្លឹមសារនៃអ្វីដែលគាត់បានអានពីមុននោះ មិនគិតថាជាលក្ខណៈលម្អិតនោះទេ។ ក៏ប៉ុន្តែឥឡូវនេះយើង

ធ្វើហាក់ដូចជាថា មិនដឹងជាមានភាពខុសគ្នាបន្តិចបន្តួច ដែលចំពោះខ្ញុំនេះខ្ញុំគិតថា យើងគួរតែធ្វើការប្រុងប្រយ័ត្នដែរ ចំពោះសាក្សីនេះ សក្ខីកម្មរបស់សាក្សីដែលមានវត្តមាននៅទីនេះ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោកមេធាវីទម្លាប់លោកអ៊ីចឹងឬក៏យ៉ាងម៉េច? និយាយដល់ទីបញ្ចប់ដល់សម្រេចហើយទើបនឹងងើបមក។ ចង់និយាយរឿងអីគេនុ៎ង?

[១៥:៤៧:០៧]

**លោក អាង ឧត្តម៖**

សូមទោសលោកប្រធាន ដោយសារខ្ញុំមើលខាងវេនខាងមេធាវីជាប់គ្នាអ៊ីចឹងថា អាចអនុញ្ញាតឲ្យខ្ញុំនិយាយបាន តែបើខ្ញុំមិនអាចនិយាយបាន-- ខ្ញុំមិនបានផ្ទុះពីម្ខាងទៅម្ខាងទេ។ តែបើលោកប្រធានអនុញ្ញាតឲ្យខ្ញុំនិយាយ ខ្ញុំសូមនិយាយតែបន្តិច។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក អាង ឧត្តម៖**

ដូចលោកបញ្ជាក់ លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ អំមិញបានមានប្រសាសន៍ យោងទៅតាមសេចក្ដីសម្រេចរបស់អង្គតុលាការរួចហើយថា បើសាក្សីបានសម្ដែង ថ្លែងនូវបញ្ជាក់ការពិតអ្វីដែលគាត់បានឆ្លើយនោះហើយ យើងមិនគួរសួរគាត់ឡើងវិញពីចំណុចនេះទេ។ តែខ្ញុំកត់សម្គាល់ឃើញថា ចាប់ផ្ដើមពីមួយចំណុចទៅមួយចំណុចសហព្រះរាអាជ្ញាបានអានសេចក្ដីថ្លែងការណ៍របស់សាក្សី ដើម្បីរំឭកការចងចាំរួចហើយ លោកព្យាយាមនឹងសួរសំណួរជាខាងក្រោយទៅវិញ តើនេះចាំបាច់ដែរឬទេ? ហើយនេះ តើពិចារណាថាជាសំណួរនាំមុខដែរឬអត់? ពីព្រោះផ្ដល់មូលដ្ឋាន ផ្ដល់ចម្លើយឲ្យសាក្សីបញ្ជាក់អ៊ីចឹង វាពិចារណាថាជាសំណួរនាំមុខ ឬក៏ជាសំណួរប្រាសចាកនឹងបញ្ញត្តិ ដែលតុលាការបានចេញពីមុនឬអត់? សូមអរគុណ។

[១៥:៤៨:២២]

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជជាតិ រៀបចំការតាំងសំណួរសាជាថ្មី ឲ្យបានសមស្របបំផុតទៅតាមសេចក្ដីណែនាំ ហើយគួរតែចៀសវាងបំផុត ឲ្យផុតពីការជំទាស់តវ៉ា ចំណាយពេលវេលាឥតប្រយោជន៍

ហើយរហូតដល់អម្បាញ់មិញនេះលោកបានប្រើពាក្យថា លោកអត់បានត្រៀមរៀបចំជាមុនទេ។ អ៊ីចឹងហើយបានមិនអាចផ្តល់លេខ ERN ជាភាសាបារាំង ភាសាអង់គ្លេសបាន។ ជាការអាម៉ាស់មួយដែលថាមកតតាំងក្តីហើយ ហើយពេលវេលាគ្រប់គ្រាន់បែរថា មិនបានត្រៀមរៀបចំនោះ។ សូមតាំងសំណួរឯណាដែលត្រឹមត្រូវ ហើយនិងលឿន ជាក់ច្បាស់។ មិនគប្បីយកចម្លើយដដែលមកសួរសាក្សីទៀតទេ ជ្រើសរើសសំណួរថ្មីៗបន្ថែមដើម្បីសួរចំពោះសាក្សីរូបនេះ។

[១៥:៤៩:៤៧]

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ។

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** លោក ខៀវ នៅ ខ្ញុំសូមសួរសំណួរលោកថា ហេតុអ្វីបានលោកដឹងថា មនុស្សទាំងនោះត្រូវបានគេជម្លៀសមកពីភ្នំពេញ ហើយជម្លៀសមកពីតាកែវនោះ?

**លោក ខៀវ នៅ៖**

**ឆ៖** មករាប់រយរាប់ពាន់អ៊ីចឹងគឺ អ្នកស្រុក អ្នកនិយាយភាគច្រើនគឺ និយាយពេញដីតែម្តង។ ហើយមួយទៀត អ្នកដែលស្គាល់គ្នា ដែលនៅភ្នំពេញ សាច់ញាតិអីភ្នំពេញ សាច់ញាតិនៅតាកែវ មកជួបគ្នាបានសួរដំណឹងហ្នឹង។

**ស៖** អរគុណលោក។ ខ្ញុំសួរសំណួរមួយទៀត។ នៅពេលដែលមានការជម្លៀសនោះ ហើយលោកបានឃើញមនុស្សរាប់រយរាប់ពាន់នោះ តើលោកមានបានឃើញព្រះសង្ឃត្រូវបានគេជម្លៀសដែរទេ?

[១៥:៥១:០៥]

**ឆ៖** រឿងព្រះសង្ឃ ខ្ញុំបានបញ្ជាក់នៅក្នុងសំណួរខាងដើម ថាលោកមន្តមកពីតាកែវ មកពីភ្នំពេញមកជួបជុំគ្នានៅវត្តអង្គរកា ខ្ញុំក៏នៅទីនោះដែរ ហើយត្រូវលាចាកសិក្ខាបទជាមួយគ្នាមួយចំនួន។ ហ្នឹងសំណួរលើកមុន ខ្ញុំបញ្ជាក់អ៊ីចឹង។ ហើយបញ្ជាក់ថែមបន្តិចទៀតថា ហ្នឹងហើយលោកដែលជម្លៀសមកពីភ្នំពេញ ពីតាកែវ។

**ស៖** អរគុណលោក។ នៅក្នុងស្ថានភាពដែលលោកឃើញ អ្នកជម្លៀសជាច្រើន តើលោកបានឃើញជនដែលងាយរងគ្រោះ ដូចជា កុមារតូចៗ មនុស្សចាស់ជរា អ្នកមានជំងឺ។ តើកម្មាភិបាលខ្មែរ

ក្រហមមានរៀបចំកន្លែងស្រួលបួល សម្រាប់ពួកគាត់ទេ?

**ឆ៖** ខ្ញុំមិនបានដើរមើលសព្វទីសព្វកន្លែងទេ។ មិនមានដើរមើលសព្វទីសព្វកន្លែងអីទូទៅ។ ដូច្នេះ មិនអាចនិយាយទូទៅបាន ថាយ៉ាងនេះយ៉ាងនោះ ការរៀបចំអីយ៉ាងនេះយ៉ាងនោះ។ ប៉ុន្តែដែលបាន ឃើញខ្លះគឺមានការរៀបចំ រៀបចំទុកដាក់ធ្វើដាក់ធ្វើអីយ៉ាងម៉េច ឈឺស្កាត់អី គឺមាន ប៉ុន្តែទូទៅច្រើនគឺ មិនបានឃើញផ្ទាល់ទេ ព្រោះដំណើរលោកសង្ឃមានទៅដើរធ្វើការពេញដីឯណា អត់ទេ។

**ស៖** អរគុណលោក ខៀវ នៅ។ ខ្ញុំសួរលោកទៀត។ កម្មាភិបាលខ្មែរក្រហម មានដើរតាមពួក ប្រជាជនដែលជម្លៀសនោះទេ?

[១៥:៥២:៥៤]

**ឆ៖** ឃើញដើរ ប៉ុន្តែនិយាយជាទូទៅមិនបានៗ ឃើញទូទៅទេ ប៉ុន្តែដើរឃើញមានដើរហើយ ចាត់ចែងត្រូវស្នាក់នៅត្រង់ណាអីត្រង់ណា ដើរអាហ្នឹងមានដើរ។

**ស៖** អរគុណលោក។ នៅពេលដែលកម្មាភិបាលដើរ ឬក៏ចាត់ចែងសម្រាប់ប្រជាជនស្នាក់នៅ ត្រង់ណាអីត្រង់ណា លោកមានប្រសាសន៍អម្បាញ់មិញ។ តើប្រជាជនគាត់មានសេរីភាពក្នុងការដើរ ចេញពីកម្មាភិបាលខ្មែរក្រហមហ្នឹងបានទេពេលហ្នឹង?

**ឆ៖** ខ្ញុំមិនបានពិនិត្យល្អិតដល់ថ្នាក់ហ្នឹងទេ ព្រោះមកព្រោងព្រាតពេញទឹកពេញដី។ ប៉ុន្តែកាល ហ្នឹងមិនទាន់រៀបចំចងជាពួកជាក្រុមទេ មកគ្រាន់តែធ្វើម៉េច ឲ្យតែបានបាយហូប ឲ្យមានកន្លែងគួរសម នោះ។ អាត្រង់របៀបរៀបរយ បើស្រុកផ្សេងៗគ្នា គ្រាន់តែសួរថាត្រូវទៅណាៗ ស្រុកកំណើតនៅឯណា ក៏ឲ្យទៅតាមហ្នឹងទៅ។ អាហ្នឹងសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** តាមការសង្កេតរបស់លោក ខ្ញុំសួរលោកថា តើលោកដឹងមូលហេតុអ្វីបានមនុស្សទាំងនោះ ចេញពីទីក្រុងភ្នំពេញដែរទេ?

**ឆ៖** ដឹងតៗគ្នាមកថាជម្លៀសចេញ ប៉ុនមិនមែនដឹងច្បាស់ពីមេធំកំពូលមកទេណា ដឹងតាមពួក ឈ្លបអីនិយាយ ក្មេងក្មាំងអីពួកឈ្លប ពួកទាហាននិយាយ។ អាហ្នឹងមិនពេញអង្គជាផ្លូវការទេ។

[១៥:៥៤:៥២]

**ស៖** បាទ ក្រៅពីពួកឈ្លបនិយាយ តើលោកមានបានពិភាក្សាជាមួយ តាម៉ុក ស្តីពីការជម្លៀស ដែរទេ?

**ឆ៖** អត់បាន ពេលហ្នឹង អត់បានទៅជួប តាម៉ុក ពិភាក្សាអីវែងឆ្ងាយទេ។ មិនបានទៅជួប

ពិភាក្សាទេ។ ទៅពេលហ្នឹង គឺតែពួកភូមិ ពួកឃុំ ពួកហ្នឹង ទៅទទួល តែប៉ុណ្ណឹងទេ ហើយនិងពួកឈ្លប ភូមិ ឈ្លបឃុំហ្នឹងទៅទទួល។

**ស៖** អរគុណ។ តើ តាម៉ុក មានឲ្យ អនុញ្ញាតឲ្យលោកធ្វើការអ្វីជាមួយលោកគាត់ទេ?

**ឆ៖** សូមសួរបញ្ជាក់ តើពេលណា?

**ស៖** នៅមុនឆ្នាំ-- នៅក្នុងខ្ទង់ឆ្នាំ៧៥ ទៅ៧៦ ហ្នឹង តើ តាម៉ុក មានអនុញ្ញាត ឬក៏អញ្ជើញលោក ហៅលោកទៅធ្វើការអ្វីជាមួយគាត់ទេ?

**ឆ៖** មានហៅទៅ ប៉ុន្តែទៅមុនដំបូង អត់មានធ្វើការងារអីទេ។ ទៅនៅទំនេរ បើខ្ញុំមិនសួរជាខ្លួនផង ប៉ុនគ្រាន់តែ គាត់គ្រាន់តែប្រាប់ថា អើ! ឲ្យមកជួយកាន់លុយ ប៉ុនមិនទាន់បានកាន់ទេ។ ឯការងារអត់ មិនទាន់មានទេ ប៉ុន្តែអាចជួយក្រៅខ្លះ ជួយរាប់របស់នេះ របស់នោះ ដែលពួកឡានដឹកមកហ្នឹងជួយរាប់ ជួយមើលបន្តិចបន្តួច ហើយពួកទាហាន ពួកឃោធាកាប់ ដាំចេក ដាំអំពៅអី គ្រាន់តែថាជួយធ្វើស្មៀតចប ធ្វើអី តែប៉ុណ្ណឹងទេ មិនបានធ្វើអីធំដុំទេ។

[១៥:៥៦:៥៤]

**ស៖** ពេលនោះ លោកដឹងថាមានការបង្កើតជាសហករណ៍ហើយនៅ?

**ឆ៖** សហករណ៍ហ្នឹង គឺខ្ញុំមិនបានកំណត់ថ្ងៃខែឆ្នាំអីត្រឹមត្រូវទេ មិននេះទេ។ ដល់កើតៗតែម្តងទៅ ហើយមិនយកចិត្តដាក់ថា ត្រូវឆ្នាំណា ខែណា ថ្ងៃណា។ អត់បានកំណត់អី កត់ត្រាអីទេ។

**ស៖** លោកដឹងថាអ្នកណាបង្កើតសហករណ៍ទេ ពេលនុ៎ង?

**ឆ៖** កិច្ចទូទៅ យើងៗមិនមែនជាអ្នកនយោបាយ មិនមែនជាអ្នកយកការណ៍ហ្នឹង យើងកំណត់ដឹងថា ចាំស្តាប់ថាកាលហ្នឹង ប្រើពាក្យ "អង្គការ"។ អង្គការឲ្យធ្វើនេះ អង្គការឲ្យធ្វើនោះ មិនចេញឈ្មោះបុគ្គលទេ។

**ស៖** បាទ ខ្ញុំសួរសំណួរតទៀត លោកដែលឮថា មនុស្សណាម្នាក់ត្រូវបានគេថា ជាខ្មាំងដែរទេ នៅក្នុងសម័យនុ៎ង?

**ឆ៖** ឮ ចេះតែឮតៗមក អត់ឮជាផ្លូវការមែនទែនទេ តៗ គេនិយាយ តែប៉ុន្មានច្រើនតំណាមក ហើយហ្នឹងមាន តែជាផ្លូវការច្បាស់លាស់នោះ នឹកទៅមិនឃើញ។ ហើយប្រសិនជាឮ ក៏បែបមិនយកចិត្តទុកដាក់ ភ្លេច។

[១៥:៥៨:៤៥]

**ស៖** ហើយនៅពេលដែលលោកឮថា មនុស្សណាម្នាក់ដែលគេចោទថា ខ្មាំង នោះ តើលោកដឹងថាមានអ្វីកើតឡើងចំពោះជននោះទេ?

**ឆ៖** ខ្ញុំមិនបានដឹងច្បាស់ទេ ដល់ហ្នឹង ល្អិតវែងឆ្ងាយ មិនបានដឹងច្បាស់ទេ។

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន ខ្ញុំសូមបញ្ចប់សំណួរខ្ញុំប៉ុណ្ណេះ ហើយអរគុណក្រុមប្រឹក្សាជំនុំជម្រះ។ អរគុណភាគីទាំងអស់ និងអរគុណលោក ខៀវ នៅ។ ហើយលោកចាំជួយឆ្លើយសំណួរជាមួយនឹងសហការីរបស់យើងខ្ញុំ។ បាទ អរគុណលោក។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ខៀវ នៅ។ ឥឡូវនេះ លោក ខៀវ នៅ ពេលវេលាសមល្មមនឹងសម្រាកហើយ ហើយអង្គជំនុំជម្រះសូមជម្រាបលោក ខៀវ នៅ ថាកិច្ចដំណើរការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី២១ ខែមិថុនា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនសាក្សីវិលត្រឡប់ទៅកាន់ទីកន្លែងគាត់ស្នាក់នៅ និងឲ្យនាំគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅក្នុងបន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

[១៦:០០:៥៥]

កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺដល់ពេលល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើទៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២១ ខែមិថុនា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

សវនាការនៅថ្ងៃស្អែកនេះ នឹងបន្តធ្វើដោយការតាំងសំណួរដេញដោល ចំពោះសាក្សី ខៀវ នៅ ដោយតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយបើពេលវេលាអាចអំណោយផលហ្នឹង នឹងបន្តដល់ក្រុមមេធាវីការពារក្តីទៀត។ សូមភាគី និងសាធារណជនជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក

វិញចុះ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ដោយឡែកលោក អៀង សារី ប្រសិនបើលោក អៀង សារី បង្ហាញជំហរច្បាស់លាស់គាត់លះបង់សិទ្ធិចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ ដោយសុំបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទាប់ឃុំខ្លួនមួយក្រោមបន្ទប់សវនាការនេះ តាមរយៈពាក្យសុំលាយលក្ខណ៍អក្សរបានមុនកិច្ចដំណើរស្តាប់សក្ខីកម្មសាក្សីនោះ សូមអនុរក្សមន្ទីរឃុំឃាំងទំនាក់ទំនងជាមួយនឹងក្រឡាបញ្ជីសវនាការ ដើម្បីទទួលព័ត៌មាន ហើយនិងឲ្យនាំលោក អៀង សារី មកត្រឹមបន្ទប់ឃុំខ្លួនមួយ ដែលមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ឯការសម្រេចលើពាក្យសុំរបស់លោក អៀង សារី អង្គជំនុំជម្រះនឹងពិចារណាសម្រេចឲ្យបានមុនពេលដំណើរការសួរដេញដោលសាក្សី។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៣នាទី)*